# ការគ្រប់គ្រងរដ្ឋបាលស្រុក



ខែកុម្ភៈ ឆ្នាំ២០២០

សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ

# អារម្ភកថា

បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាទទួលបានសន្តិភាព ឯកភាពជាតិ និងឯកភាពទឹកដីពេញលេញនៅទូទាំងប្រទេសនាចុងឆ្នាំ១៩៩៨ តាមរយៈការអនុវត្តនយោបាយឈ្នះ-ឈ្នះ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី២នៃរដ្ឋសភាបានចាប់ផ្តើមអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់នាឆ្នាំ២០០២ និងបានពង្រីកវិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនេះនៅថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌនៅទូទាំងប្រទេសនាឆ្នាំ២០០៩។ ក្នុងរយៈពេលប្រមាណ១៨ឆ្នាំកន្លងមកនេះ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបាននាំមកនូវសមិទ្ធផលនានាជាច្រើនទាំងផ្នែកនយោបាយ រដ្ឋបាល និងសេដ្ឋកិច្ច សង្គម ក្នុងនោះមានជាអាទិ៍៖

- ការបោះឆ្នោតដោយផ្ទាល់ជ្រើសរើសក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ចំនួន៤លើក
- ការបោះឆ្នោតអសកលជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌចំនួន៣លើក
- ការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃរដ្ឋបាលឯកភាព និងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ការបង្កើតប្រព័ន្ធកសាងផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ការបង្កើតប្រព័ន្ធផ្ទេរធនធានហិរញ្ញវត្ថុពីថ្នាក់ជាតិទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈការបង្កើតឡើងនូវមូលនិធិក្រុង ស្រុក និងមូលនិធិឃុំ សង្កាត់
- ការផ្ទេរមុខងារពីក្រសួង ស្ថាប័នឱ្យទៅរដ្ឋបាលថ្នាក់ក្រោមជាតិដោយភ្ជាប់ជាមួយធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស
- ការធ្វើសមាហរណកម្មបុគ្គលិកដែលបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ចូលទៅក្នុងរចនាសម្ព័ន្ធថ្មីនៃរដ្ឋបាលថ្នាក់ក្រោមជាតិ
- ការចូលរួមចំណែករបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋ ប្រកបដោយតម្លាភាព គណនេយ្យភាព បរិយាប័ន្ន និងសមធម៌សង្គម តាមរយៈការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការផ្តល់សេវាសង្គមនានា ដែលជាតម្រូវការចាំបាច់ជាក់ស្តែងរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

លើសពីនេះទៀត ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងរដ្ឋបាល ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ការិយាល័យ អង្គភាពជំនាញនានា ដែលពីមុនជាខ្សែបណ្តោយរបស់ក្រសួង ស្ថាប័ន នៅថ្នាក់ស្រុកត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងរដ្ឋបាលស្រុក តាមរយៈ *អនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក* ដែលចូលជាធរមានចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០២០តទៅ។

សៀវភៅ *ការគ្រប់គ្រងរដ្ឋបាលស្រុក* នេះត្រូវបានរៀបចំឡើងសម្រាប់ក្រុមគោលដៅជាក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិកនៅរដ្ឋបាលស្រុក ដើម្បីជាជំនួយក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព សំដៅបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅមូលដ្ឋានរបស់ខ្លួន។

ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះសារៈសំខាន់នៃសៀវភៅនេះ និងមានការជឿជាក់ថា សៀវភៅនេះនឹងជួយឱ្យក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិកនៅរដ្ឋបាលស្រុកមានភាពងាយស្រួលក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួនបានយ៉ាងល្អប្រសើរ ដើម្បីបុព្វហេតុក្នុងការបម្រើសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ និងការអភិវឌ្ឍមូលដ្ឋាន សំដៅលើកកម្ពស់គុណភាពជីវិតរស់នៅរបស់ប្រជាពលរដ្ឋនៅមូលដ្ឋានឲ្យកាន់តែប្រសើរ ប្រកបដោយសុខុមាលភាព វិបុលភាព និងសុខក្សេមក្សាន្ត។

ខ្ញុំសូមសម្តែងនូវការកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់សមាជិកក្រុមការងារទាំងអស់ដែលបានផ្តួចផ្តើមរៀបចំសៀវភៅនេះឡើង។ ទោះបីជាក្រុមការងារខិតខំយកចិត្តទុកដាក់ក្នុងការរៀបចំសៀវភៅនេះឱ្យបានល្អប្រសើរយ៉ាងណាក្តី ក្រសួងមហាផ្ទៃជឿជាក់ថា នៅតែមានចំណុចខ្វះខាត ដែលទាមទារឱ្យមានការចូលរួមយោបល់ដើម្បីកែលម្អបន្ថែមទៀត។ ក្នុងន័យនេះ ក្រសួងមហាផ្ទៃមានសេចក្តីរីករាយ និងរង់ចាំជានិច្ច ក្នុងការទទួលនូវមតិរិះគន់ ក៏ដូចជាអនុសាសន៍នានា សំដៅកែលម្អសៀវភៅនេះឱ្យកាន់តែមានលក្ខណៈឆ្លើយតប និងល្អប្រសើរថែមទៀត។

ថ្ងៃព្រហ៤រោច ខែ[illegible] ឆ្នាំកុរ ឯកស័ក ព.ស ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃ ១២ ខែធ្នូ ឆ្នាំ ២០២០

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**សម្តេចក្រឡាហោម ស ខេង**

## មាតិកា

**ជំពូកទី១÷ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា** ........................ ១
១.១. សាវតារ ........ ១
១.២. អត្ថន័យ ........ ១
១.៣. ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ........ ២
១.៤. ប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ........ ៤
**ជំពូកទី២÷រចនាសម្ព័ន្ធ តួនាទី ភារកិច្ច** ........ ១០
២.១. រចនាសម្ព័ន្ធ ........ ១០
២.២. ក្រុមប្រឹក្សា ........ ១២
២.៣. គណៈកម្មាធិការ និងការិយាល័យប្រជាពលរដ្ឋ ........ ១៥
២.៤. គណៈអភិបាល ........ ២០
២.៥. នាយករដ្ឋបាល ........ ២៣
២.៦. ការិយាល័យ និងអង្គភាពចំណុះ ........ ២៥
**ជំពូកទី៣÷មុខងារ និងធនធាន** ........ ៣៦
៣.១.មុខងារ ........ ៣៦
៣.២.បុគ្គលិក ........ ៣៧
៣.៣.ហិរញ្ញវត្ថុ ........ ៤២
៣.៤.ទ្រព្យសម្បត្តិ ........ ៤៦
**ជំពូកទី៤÷ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាព** ........ ៤៨
៤.១.ទំនាក់ទំនងការងារ ........ ៤៨
៤.២.ខ្សែគណនេយ្យភាព ........ ៥២
**ជំពូកទី៥÷របៀបរបបការងារ** ........ ៥៤
៥.១.ការងាររបៀប ........ ៥៤
៥.២.របបប្រជុំ ........ ៥៤
៥.៣.របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុក ........ ៦១
៥.៤.របាយការណ៍ស្តីពីការអនុវត្តការងាររបស់បុគ្គលិករដ្ឋបាលស្រុក ........ ៦២
៥.៥.លក្ខខណ្ឌការងារ ........ ៦២
៥.៦.ការគ្រប់គ្រងវត្តមានរបស់បុគ្គលិក ........ ៦៣
៥.៧.ការឈប់សម្រាកផ្លូវការ ច្បាប់ឈប់ប្រចាំឆ្នាំ និងច្បាប់ឈប់រយៈពេលខ្លី ........ ៦៤
៥.៨.ការបំពេញបេសកកម្ម ........ ៦៦
៥.៩.ការអនុវត្តទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីរាជការកាតព្វកិច្ចមន្ត្រីរាជការ ........ ៦៨
៥.១០.ការរៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់ការបំពេញការងាររបស់បុគ្គលិក ........ ៦៦
៥.១១.កាតព្វកិច្ចមន្ត្រីរាជការ ........ ៦៦
បញ្ជីឧបសម្ព័ន្ធ ........ ៦៩
សេចក្តីសម្រេចលេខ០០០១ សសរ/អរប ចុះថ្ងៃចន្ទ ៤រោច ខែបុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣ ត្រូវនឹងថ្ងៃទី១៣ ខែមករា ឆ្នាំ២០២០ ស្តីពីការបង្កើតក្រុមការងាររៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិសសម្រាប់ក្រុមគោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ របស់អគ្គនាយកដ្ឋានរដ្ឋបាល ក្រសួងមហាផ្ទៃ។

NASLA

# ជំពូកទី១

# ទស្សនទាននៃកំណែទម្រង់

# វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

NASLA

# ជំពូកទី១

# ទស្សនទាននៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា

## ១.១. សាវតារ

បន្ទាប់ពីប្រទេសជាតិទទួលបានសន្តិភាព ស្ថេរភាពនយោបាយ ឯកភាពជាតិ និងឯកភាពទឹកដីពេញលេញ តាមរយៈការអនុវត្ត"នយោបាយឈ្នះ-ឈ្នះ" ដែលផ្តួចផ្តើមគំនិត និងដឹកនាំអនុវត្តដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** នាចុងឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលកម្ពុជានីតិកាលទី២នៃរដ្ឋសភាបានសម្រេចចិត្តអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ តាមរយៈការដាក់ចេញច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំ២០០១ និងបានរៀបចំបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី០១ នៅឆ្នាំ២០០២។

ដោយមានបទពិសោធន៍ជោគជ័យនៃការអនុវត្តនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ឃុំ សង្កាត់ រាជរដ្ឋាភិបាលបានសម្រេចពង្រីកវិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ក្រោមជាតិទាំងមូល ដោយបានដាក់ចេញនូវច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ នៅឆ្នាំ២០០៨។

ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ បានកំណត់គោលដៅយុទ្ធសាស្ត្រនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជាដូចខាងក្រោម៖

- ពង្រឹង និងពង្រីកលទ្ធិប្រជាធិបតេយ្យនៅមូលដ្ឋាន
- ជំរុញការអភិវឌ្ឍនៅមូលដ្ឋាន និងការកាត់បន្ថយភាពក្រីក្រ។

## ១.២. អត្ថន័យ

សន្ទានុក្រមនៅក្នុងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌបានកំណត់និយមន័យនៃពាក្យ វិមជ្ឈការ និង វិសហមជ្ឈការ ដូចខាងក្រោម៖

***វិមជ្ឈការ*** មានន័យថា រាជរដ្ឋាភិបាលប្រគល់ភាពជាម្ចាស់លើមុខងារ សិទ្ធិអំណាច និងធនធាន (បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ) ឱ្យទៅក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការនៅមូលដ្ឋាន។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋមូលដ្ឋានលើបញ្ហាទាំងនេះ។

***វិសហមជ្ឈការ*** មានន័យថា រាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នធ្វើប្រតិភូកម្មមុខងារ សិទ្ធអំណាច និងធនធាន(បុគ្គលិក ហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ) ទៅឱ្យអង្គភាពក្រោមបង្គាប់ ឬទៅឱ្យក្រុមប្រឹក្សាប្រភេទណាមួយ ដើម្បីអនុវត្តក្នុងនាមរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ននោះ។ ក្នុងន័យនេះ ភាពជាម្ចាស់មិនបានផ្តល់

NASLA

ទៅឱ្យអង្គភាពក្រោមបង្គាប់ ឬក្រុមប្រឹក្សាឡើយ។ អង្គភាព ឬក្រុមប្រឹក្សានោះត្រូវមានគណនេយ្យភាព ចំពោះរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័នស្របទៅតាមតម្រូវការនៃការធ្វើប្រតិភូកម្មនោះ។

## ១.៣. ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់

គោលនយោបាយ និងច្បាប់សំខាន់ៗសម្រាប់គាំទ្រដល់ដំណើរការនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា រួមមាន៖

- យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤
- ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ

ទន្ទឹមនឹងការដាក់ចេញក្របខ័ណ្ឌគោលនយោបាយ និងក្របខ័ណ្ឌច្បាប់ខាងលើនេះ រាជរដ្ឋាភិបាលកម្ពុជាក៏បានរៀបចំនូវកម្មវិធីជាតិរយៈពេល១០ឆ្នាំ សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ កម្មវិធីជាតិនេះ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ដែលការអនុវត្តកម្មវិធីជាតិនេះ ត្រូវបានចែកចេញជាបីដំណាក់កាលតាមរយៈការរៀបចំឱ្យមានផែនការអនុវត្តន៍តាមដំណាក់កាលនីមួយៗ។ ផែនការអនុវត្តន៍៣ឆ្នាំដំណាក់កាលទី១(ផអ៣ទី១) ដែលមានរយៈពេល០៣ឆ្នាំ+០១ឆ្នាំ(២០១១-២០១៤) និងផែនការអនុវត្តន៍រយៈពេល៣ឆ្នាំដំណាក់កាលទី២ (ផអ៣ទី២) (២០១៥-២០១៧) បានបញ្ចប់។ បច្ចុប្បន្ន រាជរដ្ឋាភិបាលកម្ពុជាកំពុងអនុវត្តផែនការអនុវត្តន៍រយៈពេល៣ឆ្នាំ(២០១៨-២០២០) ដោយផ្តោតការយកទុកដាក់លើការពង្រឹងសមត្ថភាព និងលទ្ធភាពរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ។

ខាងក្រោមនេះ គឺជាខ្សែពេលវេលានៃដំណើរការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា។




NASLA

### ១.៣.១. យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤

ក្នុងការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី៣ ទី៤ ទី៥ និងទី៦ នៃរដ្ឋសភា រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ ទី២ ទី៣ និងទី៤ ដោយផ្តោតការយកចិត្តទុកដាក់លើកំណែទម្រង់បួន រួមមាន៖

- កំណែទម្រង់រដ្ឋបាលសាធារណៈ
- កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- កំណែទម្រង់កងកម្លាំងប្រដាប់អាវុធ
- ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

កំណែទម្រង់ទាំងបួននេះ ត្រូវបានពង្រឹងពង្រីក និងយកចិត្តទុកដាក់អនុវត្តកាន់តែស៊ីជម្រៅពីដំណាក់កាលមួយ ទៅដំណាក់កាលមួយ។ ជាពិសេស ពាក់ព័ន្ធកំណែទម្រង់រដ្ឋបាលសាធារណៈ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ជាកំណែទម្រង់ដ៏មានសារៈសំខាន់បំផុត ក្នុងការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការបម្រើសេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានប្រកបដោយគុណភាព មានការចូលរួម គណនេយ្យភាព សមធម៌ និងបរិយាប័ន្ន។

### ១.៣.២. ក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ

នៅក្នុងឆ្នាំ២០០៥ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំឱ្យមានក្របខ័ណ្ឌយុទ្ធសាស្ត្រស្តីពីកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្នុងគោលបំណងកំណត់អំពី៖

- ចក្ខុវិស័យរបស់រាជរដ្ឋាភិបាលកម្ពុជា ពាក់ព័ន្ធនឹងកំណែទម្រង់អភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ
- គោលដៅយុទ្ធសាស្ត្រកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- វិសាលភាពនៃការអនុវត្តកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ
- របៀបរៀបចំរចនាសម្ព័ន្ធគ្រប់គ្រងនៅតាមរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ
- ការណែនាំដល់ការងារកំណែទម្រង់ទាំងអស់ ដែលមានផលប៉ះពាល់ដល់ប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ រៀបចំឡើងដោយឈរលើមូលដ្ឋាននៃមេរៀន និងបទពិសោធន៍ដែលទទួលបានពីការអនុវត្តកំណែទម្រង់នៅថ្នាក់ឃុំ សង្កាត់តាមរយៈការដាក់ឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងច្បាប់ស្តីពីការជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងឆ្នាំ២០០១។ ផ្អែកតាមក្របខ័ណ្ឌយុទ្ធសាស្ត្រនេះ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានរៀបចំ និងដាក់ឱ្យប្រើនៅក្នុងឆ្នាំ២០០៨។

NASLA

ក្នុងការដាក់ឱ្យដំណើរការនូវរចនាសម្ព័ន្ធ និងប្រព័ន្ធគ្រប់គ្រងថ្មីនៅរដ្ឋបាលថ្នាក់ក្រោមជាតិផ្អែកតាមស្មារតីនៃច្បាប់រៀបចំអង្គការខាងលើ រាជរដ្ឋាភិបាលកម្ពុជា និងក្រសួង ស្ថាប័នពាក់ព័ន្ធបានដាក់ចេញនូវព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងលិខិតបទដ្ឋានពាក់ព័ន្ធដទៃទៀតជាច្រើន ដើម្បីធានាឱ្យប្រព័ន្ធអភិបាលកិច្ចមូលដ្ឋានអាចដំណើរការទៅបានប្រកបដោយភាពរលូន មានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

### ១.៣.៣. ច្បាប់រៀបចំអង្គការ

ច្បាប់រៀបចំអង្គការសំដៅលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ច្បាប់គ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។ ច្បាប់ទាំងនេះមានគោលបំណងកំណត់អំពីការរៀបចំប្រព័ន្ធគ្រប់គ្រងនៅរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ រួមទាំងការបោះឆ្នោតជ្រើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់។

## ១.៤. ប្រព័ន្ធអភិបាលកិច្ចនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

### ១.៤.១. គោលការណ៍

យោងមាត្រា២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវគ្រប់គ្រងតាមគោលការណ៍នៃរដ្ឋបាលឯកភាព ដើម្បីបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ។

*រដ្ឋបាលឯកភាព* គឺជាការរៀបចំឲ្យមានក្រុមប្រឹក្សានៅរដ្ឋបាលថ្នាក់ក្រោមជាតិ ដែលអាចម្ចាស់ការក្នុងការគ្រប់គ្រង ចាត់ចែងមុខងារ និងធនធាន ហើយក្រុមប្រឹក្សានីមួយៗមានសមត្ថភាពសម្របសម្រួលប្រកបដោយប្រសិទ្ធភាពនូវសកម្មភាពនៃការផ្តល់សេវាកម្ម និងការអភិវឌ្ឍដែលធ្វើឡើងដោយក្រសួង ស្ថាប័ននៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា សំដៅឆ្លើយតបសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

***ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ*** រួមមានសមាសភាពដូចខាងក្រោម៖

- ភាពជាតំណាងសាធារណៈ
- ស្វ័យភាពរបស់មូលដ្ឋាន
- ការពិគ្រោះយោបល់ និងការចូលរួម
- ការឆ្លើយតប និងគណនេយ្យភាព
- ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជននៅមូលដ្ឋាន
- ការលើកស្ទួយសមធម៌
- តម្លាភាព និងសុចរិតភាព
- វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច។

NASLA

គោលការណ៍ទាំង៨ខាងលើ គឺជាការកំណត់អំពីមូលដ្ឋានគ្រឹះដែលត្រូវដាក់បញ្ចូលទៅក្នុងកិច្ចដំណើរការនៃប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ តាមរយៈការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ បែបបទ នីតិវិធីបំពេញការងាររបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក៏ដូចជាការរៀបចំច្បាប់ និងលិខិតបទដ្ឋាននានា។ ខ្លឹមសារសំខាន់ៗនៃគោលការណ៍ទាំង៨ មានដូចខាងក្រោម៖

**ទី១៖ ភាពជាតំណាងសាធារណៈ**

ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាគ្រប់ថ្នាក់នៅថ្នាក់ក្រោមជាតិ តាមគោលការណ៍នៃការបោះឆ្នោតតាមបែបប្រជាធិបតេយ្យ សេរីពហុបក្ស គឺជាការផ្តល់ភាពជាតំណាងសាធារណៈ ដល់ក្រុមប្រឹក្សាជាប់ឆ្នោតគ្រប់លំដាប់ថ្នាក់នៃរដ្ឋបាលថ្នាក់ក្រោមជាតិ។ ក្រុមប្រឹក្សានីមួយៗត្រូវធ្វើសកម្មភាពនានា ក្នុងនាមផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួន ដោយមិនមានការរើសអើងខាងនយោបាយ ពណ៌សម្បុរ ជំនឿ សាសនា ជនជាតិ និងទ្រព្យធននោះឡើយ។

**ទី២៖ ស្វ័យភាពរបស់មូលដ្ឋាន**

ស្វ័យភាពមូលដ្ឋាន មានន័យថា រដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិធ្វើសេចក្តីសម្រេច និងអនុវត្តសេចក្តីសម្រេចរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ក្នុងមូលដ្ឋានរបស់ខ្លួនក្នុងដែនសមត្ថកិច្ចដែលច្បាប់បានកំណត់។

**ទី៣៖ ការពិគ្រោះយោបល់ និងការចូលរួម**

ការពិគ្រោះយោបល់ និងការចូលរួម គឺជាកិច្ចដំណើរការដ៏សំខាន់សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិស្វែងយល់អំពីបំណងប្រាថ្នា និងសេចក្តីត្រូវការរបស់សហគមន៍ផ្សេងៗគ្នាក្នុងមូលដ្ឋានរបស់ខ្លួន ដើម្បីរដ្ឋបាលថ្នាក់ក្រោមជាតិដាក់បញ្ចូលនូវផលប្រយោជន៍ និងសេចក្តីត្រូវការដែលមានលក្ខណៈផ្សេងៗគ្នាក្នុងមូលដ្ឋានខ្លួន (ឧទាហរណ៍ តម្រូវការរបស់ស្ត្រី កុមារ យុវជន មនុស្សចាស់ជរា ជនជាតិ ជនក្រីក្រ ... ជាដើម) សំដៅធ្វើសេចក្តីសម្រេចឆ្លើយតបបានកាន់តែប្រសើរទៅនឹងផលប្រយោជន៍ និងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់នៅក្នុងមូលដ្ឋានរបស់ខ្លួន។

**ទី៤៖ ការឆ្លើយតប និងគណនេយ្យភាព**

ក្នុងនាមជាតំណាងប្រជាពលរដ្ឋ ក្រុមប្រឹក្សាត្រូវឆ្លើយតបចំពោះប្រជាពលរដ្ឋរបស់ខ្លួនក្នុងការធ្វើគោលនយោបាយ សេចក្តីសម្រេចចិត្ត សកម្មភាព និងការបំពេញការងាររបស់ខ្លួនប្រកបដោយការទទួលខុសត្រូវនូវអ្វីដែលខ្លួនបានអនុវត្ត។ ក្រុមប្រឹក្សាក៏ទទួលខុសត្រូវផងដែរ ចំពោះរាជរដ្ឋាភិបាលក្នុងការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងច្បាប់នានា។

**ទី៥៖ ការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន**

គឺជាកិច្ចខិតខំប្រឹងប្រែង ដើម្បីបង្កើត និងធ្វើឲ្យមាននិរន្តរភាពនូវបរិយាកាសមួយប្រកបដោយសន្តិភាព សុវត្ថិភាព និងសុខុមាលភាព លើកកម្ពស់ការអភិវឌ្ឍសង្គមនិងសេដ្ឋកិច្ច និងលើកកម្ពស់ផាសុកភាព និងគុណភាពជីវិតនៃប្រជាពលរដ្ឋក្នុងមូលដ្ឋាន។ តម្រូវការរបស់ប្រជាពលរដ្ឋមានលក្ខណៈផ្សេងៗគ្នាទៅ

NASLA

តាមសហគមន៍ និងក្រុមប្រជាពលរដ្ឋដែលមានដូចជាយុវជន ស្ត្រី កុមារ ជនពិការ ចាស់ជរា ជនជាតិដើមភាគតិច ក្រុមជនក្រីក្រ ជាដើម ហេតុនេះក្រុមប្រឹក្សាត្រូវខិតខំស្វែងយល់ឲ្យបានគ្រប់ជ្រុងជ្រោយ ពីតម្រូវការផ្សេងៗគ្នារបស់អ្នកទាំងនោះ តាមរយៈការលើកកម្ពស់ការពិគ្រោះយោបល់ និងការចូលរួម។ ទន្ទឹមនេះ ក្រុមប្រឹក្សាត្រូវខិតខំប្រើប្រាស់ធនធានដ៏មានកម្រិតរបស់ខ្លួនឲ្យមានប្រសិទ្ធភាព ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនោះ។

### ទី៦៖ ការលើកស្ទួយសមធម៌

ជាគោលការណ៍ ទន្ទឹមនឹងការលើកកម្ពស់ការឆ្លើយតប គណនេយ្យភាព និងការលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗត្រូវលើកស្ទួយសមធម៌សង្គមក្នុងមូលដ្ឋានរបស់ខ្លួនផងដែរ។ ការលើកស្ទួយសមធម៌សង្គម គឺជាកិច្ចដំណើរការដែលតម្រូវឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិប្រឹងប្រែងធានាឲ្យមានការពិគ្រោះយោបល់ ការចូលរួមកាន់តែស៊ីជម្រៅជាមួយស្ត្រី កុមារ ក្រុមជនងាយរងគ្រោះ សហគមន៍ក្រីក្រ ជនជាតិភាគតិច។ល។ សំដៅធ្វើការផ្តល់សេវា និងការអភិវឌ្ឍឲ្យបានសមស្របបំផុតចំពោះក្រុមជនទាំងនោះ។ ក្នុងន័យនេះ ការផ្តល់សេវា និងការអភិវឌ្ឍត្រូវតែផ្តោតការយកចិត្តទុកដាក់ជាចម្បងដល់ក្រុមជនខាងលើនេះ ដើម្បីឲ្យក្រុមជនទាំងនេះទទួលបាននូវឱកាសកាន់តែច្រើន អត្ថប្រយោជន៍កាន់តែច្រើន ពីការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។

### ទី៧៖ តម្លាភាព និងសុចរិតភាព

តម្លាភាព និងសុចរិតភាព គឺជាគោលការណ៍ស្នូលនៃអភិបាលកិច្ចល្អ។ កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ត្រូវធានារៀបចំស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ ជាស្ថាប័នប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ជាក្រឹត្យក្រម តម្លាភាព និងសុចរិតភាពមិនអាចកើតឡើងដោយឯកឯងបានឡើយ។ តម្លាភាព និងសុចរិតភាពទាមទារត្រូវរៀបចំឲ្យមានរចនាសម្ព័ន្ធ ប្រព័ន្ធ និងនីតិវិធីច្បាស់លាស់សម្រាប់ស្ថាប័ននីមួយៗ ហើយថ្នាក់ដឹកនាំនៃស្ថាប័ននោះ ត្រូវមានការប្តេជ្ញាចិត្តក្នុងការកសាងស្ថាប័នរបស់ខ្លួនប្រកបដោយតម្លាភាព និងមានសុចរិតភាព។ ក្នុងន័យនេះ ក្រុមប្រឹក្សា គណៈអភិបាលត្រូវមានការប្តេជ្ញាចិត្តកសាងរដ្ឋបាលរបស់ខ្លួនឲ្យក្លាយជារដ្ឋបាលដែលមានលក្ខណៈបើកចំហ មានតម្លាភាព ដោយត្រូវធានាឲ្យបានថា សមាជិកក្រុមប្រឹក្សាគ្រប់ៗរូប អភិបាល អភិបាលរង មន្ត្រី បុគ្គលិកទាំងអស់ត្រូវបំពេញការងារប្រកបដោយតម្លាភាព និងត្រូវប្រកាន់យកគោលការណ៍សុចរិតភាពក្នុងការបំពេញការងារ ការផ្តល់សេវា និងការអភិវឌ្ឍក្នុងមូលដ្ឋានរបស់ខ្លួន។ កិច្ចប្រជុំជាសាធារណៈរបស់ក្រុមប្រឹក្សា ការប្រជុំគណៈអភិបាល ការកសាងរបៀបធ្វើការជាក្រុមក្នុងក្រុមប្រឹក្សា គណៈអភិបាល និងមន្ត្រីនៃរដ្ឋបាលរបស់ខ្លួន ការរៀបចំ និងដាក់ឲ្យអនុវត្តប្រព័ន្ធត្រួតពិនិត្យការងារផ្ទៃក្នុងសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិនីមួយៗ ការរៀបចំ និងដាក់ឲ្យអនុវត្តនូវប្រព័ន្ធសវនកម្មផ្ទៃក្នុង ផ្ទៃក្រៅ និងប្រព័ន្ធ នីតិវិធីនានាជាច្រើនដែលបានដាក់ឲ្យប្រើប្រាស់កន្លងមកនេះ គឺមានគោលបំណងគាំទ្រដល់ការលើកកម្ពស់តម្លាភាព និងសុចរិតភាពរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

NASLA

**ទី៨៖ វិធានការប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច**

ការប្រយុទ្ធប្រឆាំងអំពើពុករលួយ និងការរំលោភអំណាច គឺជាកាតព្វកិច្ចរបស់ស្ថាប័នសាធារណៈគ្រប់ថ្នាក់ ផ្នែកឯកជន សង្គមស៊ីវិល និងប្រជាពលរដ្ឋគ្រប់ៗរូប សំដៅកសាងសង្គមមួយប្រកបដោយភាពស្អាតស្អំ និងយុត្តិធម៌ ដើម្បីជានាឲ្យមានការអភិវឌ្ឍសង្គមប្រកបដោយចីរភាព និងសមធម៌។

## ១.៤.២.ការរៀបចំប្រព័ន្ធអភិបាលកិច្ចនៅថ្នាក់ក្រោមជាតិ

### *ក.ឋានៈផ្លូវច្បាប់*

មាត្រា ៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមាត្រា ២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ បានកំណត់ឱ្យរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺជានីតិបុគ្គលនៃនីតិសាធារណៈ។ នីតិបុគ្គលនីមួយៗ រួមមានដែនដី និងប្រជាពលរដ្ឋនៅក្នុងដែនដីនោះ និងមានក្រុមប្រឹក្សាមួយជាតំណាងដែលកើតឡើងពីការបោះឆ្នោតជ្រើសរើស ស្របតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក និងក្រុមប្រឹក្សាខណ្ឌ និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

ការផ្តល់ភាពជានីតិបុគ្គល ចំពោះរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ គឺក្នុងគោលបំណងផ្តល់សិទ្ធិអំណាច មុខងារ ធនធាន និងទ្រព្យសម្បត្តិឱ្យដល់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាអាចគ្រប់គ្រង ចាត់ចែងកិច្ចការនានានៅមូលដ្ឋាន សំដៅឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលជាម្ចាស់ឆ្នោត និងអភិវឌ្ឍមូលដ្ឋានប្រកបដោយចីរភាព ប្រសិទ្ធភាព សមធម៌ និងបរិយាប័ន្ន។

### *ខ. ក្រុមប្រឹក្សា*

ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិរួមមាន ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ក្រុមប្រឹក្សាឃុំ សង្កាត់។ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតជាសកល និងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ត្រូវបានជ្រើសរើសឡើងតាមរយៈការបោះឆ្នោតជាអសកល។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិមានអាណត្តិ៥ឆ្នាំ និងត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។

ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចខាងបញ្ញត្តិតាមរយៈការចេញដីកា និងសិទ្ធិអំណាចខាងប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចចិត្តនៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សា។

### *គ.បុគ្គលិក*

ក្រុមប្រឹក្សានីមួយៗមានបុគ្គលិករបស់ខ្លួន ដែលរួមមានបីប្រភេទដូចខាងក្រោម៖

- បុគ្គលិកដែលបានតែងតាំងដោយក្រុមប្រឹក្សា
- បុគ្គលិកដែលបានតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា



NASLA

- បុគ្គលិកដែលបានរៀបចំឡើងវិញឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា។

ក្រុមប្រឹក្សាត្រូវសម្រេចអំពីការតែងតាំង ការបណ្តេញចោល ការកម្រិតប្រាក់បៀវត្ស និងអត្ថប្រយោជន៍ផ្សេងៗទៀត សម្រាប់មុខតំណែងបុគ្គលិករបស់ខ្លួន ស្របតាម *ព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ*។

បុគ្គលិករបស់ក្រុមប្រឹក្សាត្រូវស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យដោយផ្ទាល់ របស់គណៈ-អភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន

## *ឃ. មុខងារ*

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់មុខងាររបស់ក្រុមប្រឹក្សានៃមានមុខងារពីរប្រភេទគឺមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។

***មុខងារជាកាតព្វកិច្ច*** គឺជាមុខងារដែលកំណត់ដោយច្បាប់ ឬព្រះរាជក្រឹត្យ ឬអនុក្រឹត្យ ឬ ប្រកាសតាមសំណើរបស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ក្រសួងស្ថាប័នរបស់ រាជរដ្ឋាភិបាល។

***មុខងារជាជម្រើស*** គឺជាមុខងារដែលមិនមានលក្ខណៈជាកាតព្វកិច្ច។ មុខងារជាជម្រើសមានពីរប្រភេទគឺមុខងារជាជម្រើសដែលក្រសួង ស្ថាប័ន ផ្ទេរទៅឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ និងមុខងារជាជម្រើសដែលមានលក្ខណៈជាអាណត្តិទូទៅ។ មុខងារជាជម្រើសដែលមានលក្ខណៈជាអាណត្តិទូទៅត្រូវបានប្រគល់ទៅឱ្យក្រុមប្រឹក្សាគ្រប់លំដាប់ថ្នាក់មុនការធ្វើប្រតិភូកម្ម ឬការប្រគល់មុខងារជាក់លាក់ណាមួយ ដើម្បីជាមូលដ្ឋានក្នុងការលើកកម្ពស់សមត្ថភាពដល់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការអនុវត្តមុខងារផ្សេងៗគ្នាជាច្រើនដែលបានជ្រើសរើសយកជាអាទិភាពតាមមូលដ្ឋាននីមួយៗ។ បច្ចុប្បន្ន រដ្ឋបាលថ្នាក់ក្រោមជាតិកំពុងបំពេញការងារប្រចាំថ្ងៃ ដោយផ្អែកលើអាណត្តិទូទៅទាំងនេះ។

## *ង.ហិរញ្ញវត្ថុ*

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិមានធនធានហិរញ្ញវត្ថុសមស្រប ដើម្បីបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងត្រូវគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួន ក្នុងលក្ខណៈប្រកបដោយប្រសិទ្ធភាព មានតម្លាភាព និងមានគណនេយ្យភាព។ មាត្រា ២៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់អំពីប្រភេទចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដូចខាងក្រោម៖

- ប្រភពនៅមូលដ្ឋាន
- ប្រភពពីថ្នាក់ជាតិ និង
- ប្រភពផ្សេងៗទៀត

ចំណូលពីប្រភពនៅមូលដ្ឋាន រួមមាន៖

- ពន្ធនៅមូលដ្ឋាន
- ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងទៀត
- ចំណូលរបស់ក្រុមប្រឹក្សា បានមកពីពន្ធ ឈ្នួល និងកម្រៃដែលត្រូវចែករំលែករវាងក្រុមប្រឹក្សាជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក
- អំណោយស្ម័គ្រចិត្ត
- ប្រភពផ្សេងទៀតដែលកំណត់ដោយច្បាប់ ឬអនុក្រឹត្យ។

ចំណូលពីថ្នាក់ជាតិ រួមមាន៖

- ចំណូលចែករំលែក
- មូលនិធិផ្ទេរពីថវិការដ្ឋ និង
- ថ្លៃសេវាបានមកពីមុខងារជាភ្នាក់ងារ ដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង ស្ថាប័ន។

## *ច. ទ្រព្យសម្បត្តិ*

ទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិរួមមាន ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរទៅឱ្យ និងទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង។

ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ រដ្ឋបាលថ្នាក់ក្រោមជាតិអាចគ្រប់គ្រង ប្រើប្រាស់ និងអាចទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះ ហើយរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវថែរក្សា ការពារឱ្យបានគង់វង្ស និងគ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ ដោយគ្មានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃឡើយ។

ទ្រព្យសម្បត្តិដែលរដ្ឋបាលថ្នាក់ក្រោមជាតិរកបានដោយខ្លួនឯង ជាកម្មសិទ្ធិ ដែលរដ្ឋបាលថ្នាក់ក្រោមជាតិមានសិទ្ធិស្វ័យសម្រេចក្នុងការគ្រប់គ្រង និងការប្រើប្រាស់ ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិទាំងនោះក្រោមក្របខ័ណ្ឌដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត។

រដ្ឋបាលថ្នាក់ក្រោមជាតិត្រូវធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិទាំងអស់របស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ ហើយត្រូវបញ្ជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីបញ្ចូលទៅក្នុងបញ្ជីសារពើភណ្ឌរួមនៃទ្រព្យសម្បត្តិរដ្ឋស្របតាមនីតិវិធីកំណត់ជាធរមាន៕

# ជំពូកទី២

# រចនាសម្ព័ន្ធ តួនាទី ភារកិច្ច

NASLA

# ជំពូកទី២
# រចនាសម្ព័ន្ធ តួនាទី ភារកិច្ច

## ២.១. រចនាសម្ព័ន្ធ

អនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក បានកំណត់រចនាសម្ព័ន្ធនៃរដ្ឋបាលស្រុកទូទៅ និងរដ្ឋបាលស្រុកក្នុងខេត្តបាត់ដំបងដូចខាងក្រោម៖




**<u>រចនាសម្ព័ន្ធរដ្ឋបាលស្រុក</u>**




**<u>រចនាសម្ព័ន្ធរដ្ឋបាលស្រុកនៃខេត្តបាត់ដំបង</u>**

## ២.២. ក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោតអសកល ដែលមានអាណត្តិ៥ឆ្នាំហើយត្រូវផុតកំណត់នៅពេលដែលក្រុមប្រឹក្សាថ្មីចូលកាន់តំណែង។ ក្នុងពេលរង់ចាំក្រុមប្រឹក្សាថ្មីចូលកាន់មុខតំណែង ក្រុមប្រឹក្សាដែលចប់អាណត្តិមានសិទ្ធិអនុវត្តតែកិច្ចការរដ្ឋបាលប្រចាំថ្ងៃតែប៉ុណ្ណោះ។

សមាជិកក្រុមប្រឹក្សាមានចំនួនចាប់ពី១១រូប រហូតដល់២១រូប។ ក្រុមប្រឹក្សាមានប្រធាន០១រូបដែលជាបេក្ខជនឈរឈ្មោះលេខរៀងទី១ លើបញ្ជីបេក្ខជននៃគណបក្សនយោបាយដែលទទួលបានសម្លេងគាំទ្រច្រើនជាងគេ។

ក្រុមប្រឹក្សា គឺជាតំណាងសាធារណៈ ជាអ្នកការពារ និងជាអ្នកបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋទាំងអស់ក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

### ២.២.១. សិទ្ធិអំណាច

ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ ក្រុមប្រឹក្សាប្រើប្រាស់អំណាចបញ្ញត្តិរបស់ខ្លួនតាមរយៈការធ្វើដីកា និងប្រើប្រាស់អំណាចប្រតិបត្តិតាមរយៈការធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា ស្របតាមក្របខ័ណ្ឌដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

ទន្ទឹមនេះ ក្រុមប្រឹក្សាអាចស្នើជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដើម្បីដកហូតអភិបាល អភិបាលរងចេញពីមុខតំណែង ក្នុងករណីអភិបាល អភិបាលរងនោះមានករណីណាមួយដូចខាងក្រោម៖

- បាត់បង់លក្ខណសម្បត្តិជាអភិបាល ឬ អភិបាលរង
- អសមត្ថភាព
- បំពេញការងារមិនបានល្អ
- មានបញ្ហាសុខភាព ឬបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមានលិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច
- បោះបង់ចោលការងារ
- ប្រព្រឹត្តខុសឆ្គងពីក្រមសីលធម៌វិជ្ជាជីវៈ។

### ២.២.២. តួនាទី ភារកិច្ច

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានា ដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ព្រមទាំងដើម្បីបំពេញមុខងារ ដែលបានប្រគល់ និងឬ ដែលបានធ្វើប្រតិភូកម្ម ដោយមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

### ក.ការងាររៀបចំកិច្ចប្រជុំក្រុមប្រឹក្សា

ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងតិចចំនួន១២ដងក្នុងមួយឆ្នាំ ទៅតាមប្រតិទិនដែលបានអនុម័តដោយក្រុមប្រឹក្សា។ ក្រៅពីកិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់។

### ខ.ការងាររៀបចំបទបញ្ជាផ្ទៃក្នុង

ក្រោយប្រកាសចូលកាន់តំណែងក្រុមប្រឹក្សាត្រូវរៀបចំបទបញ្ជាផ្ទៃក្នុង ដើម្បីកំណត់វិធានទាំងឡាយសម្រាប់កិច្ចប្រជុំ និងរបៀបរបបធ្វើការងាររបស់ខ្លួន។ បទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា ត្រូវធ្វើឡើងតាមទម្រង់ជាដីកា និងត្រូវអនុម័តក្នុងកិច្ចប្រជុំសាមញ្ញលើកទី២ ដែលប្រព្រឹត្តទៅមិនឱ្យមុន២៥ថ្ងៃ ឬលើសពី៣៥ថ្ងៃ បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកទី១។

### គ.ការងាររៀបចំវិធានគ្រប់គ្រងផ្ទៃក្នុង

ក្រុមប្រឹក្សានៃអាណត្តិនីមួយៗ ត្រូវរៀបចំ និងអនុម័តដីកាស្តីពីវិធានគ្រប់គ្រងផ្ទៃក្នុង ដើម្បីជានាន្ទវការលើកកម្ពស់ការគ្រប់គ្រងរដ្ឋបាលរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពស្របតាមគោលការណ៍នៃការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ។

### ឃ.ការងារដាក់ចេញដីកា និងសេចក្តីសម្រេច

ក្រុមប្រឹក្សាអាចដាក់ចេញដីកា ដើម្បីកំណត់ ហាមឃាត់ ឬត្រួតពិនិត្យលើសកម្មភាព នីតិវិធី ឬកិច្ចការណាមួយដែលស្ថិតនៅក្នុងវិសាលភាពនៃមុខងារ និងធនធានរបស់ខ្លួន ដោយផ្អែកតាមតម្រូវការនៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាធរមាន និងឬតម្រូវការក្នុងមូលដ្ឋាន។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏អាចដាក់ចេញសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាមានពីរប្រភេទ គឺសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរ និង/ឬដោយផ្ទាល់មាត់ក្នុងអង្គប្រជុំក្រុមប្រឹក្សាដោយត្រូវកត់ត្រានៅក្នុងកំណត់ហេតុនៃកិច្ចប្រជុំក្រុមប្រឹក្សា។

### ង.ការងាររៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់

ក្រុមប្រឹក្សាត្រូវរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ខ្លួន ក្នុងអំឡុងខែមិថុនានៃឆ្នាំនីមួយៗ ដោយត្រូវធ្វើឡើងនៅតាមឃុំ និងសង្កាត់នានាក្នុងស្រុក ក្នុងគោលបំណងផ្តល់ឱកាសឱ្យក្រុមប្រឹក្សាដើម្បី៖

- **ផ្តល់នូវព័ត៌មាន៖** ក្រុមប្រឹក្សារាយការណ៍អំពីសកម្មភាពរបស់ខ្លួននៅក្នុងឆ្នាំកន្លងមក និងបង្ហាញពីផែនការសម្រាប់ឆ្នាំខាងមុខ
- **ផ្តល់ប្រឹក្សា៖** អ្នកចូលរួមពិភាក្សាអំពីលទ្ធផល ផ្តល់ព័ត៌មានត្រឡប់ដល់ក្រុមប្រឹក្សាអំពីការងារនៅក្នុងឆ្នាំកន្លងមក និងលើកជាសំណើសម្រាប់ឆ្នាំបន្ទាប់
- **ជំរុញឱ្យមានការចូលរួម៖** អ្នកចូលរួមអាចរួមចំណែកនៅក្នុងដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ដែលក្នុងនោះសំណើ និងការព្រួយបារម្ភរបស់ប្រជាពលរដ្ឋត្រូវបានលើកយកមកពិចារណានៅក្នុងការសម្រេចចុងក្រោយរបស់ក្រុមប្រឹក្សា

- **លើកកម្ពស់ការសហការ៖** ក្រុមប្រឹក្សាទទួលបានព័ត៌មានប្រសើរជាងមុនអំពីតម្រូវការរបស់ប្រជាពលរដ្ឋ ហើយប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីការអភិវឌ្ឍនៅមូលដ្ឋាន។ វេទិការបស់ក្រុមប្រឹក្សាជំរុញ និងលើកកម្ពស់កិច្ចសហការគ្នារវាង ក្រុមប្រឹក្សា និងប្រជាពលរដ្ឋ។ វេទិកានេះ ចូលរួមចំណែកក្នុងការបង្កើតនូវដំណោះស្រាយ ដែលផ្តល់ផលប្រយោជន៍ដល់ប្រជាពលរដ្ឋ។

## *ច.ការងារផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល*

ក្រោយប្រកាសចូលកាន់តំណែង ក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥)ឆ្នាំ យ៉ាងយូរត្រឹមឆ្នាំទី២ នៃអាណត្តិរបស់ក្រុមប្រឹក្សា។ ផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(៥)ឆ្នាំត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមរយៈការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ។ ក្នុងការរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ប្រភេទក្រុមប្រឹក្សាផ្សេង និងអ្នកពាក់ព័ន្ធនានាដោយត្រូវគោរពតាមគោលការណ៍ដូចខាងក្រោម ៖

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាព និងសុខដុមនីយកម្ម
- ការចូលរួមពិគ្រោះយោបល់ជាទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាព និងសុក្រឹតភាពសេដ្ឋកិច្ច និងសង្គម
- ការធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌។

## *ឆ.ការអនុវត្តមុខងារ*

ក្រុមប្រឹក្សាត្រូវចាត់វិធានការចាំបាច់នានាដើម្បីធានាថា រាល់មុខងារដែលផ្ទេរទៅឱ្យក្រុមប្រឹក្សារួមទាំងមុខងារជាអាណត្តិទូទៅដែលក្រុមប្រឹក្សាបានសម្រេចជ្រើសរើសយកមកអនុវត្ត ត្រូវបានយកទៅអនុវត្តយ៉ាងពេញលេញប្រកបដោយប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងបរិយាប័ន្ន។ ទន្ទឹមនេះ ក្រុមប្រឹក្សាក៏ត្រូវធ្វើការតាមដានត្រួតពិនិត្យ និងផ្តល់យោបល់ការអនុវត្តមុខងារទាំងនោះ តាមរយៈការពិនិត្យ ពិភាក្សានៅក្នុងកិច្ចប្រជុំរបស់ក្រុមប្រឹក្សា ដោយមានគណៈអភិបាលជាអ្នកធ្វើសេចក្តីរាយការណ៍ពីវឌ្ឍនភាព និងបញ្ហាប្រឈមនានាក្នុងការអនុវត្តមុខងារទាំងនោះ។

NASLA

## ជ.ការងារគ្រប់គ្រងបុគ្គលិក

ក្នុងការគ្រប់គ្រងបុគ្គលិករបស់ខ្លួននៅរដ្ឋបាលស្រុក ក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័តលើការងារសំខាន់ៗមួយចំនួន ដូចខាងក្រោម៖

- ការរៀបចំផែនការបុគ្គលិក
- ការតែងតាំង និងការបញ្ចប់មុខតំណែងនាយករងរដ្ឋបាល និងប្រធានការិយាល័យ ឬប្រធានអង្គភាពដែលមានថ្នាក់ប្រហាក់ប្រហែល និង
- ការកំណត់ប្រាក់ឧបត្ថម្ភរបស់បុគ្គលិក។

## ឈ.ការងារគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ

ក្រុមប្រឹក្សាត្រូវគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋ និងចំពោះរាជរដ្ឋាភិបាល ដោយក្នុងនោះការងារសំខាន់ៗរួមមាន៖

- ការពិនិត្យ និងអនុម័តក្របខ័ណ្ឌចំណាយរយៈមធ្យម
- ការពិនិត្យ និងអនុម័តគម្រោងថវិកាប្រចាំឆ្នាំ
- តាមដានត្រួតពិនិត្យការអនុវត្តថវិកាដោយគណៈអភិបាល
- ការពិនិត្យ និង អនុម័តរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ
- ការពិនិត្យ និង អនុម័តការជម្រះបញ្ជីទ្រព្យសម្បត្តិជាដើម។

ព័ត៌មានបន្ថែម សូមមើលសៀវភៅស្តីពីការគ្រប់គ្រងរដ្ឋបាលតាមបែបវិមជ្ឈការ (សម្រាប់ក្រុមប្រឹក្សាស្រុក) ដែលរៀបចំឡើងក្នុងឆ្នាំ២០១៩ ដោយសាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ។

NASLA

## ២.៣. គណៈកម្មាធិការ និងការិយាល័យប្រជាពលរដ្ឋ

ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ បានកំណត់ឱ្យក្រុមប្រឹក្សាមានគណៈកម្មាធិការកាតព្វកិច្ចចំនួនបីគឺ៖

- គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស
- គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- គណៈកម្មាធិការលទ្ធកម្ម

ក្រៅពីគណៈកម្មាធិការជាកាតព្វកិច្ចទាំងបីខាងលើ ក្រុមប្រឹក្សាអាចបង្កើតគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារបន្ថែមផ្សេងទៀតតាមការចាំបាច់ ប៉ុន្តែមិនត្រូវមានតួនាទី និងភារកិច្ចត្រួតគ្នាជាមួយតួនាទី ភារកិច្ចរបស់គណៈកម្មាធិការទាំងបី ឬតួនាទី ភារកិច្ចរបស់គណៈអភិបាលឡើយ។

### ២.៣.១. គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស(គ.ស.ប)ក្រុមប្រឹក្សាស្រុក ដឹកនាំដោយអភិបាល និងមានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលលើកិច្ចការសំខាន់ៗ ដូចខាងក្រោម ៖

- ការរៀបចំផែនការអភិវឌ្ឍន៍ និងថវិកា
- ការសម្របសម្រួលកិច្ចការរបស់ក្រុមប្រឹក្សាជាមួយការិយាល័យ អង្គភាពរបស់ក្រសួង ស្ថាប័ន
- ការធ្វើកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលនៅក្នុងរដ្ឋបាលឯកភាពស្រុក
- ការធ្វើកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងស្រុក
- ការធ្វើកិច្ចសហប្រតិបត្តិការ និងការសម្របសម្រួលរវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាពាក់ព័ន្ធផ្សេងទៀត
- ការងារគ្រប់គ្រង និងចាត់ចែងមុខងារ និងធនធាន។

ចំពោះការបង្កើត និងរបៀបរបការងាររបស់គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សូមមើល *អនុក្រឹត្យលេខ២១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក។*

### ២.៣.២. គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក) នៃរដ្ឋបាលស្រុកដឹកនាំដោយសមាជិកក្រុមប្រឹក្សា០១រូបជាស្ត្រី ឬអភិបាលរង០១រូបជាស្ត្រី និងមានតួនាទី ភារកិច្ចផ្តល់យោបល់ដល់ក្រុមប្រឹក្សា និងគណៈអភិបាលពាក់ព័ន្ធការងារយេនឌ័រ ស្ត្រី យុវវ័យ និងកុមារ។

ចំពោះការបង្កើត របៀបរបបការងារ និងភារកិច្ចជាក់លាក់របស់គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ សូមមើល *ប្រកាសលេខ៤២៧៥ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការរៀបចំ*

*និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ នៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។*

### ២.៣.៣. គណៈកម្មាធិការលទ្ធកម្ម

គណៈកម្មាធិការលទ្ធកម្មដឹកនាំដោយអភិបាល និងមានតួនាទី ភារកិច្ច ក្នុងការពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ ការប្រជុំបើកសំណើដេញថ្លៃ និងការប្រជុំវាយតម្លៃប្រគល់កិច្ចសន្យាជាដើម។

ចំពោះការបង្កើត និងរបៀបរបបការងាររបស់គណៈកម្មាធិការលទ្ធកម្ម សូមមើល *ប្រកាសអន្តរក្រសួងលេខ៣២៤ សហវ ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។*

### ២.៣.៤. ការិយាល័យប្រជាពលរដ្ឋ

យោងអនុក្រឹត្យលេខ១៩ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ *ការិយាល័យប្រជាពលរដ្ឋ* គឺជាយន្តការអព្យាក្រឹតមួយដែលត្រូវបង្កើតឡើងនៅរដ្ឋបាលស្រុកនីមួយៗសម្រាប់ទទួល និងសម្រុះសម្រួលដោះស្រាយបណ្តឹងក្រៅប្រព័ន្ធតុលាការពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការគ្រប់គ្រងរដ្ឋបាលនៅថ្នាក់ស្រុក និងឃុំ សង្កាត់។

ការិយាល័យប្រជាពលរដ្ឋដឹកនាំដោយប្រធានមួយ(១)រូបដែលកើតឡើងពីការបោះឆ្នោត និងមានបុគ្គលិកមួយចំនួនជាជំនួយការ។ ប្រធានការិយាល័យប្រជាពលរដ្ឋមានអាណត្តិការងារប្រាំ(៥)ឆ្នាំ។

បែបបទ នីតិវិធី នៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋ សូមមើល *សេចក្តីណែនាំលេខ០៣៧ សណន ស្តីពីនីតិវិធីនៃការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។*

#### *ក.សមត្ថកិច្ច*

ការិយាល័យប្រជាពលរដ្ឋមានសមត្ថកិច្ចសម្រុះសម្រួលដោះស្រាយ ស៊ើបអង្កេត រាយការណ៍ និងផ្តល់អនុសាសន៍ទៅលើបណ្តឹងរដ្ឋបាល ដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនពាក់ព័ន្ធនឹង៖

- សេចក្តីសម្រេចរបស់រដ្ឋបាលស្រុក រដ្ឋបាលឃុំ សង្កាត់ និងការិយាល័យ អង្គភាពជំនាញនៅថ្នាក់ស្រុក ដែលផ្ទុយនឹងគោលការណ៍ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា ឬដែលប៉ះពាល់ដល់ផលប្រយោជន៍របស់បុគ្គល ឬសហគមន៍
- ការបំពេញការងារ និងអាកប្បកិរិយារបស់បុគ្គលិកក្រុមប្រឹក្សាស្រុក រដ្ឋបាលឃុំ សង្កាត់ និងការិយាល័យ អង្គភាពជំនាញនៅថ្នាក់ស្រុក និងភ្នាក់ងារទទួលសមត្ថកិច្ច។ ***ភ្នាក់ងារទទួលសមត្ថកិច្ច*** *សំដៅដល់ផ្នែកឯកជន និងសង្គមស៊ីវិលដែលទទួលបានសិទ្ធិ និងភារកិច្ចពីរដ្ឋហើយដែលស្ថិតនៅក្រោមការគ្រប់គ្រងត្រួតពិនិត្យរបស់រដ្ឋ ឬភ្នាក់ងាររដ្ឋ។*
- ការគ្រប់គ្រង និងការប្រើប្រាស់ហិរញ្ញវត្ថុនិងទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក រដ្ឋបាលឃុំ សង្កាត់ និងការិយាល័យ អង្គភាពជំនាញនៅថ្នាក់ស្រុក

- ការផ្តល់សេវាសាធារណៈរបស់រដ្ឋបាលស្រុក រដ្ឋបាលឃុំ សង្កាត់ និងការិយាល័យ អង្គភាពជំនាញនៅថ្នាក់ស្រុក និងភ្នាក់ងារទទួលសមត្ថកិច្ច។

សមត្ថកិច្ចខាងលើនេះ មិនរាប់បញ្ចូលបណ្តឹងដែលពាក់ព័ន្ធនឹងកងកម្លាំងនគរបាល កងរាជអាវុធហត្ថ កងយោធពលខេមរភូមិន្ទ អង្គភាពគយ ពន្ធដារ កាំកុងត្រូល ធនាគារជាតិ រតនាគារ គ្រឹះស្ថានសាធារណៈ សហគ្រាសសាធារណៈ និងមន្ត្រីរាជការដែលស្ថិតនៅក្រោមបទប្បញ្ញត្តិដោយឡែករបស់រាជរដ្ឋាភិបាលឡើយ។

## *ខ.តួនាទី ភារកិច្ច*

ការិយាល័យប្រជាពលរដ្ឋមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ទទួល និងប្រមូលពាក្យបណ្តឹងនានានៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- សម្រាំង និងវាយតម្លៃពាក្យបណ្តឹងដែលទទួលបាន
- បញ្ជូនពាក្យបណ្តឹងទាំងឡាយណា ដែលមិនស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួនទៅអង្គភាពមានសមត្ថកិច្ចពាក់ព័ន្ធ និងតាមដានការដោះស្រាយដើម្បីជូនព័ត៌មានទៅម្ចាស់បណ្តឹង
- ចាត់វិធានការស៊ើបអង្កេតបណ្តឹងរដ្ឋបាល លើកអនុសាសន៍អំពីវិធានការដោះស្រាយបណ្តឹង និងតាមដានការអនុវត្តវិធានការដោះស្រាយបណ្តឹងដែលស្ថិតក្នុងសមត្ថកិច្ចរបស់ខ្លួន
- ផ្តល់ព័ត៌មានត្រឡប់ដល់ប្រជាពលរដ្ឋអំពីលទ្ធផលនៃការ ដោះស្រាយបណ្តឹង
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយអំពីយន្តការសម្រុះសម្រួល ដោះស្រាយបណ្តឹងរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំយន្តការចាំបាច់នានាពាក់ព័ន្ធទៅនឹងដំណើរការទទួលនិងសម្រុះសម្រួលដោះស្រាយបណ្តឹងរដ្ឋបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន
- រាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការអនុវត្តការងារ និងការដោះស្រាយបណ្តឹង។

បែបបទ នីតិវិធីលម្អិតនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋស្រុក សូមអាន *សៀវភៅណែនាំស្តីពីបែបបទ និងនីតិវិធីនៃការទទួល និងការសម្រុះសម្រួលដោះស្រាយបណ្តឹងរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ដែលដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចលេខ ៧១៨១ សសរ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៩ របស់ក្រសួងមហាផ្ទៃ*។

## *គ.សិទ្ធិអំណាច*

ការិយាល័យប្រជាពលរដ្ឋ មានសិទ្ធិអំណាចដូចខាងក្រោម៖

- ប្រើប្រាស់បុគ្គលិក ថវិកា សម្ភារ និងមធ្យោបាយនានារបស់អង្គភាពខ្លួនសម្រាប់អនុវត្តសកម្មភាព ផ្អែកតាមផែនការសកម្មភាពនិងថវិការបស់ខ្លួន ដែលទទួលបានការអនុម័តពីក្រុមប្រឹក្សា
- ស៊ើបអង្កេតបណ្តឹងដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ខ្លួន តាមការចាំបាច់ ព្រមទាំងលើក



NASLA

ឡើងនូវអនុសាសន៍អំពីវិធានការដោះស្រាយ ប៉ុន្តែពុំមានសិទ្ធិចេញសេចក្តីសម្រេចដើម្បីចាត់វិធានការដោះស្រាយ ឬដាក់ទណ្ឌកម្មឡើយ

- ស្នើសុំកិច្ចសហការ ឬការចូលរួមពីបុគ្គលិកនៃអង្គភាពនានានៃរដ្ឋបាលស្រុក រដ្ឋបាលឃុំ សង្កាត់ និងការិយាល័យ អង្គភាពជំនាញតាមការចាំបាច់
- កោះអញ្ជើញបុគ្គល ឬប្រធានអង្គភាព ដែលពាក់ព័ន្ធនឹងពាក្យបណ្តឹងឱ្យចូលមកបំភ្លឺតាមការចាំបាច់
- ពិនិត្យមើលឯកសារ និងវត្ថុតាងផ្សេងៗដែលពាក់ព័ន្ធនឹងបណ្តឹងនៅតាមអង្គភាពពាក់ព័ន្ធនានា ដោយពុំចាំបាច់ជូនដំណឹងជាមុន និងអាចដកហូតយកឯកសារ និងវត្ថុតាងទាំងនោះមករក្សាទុកជាបណ្តោះអាសន្នតាមការចាំបាច់

ក្រៅពីសិទ្ធិអំណាចខាងលើ ប្រធានការិយាល័យប្រជាពលរដ្ឋអាចជូនដំណឹងដល់អភិបាលស្រុក ឬមេឃុំ ចៅសង្កាត់ អំពីការមិនសហការក្នុងការស៊ើបអង្កេតរបស់ប្រធានអង្គភាព និងឬបុគ្គលដែលពាក់ព័ន្ធនឹងបណ្តឹង និងការមិនចាត់វិធានការដោះស្រាយ ឬការចាត់វិធានការដោះស្រាយមិនសមស្របរបស់ប្រធានអង្គភាពចំពោះពាក្យបណ្តឹងនានា ដែលពាក់ព័ន្ធនឹងអង្គភាពនោះ។ ក្នុងករណីដែលអភិបាលស្រុក ឬមេឃុំ ចៅសង្កាត់មិនបានចាត់វិធានការដោះស្រាយឱ្យបានសមស្រប ប្រធានការិយាល័យប្រជាពលរដ្ឋអាចរាយការណ៍ជូនប្រធានក្រុមប្រឹក្សាស្រុក ឬក្រុមប្រឹក្សាឃុំ សង្កាត់ ដើម្បីដោះស្រាយ និងអាចរាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងមហាផ្ទៃដើម្បីសម្របសម្រួលដោះស្រាយ ប្រសិនបើក្រុមប្រឹក្សាមិនអាចដោះស្រាយបាន។

NASLA

## ២.៤. គណៈអភិបាល

គណៈអភិបាលរួមមាន អភិបាល០១រូប និងអភិបាលរងចំនួន០៤រូប[១]។ អភិបាល និងអភិបាលរង មានអាណត្តិការងារមិនលើសពីបួន(៤)ឆ្នាំ និងអាចត្រូវបានតែងតាំងបានបួន(៤)ឆ្នាំទៀតសម្រាប់អាណត្តិទី២របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល។

អភិបាល ត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិលទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ក្រសួងមហាផ្ទៃ ឬ ក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរសក្តិចាប់ពីអនុមន្ត្រីឡើង
- មានអាយុចាប់ពីសាមសិប (៣០) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង
- មានបទពិសោធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចប្រាំ(៥)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្រ ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។

ដោយឡែក អភិបាលរង ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ដោយត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការស៊ីវិលទាំងពីរភេទដែលស្ថិតក្នុងក្របខ័ណ្ឌមន្ត្រីក្រមការក្រសួងមហាផ្ទៃ ឬ ក្រៅក្របខ័ណ្ឌក្រសួងមហាផ្ទៃ និងត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានឋានន្តរសក្តិចាប់ពីនាយក្រមការឡើង
- មានអាយុចាប់ពីម្ភៃប្រាំ (២៥) ឆ្នាំឡើង គិតដល់ថ្ងៃតែងតាំង
- មានបទពិសោជធន៍ការងារផ្នែករដ្ឋបាលសាធារណៈយ៉ាងតិចបី(៣)ឆ្នាំ ឬ/និងមានសញ្ញាបត្របរិញ្ញាបត្ររង ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា
- មានឈ្មោះក្នុងបញ្ជីឈ្មោះបោះឆ្នោតផ្លូវការក្នុងរយៈពេលនៃការតែងតាំង
- មិនធ្លាប់មានទោសឧក្រិដ្ឋ ឬ មជ្ឈិមណាមួយ។

### ២.៤.១. សិទ្ធិអំណាច

គណៈអភិបាលមានសិទ្ធិអំណាចដូចខាងក្រោម៖

- បញ្ចេញមតិយោបល់ក្នុងកិច្ចប្រជុំក្រុមប្រឹក្សា ប៉ុន្តែមិនអាចធ្វើការបោះឆ្នោតបានឡើយ
- ចុះហត្ថលេខាលើលិខិតបទដ្ឋាន និងលិខិតរដ្ឋបាលនានាសម្រាប់ចាត់ចែងការងារប្រចាំថ្ងៃ និងការងារចាំបាច់ផ្សេងៗទៀត ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា លើកលែងតែលិខិតបទដ្ឋានទាំងឡាយណាដែលតម្រូវឱ្យប្រធានក្រុមប្រឹក្សាចុះហត្ថលេខាក្នុងនាមក្រុមប្រឹក្សា

[១] យោងតាមអនុក្រឹត្យលេខ ១០៨០ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលចំនួនគណៈអភិបាលខេត្ត គណៈអភិបាលក្រុង គណៈអភិបាលស្រុក, មាត្រា២

NASLA

- ផ្តួចផ្តើមលើកសំណើ សំណូមពរជូនក្រុមប្រឹក្សារបស់ខ្លួន ដើម្បីដាក់ចេញនូវសេចក្តីសម្រេចខាងបញ្ញត្តិ ឬសេចក្តីសម្រេចខាងប្រតិបត្តិ
- លើកសំណើបង្កើតគណៈកម្មាធិការ ឬអនុគណៈកម្មាធិការ ឬក្រុមការងារនានា
- សិទ្ធិអំណាចមួយចំនួនពាក់ព័ន្ធការងារគ្រប់គ្រងបុគ្គលិកដែលមិនតម្រូវឱ្យមានការអនុម័តដោយក្រុមប្រឹក្សា។

ការសម្រេច ឬការអនុវត្តកិច្ចការណាមួយរបស់គណៈអភិបាល ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សា ហើយពុំទទួលបានការសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬការអនុវត្តកិច្ចការនោះពុំមានសុពលភាពឡើយ។ ក្នុងករណីនេះ គណៈអភិបាល ឬ អភិបាល ឬ អភិបាលរងត្រូវទទួលខុសត្រូវចំពោះមុខច្បាប់អំពីការសម្រេច ឬសកម្មភាពទាំងនោះ។

គណៈអភិបាលអាចសម្រេច ឬអនុវត្តកិច្ចការណាមួយដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាដោយពុំចាំបាច់មានការអនុញ្ញាតជាមុនពីក្រុមប្រឹក្សាបាន ក្នុងក្របខ័ណ្ឌនៃអំណាចដែលខ្លួនទទួលបានពីការធ្វើប្រតិភូកម្មពីក្រុមប្រឹក្សា ឬ ក្នុងករណីប្រធានស័ក្តិ។ ក្នុងករណីនេះ គណៈអភិបាលត្រូវធ្វើ សេចក្តីរាយការណ៍ជូនក្រុមប្រឹក្សាអំពីកិច្ចការទាំងនោះ។

NASLA

### ២.៤.២. តួនាទី ភារកិច្ច

គណៈអភិបាលមានតួនាទីជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា។ ក្រៅពីនេះ អភិបាលក៏មានតួនាទីជាតំណាងរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងដែនសមត្ថកិច្ចរបស់ស្រុកផងដែរ។

ក្នុងនាមជាអ្នកអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា គណៈអភិបាលមានភារកិច្ចសំខាន់ៗដូចជា៖

- អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា
- លើកយោបល់ជូនក្រុមប្រឹក្សា ពាក់ព័ន្ធកិច្ចការនានាដែលក្រុមប្រឹក្សាត្រូវពិនិត្យ និងអនុម័ត
- ផ្តួចផ្តើម រៀបចំ និងដាក់ជូនក្រុមប្រឹក្សានូវសេចក្តីព្រាងដីកា សេចក្តីសម្រេច និង/ឬ បទបញ្ជានានា ដើម្បីក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- ធ្វើរបាយការណ៍ជូនក្រុមប្រឹក្សាអំពីការអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា ការអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ កម្មវិធីវិនិយោគបីឆ្នាំរំកិល ថវិកា និងសកម្មភាពផ្តល់សេវាកម្មនានារបស់រដ្ឋបាលស្រុក ព្រមទាំងការអនុវត្តគម្រោង ឬកម្មវិធីនានា។

ក្នុងតួនាទីជាតំណាងរាជរដ្ឋាភិបាល តំណាងក្រសួង ស្ថាប័ននៃរាជរដ្ឋាភិបាលនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន អភិបាលត្រូវ៖

- មានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ និងក្រសួង ស្ថាប័ននានា និងធ្វើសេចក្តីរាយការណ៍ជូនរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានា
- ដឹកនាំ សម្របសម្រួលការិយាល័យ អង្គភាពពាក់ព័ន្ធ និងរដ្ឋបាលឃុំ សង្កាត់ ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ ការអនុវត្តច្បាប់ និងការការពារ

សិទ្ធិមនុស្ស ក្នុងនាមជាប្រធានគណៈបញ្ជាការឯកភាព

- ណែនាំ សម្របសម្រួល តម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួង ស្ថាប័នដែលប្រតិបត្តិការនៅក្នុងស្រុក ក្នុងការអនុវត្តតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពនៅមូលដ្ឋាន
- ការតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមន្ត្រីរាជការស៊ីវិលនៅក្នុងរដ្ឋបាលស្រុក។

NASLA

## ២.៥.នាយករដ្ឋបាល

រដ្ឋបាលស្រុកនីមួយៗមាននាយករដ្ឋបាល០១រូប និងនាយករងរដ្ឋបាលយ៉ាងច្រើន០២រូបជាជំនួយការ។

នាយករដ្ឋបាល គឺជាបុគ្គលិកមានឋានន្តរស័ក្តិទាបបំផុតត្រឹមក្រមការដើមខ្សែ (ក្របខ័ណ្ឌ ខ២) ដែលតែងតាំងឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សាតាមរយៈប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

នាយករដ្ឋបាលមានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ជាជំនួយការដល់ក្រុមប្រឹក្សា គណៈអភិបាល និងអភិបាលក្នុងការចាត់ចែងកិច្ចការរដ្ឋបាល និងការធានានិរន្តរភាពកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក។ ក្នុងការអនុវត្តតួនាទីនេះ នាយករដ្ឋបាលត្រូវ៖
    - ធ្វើរបាយការណ៍ និងត្រូវមានគណនេយ្យភាពចំពោះគណៈអភិបាល អភិបាល និងក្រុមប្រឹក្សារបស់ខ្លួន
    - រៀបចំ និងដាក់ជូនគណៈអភិបាលពិនិត្យ សម្រេចនូវកិច្ចការរដ្ឋបាលប្រចាំថ្ងៃក្នុងសាលាស្រុក ក្នុងក្របខ័ណ្ឌសមត្ថកិច្ចរបស់គណៈអភិបាល ហើយត្រូវធានាថា កិច្ចការទាំងនោះត្រូវបានរៀបចំឡើងស្របតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងទម្រង់បែបបទនៃលិខិតស្នាមរដ្ឋបាល
    - រៀបចំ និងដាក់ជូនគណៈអភិបាលនូវវិធានការ និងគោលការណ៍ក្នុងការអនុវត្ត ដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក
    - ធ្វើជាសេនាធិការជូនអភិបាល និងប្រធានក្រុមប្រឹក្សា ក្នុងការត្រៀមរៀបចំសេចក្តីព្រាងរបៀបវារៈនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា រួមទាំងការសម្របសម្រួលក្នុងការរៀបចំឯកសារ និងខ្លឹមសារសម្រាប់របៀបវារៈនីមួយៗនៃកិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា ស្របតាមបទបញ្ជាផ្ទៃក្នុងក្រុមប្រឹក្សារបស់ខ្លួន។ សេចក្តីព្រាងរបៀបវារៈ ឯកសារ និងខ្លឹមសារទាំងអស់ ដែលនាយករដ្ឋបាលសាលាស្រុកបានរៀបចំ សម្រាប់ដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សា ត្រូវដាក់ជូនគណៈអភិបាល ដើម្បី ពិនិត្យ និងផ្តល់យោបល់ជាមុន លើកលែងតែមានការកំណត់ផ្សេងដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា
    - ធ្វើជាសេនាធិការជូនក្រុមប្រឹក្សាក្នុងការរៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សា
    - ត្រៀមរៀបចំកិច្ចការនានា សម្រាប់បម្រើឱ្យកិច្ចប្រជុំទាំងអស់របស់គណៈអភិបាលតាមការណែនាំរបស់អភិបាល
    - ធានាក្នុងការទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឱ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សា អភិបាល និងអភិបាលរង ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យ និងអ្នកពាក់ព័ន្ធនានា

NASLA

- ○ គ្រប់គ្រង និងប្រើប្រាស់ត្រារដ្ឋបាលឱ្យបានត្រឹមត្រូវតាមការកំណត់
- ○ ធានារក្សាទុកដាក់ឱ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សា និងគណៈអភិបាល និងរដ្ឋបាលរបស់ខ្លួន
- ○ បំពេញភារកិច្ចផ្សេងទៀត តាមការប្រគល់ភារកិច្ចពីក្រុមប្រឹក្សាស្រុក គណៈអភិបាល អភិបាល ឬដែលតម្រូវដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

- មានសិទ្ធិចូលរួម និងបញ្ចេញយោបល់ក្នុងគ្រប់កិច្ចប្រជុំក្រុមប្រឹក្សា កិច្ចប្រជុំគណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សា និងក្នុងកិច្ចប្រជុំគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតអនុម័តឡើយ លើកលែងតែនាយករដ្ឋបាលជាសមាជិកគណៈ-កម្មាធិការ ឬអនុគណៈកម្មាធិការ ឬ ក្រុមការងារណាមួយនោះ
- ក្នុងការចូលរួមក្នុងកិច្ចប្រជុំ និងការអនុវត្តការងារប្រចាំថ្ងៃ នាយករដ្ឋបាលអាចផ្តល់យោបល់ដល់ក្រុមប្រឹក្សា គណៈកម្មាធិការ អនុគណៈកម្មាធិការ និងក្រុមការងារនានារបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន អំពីបញ្ហាច្បាប់ និងបច្ចេកទេស ដើម្បីធានាថាសេចក្តីសម្រេច និងសកម្មភាពនានារបស់ក្រុមប្រឹក្សា គណៈអភិបាល និងអភិបាលមានលក្ខណៈសមស្រប តាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ព្រមទាំងបទដ្ឋានជាតិ សម្រាប់សុវត្ថិភាព និងគុណភាពដែលបានកំណត់ ព្រមទាំងការលើកកម្ពស់ប្រសិទ្ធភាពការងារក្នុងសាលាស្រុក
- ត្រូវធានាឱ្យការិយាល័យ មន្ត្រី បុគ្គលិកទាំងអស់អនុវត្តការងារបានត្រឹមត្រូវទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនានា និងតាមការសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាលរបស់ខ្លួន។

គណៈអភិបាល និងអភិបាល អាចធ្វើប្រតិភូកម្មដល់ នាយករដ្ឋបាលឱ្យលើកយោបល់លើកិច្ចការណាមួយ ដែលស្ថិតក្នុងវិសាលភាពនៃតួនាទី ភារកិច្ចរបស់ខ្លួន ដើម្បីគណៈអភិបាល ឬអភិបាល ពិនិត្យសម្រេចតាមការចាំបាច់។

NASLA

## ២.៦. ការិយាល័យ និងអង្គភាពចំណុះ

យោងអនុក្រឹត្យលេខ១៨៤ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក បានកំណត់ឱ្យមានការិយាល័យចំណុះចំនួន១២ និងអង្គភាពចំណុះចំនួន១ ដូចខាងក្រោម ៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- អង្គភាពលទ្ធកម្ម
- ការិយាល័យគ្រប់គ្រងធនធានមនុស្ស
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់
- ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង
- ការិយាល័យលេខាធិការក្រុមប្រឹក្សា
- ការិយាល័យអប់រំ យុវជន និងកីឡា
- ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល
- ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន
- ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន
- ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍
- ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម
- ការិយាល័យច្រកចេញចូលតែមួយ។

ការិយាល័យ និងអង្គភាពនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយ(០១)រូប និងមានអនុប្រធានយ៉ាងច្រើនពីរ(០២)រូបជាជំនួយការ។ ប្រធានការិយាល័យមានមានឋានន្តរស័ក្តិទាបបំផុតត្រឹមក្រមការដើមខ្សែ (ក្របខ័ណ្ឌ ខ២) និងត្រូវតែងតាំងដោយដីការបស់រដ្ឋបាលស្រុកក្រោយមានការអនុម័តពីក្រុមប្រឹក្សា។ អនុប្រធានការិយាល័យមានឋានន្តរស័ក្តិទាបបំផុតត្រឹមក្រមការ (ក្របខ័ណ្ឌ ខ៣) និងត្រូវតែងតាំងដោយដីការបស់រដ្ឋបាលស្រុកដោយពុំចាំបាច់មានការអនុម័តពីក្រុមប្រឹក្សាឡើយ។ ដោយឡែកចំពោះប្រធានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ និងប្រធានអង្គភាពលទ្ធកម្ម មុនចេញដីកាតែងតាំង ត្រូវមានការយល់ព្រមពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

### ២.៦.១. ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

*ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ* ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម ៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ព័ត៌មាន ពិធីការ ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តរជាតិ
- ការងារអត្រានុកូលដ្ឋាន
- ការគ្រប់គ្រង និងការថែរក្សាត្រា ឯកសារ លិខិតបទដ្ឋាននានារបស់រដ្ឋបាលស្រុក
- ការពិនិត្យ និងការកែសម្រួលរចនាសម្ព័ន្ធរបស់រដ្ឋបាលស្រុក

- ការរៀបចំនីតិវិធីរដ្ឋបាល និងនីតិវិធីហិរញ្ញវត្ថុសម្រាប់អង្គភាពរបស់រដ្ឋបាលស្រុកផ្អែកតាមគោលការណ៍ និងបទប្បញ្ញត្តិជាធរមាន
- ការងារហិរញ្ញវត្ថុ ថវិកា និងទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក
- ការងារសណ្តាប់ធ្នាប់សាធារណៈ
- ការងាររបាយការណ៍ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ និងរបាយការណ៍ហិរញ្ញវត្ថុរបស់រដ្ឋបាលស្រុក
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

នីតិវិធីរដ្ឋបាលត្រូវអនុវត្តតាម សៀវភៅណែនាំកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ រួមទាំងការងារជំនាញដែលពីមុនធ្លាប់ធ្វើឡើងដោយប្រធានការិយាល័យជំនាញទៅប្រធានមន្ទីរ អង្គភាពជំនាញថ្នាក់ខេត្ត ត្រូវធ្វើតាមនីតិវិធីរដ្ឋបាលរបស់រដ្ឋបាលស្រុក។

មុខងារពាក់ព័ន្ធការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុដែលបានប្រគល់ តាមរយៈ *អនុក្រឹត្យលេខ១៨៤ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក*រួមមាន៖

- ការងារនីត្យានុកូលកម្ម
- ការងាររដ្ឋបាល
- ការងារអត្រានុកូលដ្ឋាន

ចំពោះមុខងាររងនៃមុខងារខាងលើ សូមមើលក្នុងឧបសម្ព័ន្ធទី១។

ការងាររបាយការណ៍នៅរដ្ឋបាលស្រុក សូមមើលចំណុច ៥.៣ និង ៥.៤ នៃជំពូកទី៥ ក្នុងសៀវភៅនេះ។

ការងារហិរញ្ញវត្ថុ សូមមើលចំណុច ៣.៣ នៃជំពូកទី៣ ក្នុងសៀវភៅនេះ។

### ២.៦.២. អង្គភាពលទ្ធកម្ម

អង្គភាពលទ្ធកម្មត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារលទ្ធកម្មសាធារណៈ និងមានភារកិច្ចចាត់ចែងការងារដូចខាងក្រោម៖

- ការរៀបចំផែនការលទ្ធកម្មប្រចាំឆ្នាំ
- ការរៀបចំឯកសារដេញថ្លៃ ការរៀបចំ និងការផ្សព្វផ្សាយអំពីកិច្ចលទ្ធកម្ម ការផ្តល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការរៀបចំទុកដាក់ឯកសារសំណើដេញថ្លៃ ការរៀបចំទីកន្លែង និងការរៀបចំបើកសំណើដេញថ្លៃ
- ការរៀបចំរបាយការណ៍ និងកំណត់ហេតុស្តីពីការបើកសំណើដេញថ្លៃ
- ការរៀបចំ និងការសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ការរៀបចំកិច្ចសន្យា និងលិខិតជូនដំណឹងអំពីការប្រគល់កិច្ចសន្យា
- ការផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃ
- ការតាមដានការអនុវត្តកិច្ចសន្យា និងការរៀបចំរបាយការណ៍ស្តីពីការអនុវត្តកិច្ចលទ្ធកម្ម
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។



NASLA

ចំពោះវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលស្រុក សូមមើល *សេចក្តីណែនាំលេខ០០២ សហវ .អលស ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៤ ស្តីពីវិធីសាស្ត្រ និងនីតិវិធីលទ្ធកម្មរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ* និងលិខិតបទដ្ឋានជាធរមានដទៃទៀត។

## ២.៦.៣. ការិយាល័យគ្រប់គ្រងធនធានមនុស្ស

*ការិយាល័យគ្រប់គ្រងធនធានមនុស្ស* ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារគ្រប់គ្រងធនធានមនុស្ស និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការគ្រប់គ្រង ការចាត់ចែង និងការប្រើប្រាស់បុគ្គលិករបស់រដ្ឋបាលស្រុក
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលស្រុក
- ការគ្រប់គ្រងបុគ្គលិកផ្សេងទៀតតាមការផ្ទេរសិទ្ធិអំណាចពីរាជរដ្ឋាភិបាល ឬក្រសួង ស្ថាប័ន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

ការងារបុគ្គលិក សូមមើលចំណុច ៣.២ នៃជំពូកទី៣ ក្នុងសៀវភៅនេះ។

## ២.៦.៤. ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់

*ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់* ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារផែនការ និងគាំទ្រឃុំ សង្កាត់ក្នុងស្រុក និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍ប្រាំឆ្នាំនិងកម្មវិធីវិនិយោគបីឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលស្រុក
- ការតាមដាន ការត្រួតពិនិត្យ និងការវាយតម្លៃលើការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគប(០៣)ឆ្នាំរំកិល ផែនការសកម្មភាពនិងថវិកាប្រចាំឆ្នាំ និងគម្រោងអភិវឌ្ឍន៍នានារបស់រដ្ឋបាលស្រុក
- ការងារស្ថិតិប្រជាជន
- ការគាំទ្រ ការសម្របសម្រួល និងការតាមដាន ត្រួតពិនិត្យ វាយតម្លៃរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុកលើការរៀបចំ និងការអនុវត្តផែនការអភិវឌ្ឍន៍ប្រាំ(០៥)ឆ្នាំ កម្មវិធីវិនិយោគបី(០៣) ឆ្នាំរំកិល និងគម្រោងនានារបស់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក
- ការណែនាំ និងការជំរុញការប្រមូលទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យថ្នាក់ស្រុកតាមការកំណត់
- ការគ្រប់គ្រង និងការស្វែងរកការគាំទ្រការកែច្នៃទិន្នន័យមូលដ្ឋានឃុំ សង្កាត់ និងទិន្នន័យថ្នាក់ស្រុក
- ការបណ្តុះបណ្តាល និងការអភិវឌ្ឍសមត្ថភាពបុគ្គលិក និងក្រុមប្រឹក្សាឃុំ សង្កាត់តាមតម្រូវការចាំបាច់
- ការគាំទ្របច្ចេកទេសលើការងាររដ្ឋបាល និងហិរញ្ញវត្ថុដល់រដ្ឋបាលឃុំ សង្កាត់
- ការដោះស្រាយសំណើ សំណូមពរ និងបញ្ហាប្រឈមនានារបស់រដ្ឋបាលឃុំ សង្កាត់

NASLA

- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។

នីតិវិធីនៃការរៀបចំនិងការកសាងផែនការអភិវឌ្ឍន៍ស្រុក និងកម្មវិធីវិនិយោគ សូមមើល *ប្រកាសអន្តរក្រសួងលេខ ០៨២ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងផែនការអភិវឌ្ឍន៍ស្រុក* និង *ប្រកាសអន្តរក្រសួងលេខ ០៧៦ ផក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០១៧ ស្តីពីការដាក់ឱ្យប្រើប្រាស់សេចក្តីណែនាំបច្ចេកទេសស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលស្រុក*។

### ២.៦.៥. ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង

*ការិយាល័យត្រួតពិនិត្យផ្ទៃក្នុង* ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការត្រួតពិនិត្យការបំពេញការងាររបស់ការិយាល័យ និងអង្គភាពនានាចំណុះរដ្ឋបាលស្រុក និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការត្រួតពិនិត្យលើការអនុវត្តតាមច្បាប់ ដីកា លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវានានាដែលបានកំណត់ជាធរមាន
- ការត្រួតពិនិត្យលើការងាររដ្ឋបាល ការងារបុគ្គលិក ការងារហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុក
- ការត្រួតពិនិត្យការអនុវត្តវិន័យ បទបញ្ជាផ្ទៃក្នុង ក្រមសីលធម៌ និងម៉ោងបំពេញការងាររបស់បុគ្គលិករដ្ឋបាលស្រុក
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។

### ២.៦.៦. ការិយាល័យលេខាធិការក្រុមប្រឹក្សា

*ការិយាល័យលេខាធិការក្រុមប្រឹក្សា* ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារលេខាធិការដ្ឋានជូនក្រុមប្រឹក្សា និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការរៀបចំកិច្ចប្រជុំសាមញ្ញ និងវិសាមញ្ញរបស់ក្រុមប្រឹក្សា
- ការរៀបចំកំណត់ហេតុនៃកិច្ចប្រជុំនានារបស់ក្រុមប្រឹក្សា
- ការរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នានារបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង ការថែរក្សា និងការទុកដាក់ឯកសារនានារបស់ក្រុមប្រឹក្សា
- ការបិទផ្សាយ និងការផ្សព្វផ្សាយនូវសេចក្តីសម្រេច និងឯកសារនានារបស់ក្រុមប្រឹក្សា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់ប្រធានក្រុមប្រឹក្សា និងអភិបាលស្រុក។

ការងាររៀបចំកិច្ចប្រជុំរបស់ក្រុមប្រឹក្សា និងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់ សូមមើល *ឯកសារបច្ចេកទេសស្តីពីកិច្ចប្រជុំក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* និង *ឯកសារបច្ចេកទេសស្តីពីឯកសារបច្ចេកទេសស្តីពីវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*។

ការងារគ្រប់គ្រងឯកសារ សូមមើល *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*។



NASLA

### ២.៦.៧. ការិយាល័យអប់រំ យុវជន និងកីឡា

*ការិយាល័យអប់រំ យុវជន និងកីឡា* ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារអប់រំ យុវជន និងកីឡា និងមានភារកិច្ចគ្រប់គ្រង គាំទ្រ សម្របសម្រួល និងតាមដាន ត្រួតពិនិត្យ វាយតម្លៃលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា
- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអប់រំក្រៅប្រព័ន្ធ
- ការអភិវឌ្ឍយុវជន
- ការអប់រំកាយ និងកីឡា
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។

មុខងារពាក់ព័ន្ធការិយាល័យអប់រំ យុវជន និងកីឡាដែលបានប្រតិភូកម្មទៅឱ្យរដ្ឋបាលស្រុកទូទាំងប្រទេសលើកលែងស្រុកក្នុងខេត្តបាត់ដំបង តាមរយៈ *អនុក្រឹត្យលេខ១៨៤ អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក*រួមមាន៖

- ការគ្រប់គ្រងការអប់រំកុមារតូច
- ការគ្រប់គ្រងការអប់រំបឋមសិក្សា
- ការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ
- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអភិវឌ្ឍយុវជន
- ការងារអប់រំកាយ និងកីឡា

ចំពោះមុខងាររងនៃមុខងារខាងលើ សូមមើលក្នុងឧបសម្ព័ន្ធទី២។

*__រដ្ឋបាលស្រុកនៃខេត្តបាត់ដំបង__*

ចំពោះរដ្ឋបាលស្រុកនៃខេត្តបាត់ដំបង មុខងារពាក់ព័ន្ធការិយាល័យអប់រំ យុវជន និងកីឡា ដែលបានផ្ទេរតាមរយៈ *អនុក្រឹត្យលេខ១៨៤អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក* រួមមានមុខងារដែលបានប្រគល់ចំនួន ០៣មុខងារ និងមុខងារដែលត្រូវបានធ្វើប្រតិភូកម្មចំនួន ០៣មុខងារ។

មុខងារដែលបានប្រគល់រួមមាន៖

- ការគ្រប់គ្រងការអប់រំកុមារតូច
- ការអប់រំបឋមសិក្សា និង
- ការអប់រំក្រៅប្រព័ន្ធ។

NASLA

មុខងារដែលបានប្រតិភូកម្មរួមមាន៖

- ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ
- ការអភិវឌ្ឍយុវជន និង
- ការងារអប់រំកាយ និងកីឡា។

មុខងាររង និងសកម្មភាពនៃមុខងារ ដែលត្រូវបានប្រគល់ និងធ្វើប្រតិភូកម្មខាងលើ សូមមើលក្នុងឧបសម្ព័ន្ធទី២ក។

ក្រៅពីមុខងារខាងលើគ្រឹះស្ថានបឋមសិក្សាសាធារណៈ គ្រឹះស្ថានមត្តេយ្យសិក្សាសាធារណៈ និងមជ្ឈមណ្ឌលសិក្សាសហគមន៍ ក៏ត្រូវបានធ្វើសមាហរណកម្មមកស្ថិតក្រោមការគ្រប់គ្រងរបស់ការិយាល័យអប់រំ យុវជន និងកីឡា នៃរដ្ឋបាលស្រុកនៃខេត្តបាត់ដំបង ដូចមានក្នុងគំនូសបំព្រួញនៃរចនាសម្ព័ន្ធនៃរដ្ឋបាលស្រុកនៃខេត្តបាត់ដំបង។

## ២.៦.៨. ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

*ការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល* ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- សំណង់
- ការងាររៀបចំដែនដី និងនគរូបនីយកម្ម
- ការងារភូមិបាល
- ការងារការងារលំនៅឋាន
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។

មុខងាររងពាក់ព័ន្ធការងារខាងលើដែលបានប្រគល់តាមរយៈ*អនុក្រឹត្យលេខ ១៨៤ អនក្រ.បក ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក* សូមមើលក្នុងឧបសម្ព័ន្ធទី៣។

## ២.៦.៩. ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន

*ការិយាល័យនីតិកម្ម និងសម្រុះសម្រួលវិវាទមូលដ្ឋាន* មានតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុក លើការងារនីតិកម្ម និងការសម្រុះសម្រួលវិវាទមូលដ្ឋានក្រៅប្រព័ន្ធតុលាការ និងមានភារកិច្ចចាត់ចែងលើការងារមួយចំនួនដូចខាងក្រោម៖

- ការសិក្សាស្រាវជ្រាវ ការរៀបចំ និងការផ្តល់យោបល់លើការរៀបចំលិខិតបទដ្ឋានគតិយុត្តនានារបស់រដ្ឋបាលស្រុក
- ការផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាដល់មន្ត្រី បុគ្គលិក និងប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុក
- ការផ្តល់ប្រឹក្សាយោបល់ផ្លូវច្បាប់ដល់ប្រជាពលរដ្ឋ

NASLA

- ការរៀបចំការបណ្ដុះបណ្ដាលជំនាញសម្រុះសម្រួល និងច្បាប់ដល់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក
- ការទទួលពាក្យបណ្ដឹង និងការសម្រុះសម្រួលវិវាទនៅមូលដ្ឋានដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុកស្របតាមច្បាប់កំណត់
- ការពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្ដីសម្រេចនានារបស់រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុកតាមគោលការណ៍កំណត់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។

### ២.៦.១០. ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន

*ការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន* មានតួនាទីធ្វើជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារកសិកម្ម រុក្ខប្រមាញ់ និងនេសាទ
- ការងារធនធានទឹក
- ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន
- ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

មុខងារពាក់ព័ន្ធការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថានដែលបានប្រគល់តាមរយៈ *អនុក្រឹត្យលេខ១៨៤អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក* រួមមាន៖

#### ក.វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- ការងារកសិកម្ម
- ការងារសុខភាពសត្វ និងផលិតកម្មសត្វ
- ការងារព្រៃឈើ
- ការងារជលផល
- ការផ្ដល់សេវារដ្ឋបាល

#### ខ.វិស័យធនធានទឹក

- ការងារធារាសាស្ត្រ
- ការងារគ្រប់គ្រងដីចំណីទន្លេ ស្ទឹង ព្រែក ប្រឡាយ ទំនប់ទឹក
- ការងារគ្រប់គ្រងស្ថានីយ៍បូមទឹក

**គ.វិស័យបរិស្ថាន និងធនធានធម្មជាតិ**

- ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ
- ការគ្រប់គ្រងសហគមន៍ តំបន់ការពារធម្មជាតិ
- ការងារគាំពារបរិស្ថាន
- ការងារផ្សព្វផ្សាយ
- ការងារអភិវឌ្ឍដោយចីរភាព

ចំពោះមុខងាររងនៃមុខងារខាងលើ សូមមើលឧបសម្ព័ន្ធទី៤។

### ២.៦.១១. ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍

*ការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍* ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការអភិវឌ្ឍសេដ្ឋកិច្ច ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសហគមន៍ និងមានភារកិច្ចចាត់ចែងមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសាធារណការ និងដឹកជញ្ជូន
- ការងារឧស្សាហកម្ម និងសិប្បកម្ម
- ការងាររ៉ែ និងថាមពល
- ការងារទេសចរណ៍
- ការងារអភិវឌ្ឍន៍ជនបទ
- ការងារពាណិជ្ជកម្ម
- ការងារប្រៃសណីយ៍ និងទូរគមនាគមន៍
- ការងារអភិវឌ្ឍន៍សហគមន៍
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាល។

មុខងារពាក់ព័ន្ធការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍ដែលបានប្រគល់តាមរយៈអនុក្រឹត្យលេខ១៨៤អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្តីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក រួមមាន៖

**ក.វិស័យសាធារណការ និងដឹកជញ្ជូន**

- ការងារផ្លូវថ្នល់
- ការផ្តល់សេវារដ្ឋបាល

**ខ.វិស័យឧស្សាហកម្ម និងសិប្បកម្ម**

- ការងារផ្គត់ផ្គង់ទឹកស្អាត
- ការងារផ្តល់សេវារដ្ឋបាល

**គ.វិស័យរ៉ែ និងថាមពល**

- ការងារធនធានរ៉ែ
- ការងារថាមពល
- ការងារប្រេងកាត

**ឃ.វិស័យពាណិជ្ជកម្ម**

- ការងារអាជីវកម្ម សេវាកម្ម និងពាណិជ្ជកម្ម
- ការងារបិទស្លាកថ្លៃលើមុខទំនិញ
- ការងារទីផ្សារ

**ង.វិស័យទេសចរណ៍**

- តំបន់ទេសចរណ៍ធម្មជាតិ និងតំបន់រមនីយដ្ឋានទេសចរណ៍
- ការផ្តល់សេវារដ្ឋបាល

**ច.វិស័យអភិវឌ្ឍន៍ជនបទ**

- ការអភិវឌ្ឍផ្លូវជនបទ
- ការគ្រប់គ្រង និងផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត
- ការគ្រប់គ្រង និងការផ្តល់ សេវាអនាម័យជនបទ
- ការគ្រប់គ្រងផ្សារសហគមន៍

**ឆ.វិស័យពាណិជ្ជកម្ម**

- ការងារអាជីវកម្ម សេវាកម្ម និងពាណិជ្ជកម្ម
- ការងារបិទស្លាកថ្លៃលើមុខទំនិញ
- ការងារទីផ្សារ

**ជ.វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍**

- ការងារប្រៃណីយ៍ និងទូរគមនាគមន៍

ចំពោះមុខងាររងនៃមុខងារខាងលើ សូមមើលឧបសម្ព័ន្ធទី៥។

### ២.៦.១២. ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម

*ការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម* ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារសង្គមកិច្ច និងសុខុមាលភាពសង្គម និងមានភារកិច្ចចាត់ចែងលើមុខងារមួយចំនួនដូចខាងក្រោម៖

- ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
- ការងារសុខាភិបាល
- ការងារកិច្ចការនារី
- ការងារធម្មការ និងសាសនា
- ការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការងារគ្រោះមហន្តរាយ
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

NASLA

មុខងារពាក់ព័ន្ធការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គមដែលបានប្រគល់តាមរយៈ*អនុក្រឹត្យលេខ១៨៤អនក្រ.បកចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុករួមមាន៖*

**វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

- ការងារកុមារកំព្រា និងកុមារងាយរងគ្រោះ
- ការងារជនរងគ្រោះ និងជនងាយរងគ្រោះ
- ការងារជនពិការ
- ជាតិអតីត យុទ្ធជន និងបេឡាជាតិសន្តិសុខសង្គម
- ការងារអតីតយុទ្ធជន និងគ្រួសារ
- ការងារមណ្ឌលស្ដារនីតិសម្បទា
- ការងារសមាគមមនុស្សវ័យចាស់
- ការងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែន

**វិស័យសុខាភិបាល**

- ការផ្ដល់សេវារដ្ឋបាល

**វិស័យកិច្ចការនារី**

- ការងារស្ត្រី និងកុមារ

**វិស័យធម្មការ និងសាសនា**

- ការងារធម្មការ និងសាសនា

**វិស័យការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ**

- សេវាការងារ និងទីផ្សារការងារ
- ការផ្ដល់សេវារដ្ឋបាល

**វិស័យវប្បធម៌ និងវិចិត្រសិល្បៈ**

- ការងារវប្បធម៌ និងវិចិត្រសិល្បៈ
- ការផ្ដល់សេវារដ្ឋបាល

ចំពោះមុខងាររងនៃមុខងារខាងលើ សូមមើលក្នុងឧបសម្ព័ន្ធទី៦។

### ២.៦.១៣. ការិយាល័យច្រកចេញចូលតែមួយ

*ការិយាល័យច្រកចេញចូលតែមួយ* ជាកន្លែងប្រមូលផ្ដុំការផ្ដល់សេវារដ្ឋបាលនៅកន្លែងតែមួយតាមនីតិវិធីសាមញ្ញ ប្រកបដោយគុណភាព ប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ការិយាល័យច្រកចេញចូលតែមួយត្រូវបានរៀបចំជាពីរផ្នែកគឺ ផ្នែកជួរមុខ និងផ្នែកជួរក្រោយ។

NASLA

**ផ្នែកជួរមុខ៖** គឺជាកន្លែងសម្រាប់ប្រជាពលរដ្ឋប្រាស្រ័យទាក់ទងដោយផ្ទាល់ ដើម្បីទទួលព័ត៌មាននានាអំពីការផ្តល់សេវារដ្ឋបាល ទទួលទម្រង់បែបបទ ដាក់ពាក្យស្នើសុំ បង់ប្រាក់កម្រៃ និងទទួលលទ្ធផលសម្រេចជាផ្លូវការនៃសេវារដ្ឋបាលដែលបានស្នើសុំ។

**ផ្នែកជួរក្រោយ៖** គឺជាផ្នែកដែលទ្រទ្រង់ដ៏សំខាន់លើការងារបច្ចេកទេស។ ផ្នែកជួរក្រោយមានតួនាទីពិនិត្យ និងផ្តល់យោបល់ផ្នែកបច្ចេកទេសលើការផ្តល់សេវារដ្ឋបាលតាមវិស័យជំនាញ។

ការិយាល័យច្រកចេញចូលតែមួយ ត្រូវបំពេញតួនាទីជាសេនាធិការឱ្យរដ្ឋបាលស្រុកលើការងារផ្តល់សេវារដ្ឋបាលនានា និងមានភារកិច្ចចាត់ចែងលើការងារដូចខាងក្រោម៖

- ការទទួល និងការផ្តល់សេវារដ្ឋបាលនានាជូនប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុក
- ការប្រមូល និងការបង់កម្រៃសេវារដ្ឋបាលតាមគោលការណ៍ និងនីតិវិធីកំណត់
- ការផ្តល់ព័ត៌មាននានា និងការផ្សព្វផ្សាយជាសាធារណៈពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ការទុកដាក់ ការថែរក្សា និងការគ្រប់គ្រងឯកសារនានាពាក់ព័ន្ធនឹងការផ្តល់សេវារដ្ឋបាល
- ការងារផ្សេងទៀតតាមការប្រគល់ភារកិច្ចរបស់អភិបាលស្រុក។

NASLA

# ជំពូកទី៣
# មុខងារ និងធនធាន

NASLA

# ជំពូកទី៣
# មុខងារ និងធនធាន

## ៣.១.មុខងារ

មុខងារ គឺជាអំពើ ឬសកម្មភាពដែលរាប់បញ្ចូលទាំងការផ្តល់សេវាសាធារណៈ ហេដ្ឋារចនាសម្ព័ន្ធ និងមធ្យោបាយផ្សេងៗទៀត។

រដ្ឋបាលស្រុកត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារខ្លួនដើម្បី បង្កើតជំរុញ និងធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

មុខងាររបស់រដ្ឋបាលស្រុករួមមាន មុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច ដែលបានប្រគល់ និង ឬប្រតិភូកម្មដោយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនិងអាជ្ញាធរគ្រប់លំដាប់ថ្នាក់។

### ៣.១.១. មុខងារជាជម្រើស

មុខងារជាជម្រើស គឺជាមុខងារទាំងឡាយដែលផ្តួចផ្តើមជ្រើសរើសដោយក្រុមប្រឹក្សាស្រុក ដែលមុខងារទាំងនោះ មិនស្ថិតនៅក្រោមអាណត្តិនៃក្រសួង ស្ថាប័ន មន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាល ឬស្ថិតនៅក្រោមអាណត្តិរបស់ក្រសួង ស្ថាប័ន មន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាល ប៉ុន្តែក្រសួងស្ថាប័ន មន្ទីរអង្គភាពពាក់ព័ន្ធពុំជំទាស់ចំពោះរដ្ឋបាលស្រុកក្នុងការជ្រើសរើស និងការអនុវត្តនូវមុខងារទាំងនោះ។

រដ្ឋបាលស្រុកសម្រេចប្រើប្រាស់ធនធានឆន្ទានុសិទ្ធិរបស់ខ្លួន ក្នុងការអនុវត្តមុខងារជាជម្រើស។

រដ្ឋបាលស្រុកជ្រើសរើសអនុវត្តមុខងារជាជម្រើសរបស់ខ្លួនក្នុងគោលបំណង៖

- ឆ្លើយតបទៅនឹងសេចក្តីត្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន
- កែលម្អគុណភាព និងពង្រីកវិសាលភាពនៃសេវាសាធារណៈនៅមូលដ្ឋាន
- ការពារបរិស្ថាន និងសម្រេចឱ្យបាននូវការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព
- ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន។

សូមមើល*ឯកសារបច្ចេកទេសស្តីពីការជ្រើសរើស ការគ្រប់គ្រង ការចាត់ចែង និងការអនុវត្ត មុខងារជាជម្រើសដោយក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិ បោះពុម្ពនៅលេខាធិការដ្ឋាន គ.ជ.អ.ប ឆ្នាំ២០១៥។*

### ៣.១.២. មុខងារជាកាតព្វកិច្ច

មុខងារជាកាតព្វកិច្ចគឺជាមុខងារទាំងឡាយណាដែលបានប្រគល់ ឬប្រតិភូកម្មឱ្យទៅក្រុមប្រឹក្សាដោយក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ក្នុងប្រភេទជា "មុខងារជាកាតព្វកិច្ច" ដោយភ្ជាប់មកជាមួយនូវធនធាន( បុគ្គលិក ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ) សម្រាប់អនុវត្តមុខងារទាំងនោះ។

ក្នុងការអនុវត្តមុខងារជាកាតព្វកិច្ចដែលបានប្រគល់ ឬប្រតិភូកម្ម រដ្ឋបាលស្រុកត្រូវ៖

- អនុវត្តមុខងារទាំងឡាយណាដែលបានប្រគល់ ផ្អែកតាមធនធានដែលបានផ្ទេរសម្រាប់អនុវត្តមុខងារទាំងនោះ ដោយធានាឱ្យបាននូវកម្រិតស្តង់ដាអប្បបរមា ដែលបានកំណត់ដោយក្រសួងស្ថាប័ន និងអាជ្ញាធរសាមី។ រដ្ឋបាលស្រុកមានភាពជាម្ចាស់ និងត្រូវទទួលខុសត្រូវពេញលេញក្នុងការគ្រប់គ្រង ការចាត់ចែង និងអនុវត្តមុខងារដែលបានប្រគល់ទាំងនោះ។ លើសពីនេះ រដ្ឋបាលស្រុកត្រូវខិតខំប្រឹងប្រែងកៀរគរធនធាននៅមូលដ្ឋាន ដើម្បីបង្កើនគុណភាពនៃការផ្តល់សេវាឱ្យលើសពីកម្រិតស្តង់ដាអប្បបរមា ក្នុងការឆ្លើយតបទៅនឹងតម្រូវ-ការរបស់មូលដ្ឋាន និងអនុលោមទៅតាមផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់ខ្លួន។
- អនុវត្តមុខងារទាំងឡាយណាដែលបានធ្វើប្រតិភូកម្មទៅតាមលក្ខខណ្ឌ និងស្តង់ដានានាដែលបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្តនៃការធ្វើប្រតិភូកម្ម និងតាមធនធានដែលបានផ្ទេរ ដោយធានាឱ្យបាននូវកម្រិតស្តង់ដាជាអប្បបរមា ដែលបានកំណត់ដោយក្រសួងស្ថាប័ន និងអាជ្ញាធរសាមី។ រដ្ឋបាលស្រុកត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និង អនុវត្តមុខងារដែលបានធ្វើប្រតិភូកម្មទាំងនោះ ក្នុងនាមក្រសួង ស្ថាប័ន និងអាជ្ញាធរដែលបានធ្វើប្រតិភូកម្ម។ ក្នុងន័យនេះ ក្រសួង ស្ថាប័ន និងអាជ្ញាធរដែលធ្វើប្រតិភូកម្មនៅតែមានភាពជាម្ចាស់លើមុខងារទាំងនោះ និងអាចធ្វើអន្តរាគមន៍ជាប្រចាំដើម្បីជំរុញ និងគាំទ្រ ដល់ការធ្វើប្រតិភូកម្មទាំងនោះ។ រដ្ឋបាលស្រុកត្រូវខិតខំប្រឹងប្រែងកៀរគរធនធាននៅមូលដ្ឋាន ដើម្បីបង្កើនគុណភាពនៃការផ្តល់សេវាឱ្យហួសពីកម្រិតស្តង់ដាអប្បបរមាដែលកំណត់ដោយក្រសួង ស្ថាប័ន និងអាជ្ញាធរសាមី។

### ៣.១.៣. បែបផែននៃការអនុវត្តមុខងារ

បែបផែននៃការអនុវត្តមុខងាររបស់រដ្ឋបាលស្រុករួមមាន៖

១)ការអនុវត្តផ្ទាល់ដោយការិយាល័យ អង្គភាពនានាចំណុះរដ្ឋបាលស្រុកទៅតាមធនធានដែលមាន

២)ការអនុវត្តដោយសហការជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិ ឬក្រសួង ស្ថាប័ន មន្ទីរ អង្គភាពជំនាញពាក់ព័ន្ធនានា

៣)ការចុះកិច្ចសន្យាជាមួយផ្នែកឯកជន ឬអង្គការសង្គមស៊ីវិល

៤)ការស្នើសុំឱ្យមន្ទីរ អង្គភាពជំនាញ ឬរដ្ឋបាលខេត្តអនុវត្ត

៥)ការផ្ទេរឱ្យទៅរដ្ឋបាលឃុំ សង្កាត់នីមួយៗ នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយភ្ជាប់ជាមួយនូវធនធានសម្រាប់អនុវត្តមុខងារដែលបានផ្ទេរទាំងនោះ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន

៦)ការប្រគល់ទៅឱ្យសហគ្រាសសាធារណៈដាក់លាក់ណាមួយនៃរដ្ឋបាលរបស់ខ្លួន ដែលមានស្វ័យភាពក្នុងការគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុដែលហិរញ្ញវត្ថុនេះជារបស់រដ្ឋបាលខ្លួនទាំងស្រុង ឬភាគច្រើន។

NASLA

## ៣.១.៤. ការជ្រើសរើសបែបផែននៃការអនុវត្តមុខងារ

ក្នុងការអនុវត្តមុខងាររបស់ខ្លួន រដ្ឋបាលស្រុកត្រូវសម្រេចជ្រើសរើសយកបែបផែនណាមួយ ឬបែបផែនមួយចំនួនរួមគ្នា ដូចបានបរិយាយខាងលើ ដើម្បីធានាបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។ ការជ្រើសរើសនេះ ត្រូវបានលើកលែងចំពោះមុខងារទាំងឡាយណាដែលបានផ្ទេរឱ្យទៅរដ្ឋបាលស្រុក ហើយបានកំណត់ច្បាស់លាស់អំពីបែបផែននៃការអនុវត្តមុខងារទាំងនោះ នៅក្នុងលិខិតបទដ្ឋានគតិយុត្តនៃការផ្ទេរ។

NASLA

## ៣.២.បុគ្គលិក

រដ្ឋបាលស្រុកត្រូវមានបុគ្គលិកគ្រប់គ្រាន់ទាំងបរិមាណ និងគុណភាព ដោយផ្អែកតាមស្ថានភាពភូមិសាស្ត្រ ប្រជាសាស្ត្រ ទំហំការងារ និងធនធានរបស់រដ្ឋបាលខ្លួន និងត្រូវគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់បុគ្គលិកទាំងនោះ ប្រកបដោយផលិតភាព ប្រសិទ្ធភាព និងប្រសិទ្ធផល ស្របតាមគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ពាក់ព័ន្ធនឹងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។

រដ្ឋបាលស្រុកត្រូវមានចំនួនបុគ្គលិកជាស្ត្រីសមស្រប ផ្អែកតាមតម្រូវការរបស់រដ្ឋបាលស្រុកនីមួយៗ និងផ្អែកតាមគោលនយោបាយជាតិស្តីពីសមភាពយេនឌ័រ ព្រមទាំងលើកទឹកចិត្តដល់ជនពិការ។

### ៣.២.១. និយមន័យ

បុគ្គលិករបស់ក្រុមប្រឹក្សា គឺជាមន្ត្រីរាជការស៊ីវិលនិងជាបុគ្គលិកដែលមិនមែនជាមន្ត្រីរាជការស៊ីវិល ក្នុងនោះរួមមាន៖

១)បុគ្គលិកដែលត្រូវបានជ្រើសរើស និងតែងតាំងដោយក្រុមប្រឹក្សា នៅពេលមានតម្រូវការធនធានមនុស្ស ។

២)បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញនិងផ្ទេរទៅឱ្យក្រុមប្រឹក្សា ក្នុងនោះរួមមាន ៖
- បុគ្គលិកដែលត្រូវបានរៀបចំឡើងវិញតាមការធ្វើសមាហរណកម្មរចនាសម្ព័ន្ធ និងមន្ត្រីរាជការដែលមានបច្ចុប្បន្នទៅក្នុងរចនាសម្ព័ន្ធថ្មីរបស់រដ្ឋបាលស្រុក និង
- បុគ្គលិកដែលបានផ្ទេរពីក្រសួងស្ថាប័នទៅឱ្យក្រុមប្រឹក្សា តាមរយៈកិច្ចដំណើរការនៃការផ្ទេរមុខងារនិងធនធាន។

៣)បុគ្គលិកដែលត្រូវបានតែងតាំងដោយរាជរដ្ឋាភិបាល ក្រសួង ស្ថាប័នថ្នាក់ជាតិឱ្យទៅបំពេញការងារជាមួយក្រុមប្រឹក្សា ស្របតាមលិខិតបទដ្ឋានជាធរមាន ។

បុគ្គលិកដែលមិនមែនជាមន្ត្រីរាជការស៊ីវិលរួមមាន មន្ត្រីជាប់កិច្ចសន្យា បុគ្គលិកអណ្តែត និងទីប្រឹក្សាបច្ចេកទេសដែលជ្រើសរើស និងចុះកិច្ចសន្យាជាមួយរដ្ឋបាលស្រុក សម្រាប់ជួយការងារដល់ការិយាល័យអង្គភាពនានានៃរដ្ឋបាលស្រុក។ បុគ្គលិកប្រភេទនេះ ស្ថិតក្នុងបុគ្គលិកប្រភេទទី១ខាងលើ។

សមាជិកក្រុមប្រឹក្សាមិនមែនជាបុគ្គលិករបស់ក្រុមប្រឹក្សាឡើយ។

បុគ្គលិកក្រុមប្រឹក្សា មិនរាប់បញ្ចូលមន្ត្រីនៃក្រសួង ស្ថាប័ន មន្ទីរអង្គភាពនានារបស់រាជរដ្ឋាភិបាល មន្ត្រីដទៃទៀតដែលអនុវត្តភារកិច្ចពាក់ព័ន្ធសន្តិសុខ សណ្តាប់ធ្នាប់របៀបរៀបរយសាធារណៈ ច្បាប់ និងសិទ្ធិមនុស្ស និងបុគ្គលិករបស់គម្រោងកម្មវិធីនានា ដែលបញ្ជូនឱ្យមកបំពេញការងារនៅរដ្ឋបាលស្រុកឡើយ។

### ៣.២.២. ការគ្រប់គ្រងបុគ្គលិក

រដ្ឋបាលស្រុកត្រូវគ្រប់គ្រងបុគ្គលិករបស់ខ្លួន ស្របតាមលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមានពាក់ព័ន្ធនឹងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។



NASLA

បុគ្គលិករបស់រដ្ឋបាលស្រុកត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់គណៈអភិបាលក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

បុគ្គលិករបស់រដ្ឋបាលស្រុកត្រូវបំពេញកិច្ចការប្រចាំថ្ងៃក្រោមការដឹកនាំផ្ទាល់របស់ប្រធានការិយាល័យអង្គភាពរបស់ខ្លួន ដើម្បីអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល។

ឯកសារសំខាន់ៗពាក់ព័ន្ធគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិកនៅរដ្ឋបាលស្រុកមានដូចខាងក្រោម៖

- ព្រះរាជក្រឹត្យលេខនស/រកត/០៤១៦/៣៧៣ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- អនុក្រឹត្យលេខ ២៤០ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឱ្យគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុកក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំលេខ ៧៨៩ មស.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈ ស្តីពីគោលការណ៍ បែបបទ និងនីតិវិធី នៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ
- សេចក្តីណែនាំលេខ១២៣២ មស.សណនចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ របស់ក្រសួងមុខងារសាធារណៈស្តីពីការកែសម្រួលខ្លឹមសារនៃសេចក្តីណែនាំលេខ៧៨៩ មស.សណន ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីគោលការណ៍ បែបបទ និងនីតិវិធីនៃការគ្រប់គ្រងបុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ។
- ប្រកាសលេខ៦៦០៦ ប្រក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- សៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ បោះពុម្ពលើកទី២ ដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

### ៣.២.៣. ការអភិវឌ្ឍសមត្ថភាព

រដ្ឋបាលស្រុកត្រូវអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់ខ្លួន ឱ្យមានសមត្ថភាពគ្រប់គ្រាន់ក្នុងការអនុវត្តតួនាទីភារកិច្ចរបស់ខ្លួនប្រកបដោយសីលធម៌ មនសិការវិជ្ជាជីវៈ តម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

រដ្ឋបាលស្រុកត្រូវចាត់ចែងឱ្យបុគ្គលិកគ្រប់រូបដែលជាមន្ត្រីរាជការស៊ីវិលនៃរដ្ឋបាលរបស់ខ្លួនបានចូលរួមកម្មវិធីអភិវឌ្ឍន៍សមត្ថភាពជាកាតព្វកិច្ច ដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ និងចាត់ចែងឱ្យមន្ត្រីដែលមានមុខតំណែងនៅក្នុងរដ្ឋបាលរបស់ខ្លួន បានចូលរួមកម្មវិធីអភិវឌ្ឍន៍សមត្ថភាពដទៃទៀតយ៉ាងតិចចំនួន

NASLA

**៣០ម៉ោងក្នុង១ឆ្នាំ** ដែលរៀបចំឡើងដោយក្រសួងមហាផ្ទៃ រដ្ឋបាលស្រុកសាមី និងឬអង្គភាព ស្ថាប័នដទៃ។[២]

ការអភិវឌ្ឍសមត្ថភាពបុគ្គលិករបស់រដ្ឋបាលស្រុក ត្រូវផ្តោតជាចម្បងទៅលើតម្រូវការចាំបាច់របស់បុគ្គលិក ផ្អែកតាមធនធានរបស់ខ្លួន និងធនធានពីខាងក្រៅ ដើម្បីឱ្យមានការផ្លាស់ប្តូរជាវិជ្ជមានទៅលើសមត្ថភាពបុគ្គលិក ដែលរួមមានចំណេះដឹង ជំនាញ បទពិសោធន៍ អាកប្បកិរិយា និងឥរិយាបថរបស់បុគ្គលិកនៅក្នុងរដ្ឋបាលស្រុក។

រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានកិច្ចដំណើរការនៃការអភិវឌ្ឍសមត្ថភាពរដ្ឋបាលរបស់ខ្លួនតាមជំហានសំខាន់ៗដូចខាងក្រោម៖

១).ធ្វើការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍន៍សមត្ថភាព ដើម្បីកំណត់អំពីចំណុចខ្លាំង និងចំណុចខ្សោយរបស់បុគ្គល និងស្ថាប័ននៃរដ្ឋបាលស្រុក

២).រៀបចំផែនការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលស្រុក ផ្អែកតាមលទ្ធផលនៃការប៉ាន់ប្រមាណតម្រូវការអភិវឌ្ឍន៍សមត្ថភាព

៣).រៀបចំតាក់តែង និងផ្តល់កិច្ចអន្តរាគមន៍អភិវឌ្ឍន៍សមត្ថភាព ផ្អែកតាមផែនការអភិវឌ្ឍន៍សមត្ថភាពរបស់រដ្ឋបាលស្រុក

៤).វាយតម្លៃលទ្ធផលនៃការអភិវឌ្ឍសមត្ថភាពរបស់រដ្ឋបាលស្រុក ដោយផ្តោតលើការប្រើប្រាស់ចំណេះដឹងដែលទទួលបានពីការរៀនសូត្រ និងការផ្លាស់ប្តូររបៀបរបបការងាររបស់រដ្ឋបាលស្រុក។

សូមមើល*ប្រកាសលេខ ៦៦០៦ ប្រក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ ផែនការយុទ្ធសាស្ត្ររយៈពេល៥ឆ្នាំ (២០១៩-២០២៣) ស្តីពីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ* និង *សៀវភៅណែនាំស្តីពីការអភិវឌ្ឍស្ថាប័នសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ* បោះពុម្ពលើកទី២ ដោយគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

[២] *ប្រកាសលេខ៦៦០៦ ប្រក ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការអភិវឌ្ឍសមត្ថភាពរបស់មន្ត្រីរាជការស៊ីវិលនៅទីស្តីការក្រសួងមហាផ្ទៃ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។*

## ៣.៣.ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួន ដើម្បីធានាដល់ការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ដោយផ្តោតលើតម្រូវការអភិវឌ្ឍន៍សំខាន់ៗបំផុតដូចខាងក្រោម៖

- តម្រូវការរបស់រដ្ឋបាលស្រុកក្នុងការរៀបចំសម្រាប់ទទួលមុខងារភារកិច្ចនិងធនធានថ្មីៗ
- សេវា មធ្យោបាយ សម្ភារ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាននិងចាំបាច់
- ការកាត់បន្ថយភាពក្រីក្រ និង
- តម្រូវការផ្សេងៗរបស់ស្ត្រីបុរសយុវវ័យកុមារជនពិការ ជនចាស់ជរា ជនក្រីក្រជនជាតិដើមភាគតិច និងក្រុមជនងាយរងគ្រោះផ្សេងទៀត។

ក្រុមប្រឹក្សាត្រូវគ្រប់គ្រង និងចាត់ចែងហិរញ្ញវត្ថុរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាពចំពោះប្រជាពលរដ្ឋរបស់ខ្លួន និងចំពោះរាជរដ្ឋាភិបាល ដោយអនុវត្តតាមបទដ្ឋាន វិធាន ប្រព័ន្ធ និងនីតិវិធីហិរញ្ញវត្ថុដែលបានកំណត់ជាធរមាន។

ក្រុមប្រឹក្សាគ្មានសិទ្ធិខ្ចីប្រាក់បោះផ្សាយសញ្ញាប័ណ្ណ និងឬមូលប័ត្រធានាគ្រប់កិច្ចសន្យានិងប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុណាមួយដែលនាំឱ្យកើតជាបំណុល។

ក្រុមប្រឹក្សាមានសិទ្ធិទទួលបានចំណូល**ពីប្រភពនៅមូលដ្ឋាន ពីប្រភពនៅថ្នាក់ជាតិ** និង**ពីប្រភពផ្សេងៗទៀត** ដោយអនុលោមទៅតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

### ៣.៣.១. ចំណូលពីប្រភពនៅមូលដ្ឋាន

ចំណូលពីប្រភពនៅមូលដ្ឋានរបស់រដ្ឋបាលស្រុក រួមមាន៖

១) ចំណូលសារពើពន្ធនៅមូលដ្ឋានដែលជាចំណូលពន្ធ និងអាករ ដើម្បីជាគុណប្រយោជន៍ទាំងស្រុងដល់ថវិការបស់រដ្ឋបាលស្រុក

២) ចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋាន រួមមានចំណូលដែលបានមកពី ៖

- ការជួលទ្រព្យសម្បត្តិ កម្រៃសេវា និងចំណូលផ្សេងៗរបស់រដ្ឋបាលស្រុក
- ការបែងចែកចំណូលមិនមែនសារពើពន្ធនៅមូលដ្ឋានរវាងរដ្ឋបាលស្រុក ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិផ្សេងៗ
- អំណោយដែលបានមកពីប្រភពខាងក្នុង និងខាងក្រៅដែនសមត្ថកិច្ចរបស់រដ្ឋបាលស្រុក
- ចំណូលពីប្រភពផ្សេងៗដែលកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្ត។

### ៣.៣.២. ចំណូលពីថ្នាក់ជាតិ

ចំណូលពីថ្នាក់ជាតិរបស់រដ្ឋបាលស្រុក រួមមាន៖

**ក.មូលនិធិក្រុង ស្រុក**

មូលនិធិក្រុង ស្រុកជាមូលនិធិផ្ទេរគ្មានភ្ជាប់លក្ខខណ្ឌ។ រដ្ឋបាលស្រុកប្រើប្រាស់ធនធានដែលបានមកពីប្រភពចំណូលនេះ សម្រាប់ ៖

- បំពេញភារកិច្ចតាមផ្លូវច្បាប់
- បំពេញមុខងារ ភារកិច្ចក្នុងការបង្កើត ការជំរុញ និងការធ្វើឱ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ចំណាយប្រតិបត្តិការរដ្ឋបាល និង
- អនុវត្តមុខងារជាជម្រើស។

លើសពីនេះទៀត រដ្ឋបាលស្រុកអាចពិចារណាក្នុងការប្រើប្រាស់ធនធានមូលនិធិនេះសម្រាប់ចូលរួមចំណែកក្នុងការអនុវត្តមុខងារជាកាតព្វកិច្ច។

***មូលនិធិក្រុង ស្រុក***[3] *គឺជាមូលនិធិដែលបានមកពីការផ្ទេរធនធានពីថវិកាជាតិ និងការចូលរួមចំណែកពីដៃគូអភិវឌ្ឍន៍នានា។ មូលនិធិក្រុង ស្រុកចែកចេញជា២សមាសភាគ គឺសមាសភាគប្រតិបត្តិការរដ្ឋបាលទូទៅ និងសមាសភាគអភិវឌ្ឍន៍មូលដ្ឋាន។*

*ការបែងចែកធនធាននៃសមាសភាគប្រតិបត្តិការរដ្ឋបាលទៅឱ្យរដ្ឋបាលក្រុងស្រុកនីមួយៗ អនុលោមតាមនិយាមដូចខាងក្រោម៖*

- *ចំណាយប្រាក់ឧបត្ថម្ភសម្រាប់សមាជិកក្រុមប្រឹក្សាក្រុង ស្រុក*
- *ចំណាយប្រាក់បៀវត្សរបស់អភិបាល អភិបាលរងក្រុង ស្រុក*
- *ចំណាយប្រាក់បៀវត្សរបស់បុគ្គលិកនៃរដ្ឋបាលក្រុង ស្រុក*
- *ធនធានសម្រាប់ចំណាយប្រតិបត្តិការរដ្ឋបាលផ្សេងៗត្រូវបែងចែកទៅរដ្ឋបាលក្រុងស្រុកនីមួយៗតាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម៖*
    - ***ចំណែកស្មើគ្នា៖*** *៤០% ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នាសម្រាប់រដ្ឋបាល ក្រុង ស្រុកនីមួយៗ*
    - ***សមាជិកក្រុមប្រឹក្សា និងគណៈអភិបាល៖*** *៣០%ត្រូវបែងចែកទៅតាម*

[3] *អនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃមូលនិធិក្រុង ស្រុក។*

NASLA

សមាមាត្រ នៃចំនួនសមាជិកក្រុមប្រឹក្សា និងគណៈអភិបាលនៃរដ្ឋបាលក្រុង ស្រុក នីមួយៗ

- **ចំនួនបុគ្គលិក៖** ៣០% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនមន្ត្រី បុគ្គលិកនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ។

ការវិភាជធនធាននៃសមាសភាគអភិវឌ្ឍន៍មូលដ្ឋានទៅឱ្យរដ្ឋបាលក្រុង ស្រុកនីមួយៗ តាមការគណនាដោយផ្អែកលើសន្ទស្សន៍ដូចខាងក្រោម៖

- **ចំណែកស្មើគ្នា** ៖ ៤០% ត្រូវបានបែងចែកក្នុងទំហំចំនួនស្មើៗគ្នា សម្រាប់រដ្ឋបាល ក្រុង ស្រុកនីមួយៗ
- **ចំនួនប្រជាជន** ៖ ២០% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃចំនួនប្រជាជននៃ រដ្ឋបាលក្រុង ស្រុកនីមួយៗ
- **សន្ទស្សន៍ភាពក្រីក្រ** ៖ ៤០% ត្រូវបានបែងចែកទៅតាមសមាមាត្រនៃសន្ទស្សន៍ភាពក្រីក្រនៃរដ្ឋបាលក្រុង ស្រុកនីមួយៗ

កម្រិតនៃការផ្ទេរពីថវិកាជាតិទៅក្នុងគណនីមូលនិធិក្រុង ស្រុក[4] សម្រាប់ថេរវេលា៥ឆ្នាំ (២០១៩-២០២៣) ត្រូវបានកំណត់ដូចខាងក្រោម៖

- **២០១៩៖ ១,១% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៨**
- **២០២០៖ ១,២% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០១៩**
- **២០២១៖ ១,៣% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០២០**
- **២០២២៖ ១,៤% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០២១**
- **២០២៣៖ ១,៥% នៃចំណូលចរន្តថវិកាជាតិដែលបានអនុម័តឆ្នាំ២០២២។**

**ក្នុងឆ្នាំ២០២០នេះ** មូលនិធិក្រុង ស្រុកមានធនធានសរុប ២៣៥.១១៧លានរៀល (ប្រមាណ ៥៨.០៥៣.៥៨០ដុល្លាអាមេរិក)។ គិតជាមធ្យមរដ្ឋបាលក្រុង ស្រុកនីមួយៗ ទទួលបានថវិកាសរុប១.២៤២លានរៀល (ប្រមាណ ៣០៧.១៦២ដុល្លាសហរដ្ឋអាមេរិក)។ *អត្រាប្តូរប្រាក់ ៖ ៤០៥០រៀលក្នុង១ដុល្លាសហរដ្ឋអាមេរិក។*

[4] អនុក្រឹត្យលេខ ៥០ អនក្រ.បក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៨ ស្តីពីការផ្ទេរធនធានថវិការដ្ឋជូនមូលនិធិក្រុង ស្រុក។

### ខ.មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ

មូលនិធិផ្ទេរមានភ្ជាប់លក្ខខណ្ឌ ជាមូលនិធិផ្ទេរភ្ជាប់មកជាមួយមុខងារដែលបានផ្ទេរ មូលនិធិវិនិយោគសម្រាប់រដ្ឋបាលថ្នាក់ ក្រោមជាតិ និងមូលនិធិផ្សេងៗទៀតដែលកំណត់គោលដៅជាក់លាក់។ រដ្ឋបាលស្រុកប្រើប្រាស់ធនធាន ដែលបានមកពីប្រភពចំណូលនេះ សម្រាប់អនុវត្តមុខងារជាក់លាក់ដែលបានផ្ទេរពីក្រសួង ស្ថាប័នថ្នាក់ជាតិ និងគម្រោងជាក់លាក់នានាទៅតាមលក្ខខណ្ឌនៃការផ្ទេរមូលនិធិទាំងនោះ។

### គ.ចំណូលចែករំលែក

ចំណូលចែករំលែក គឺជាចំណូលដែលត្រូវចែករំលែករវាងថ្នាក់ជាតិជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិពាក់ព័ន្ធ។

### ឃ.ថ្លៃសេវាដែលបានមកពីការបំពេញមុខងារជាភ្នាក់ងារ

រដ្ឋបាលស្រុកប្រើប្រាស់ធនធានដែលបានមកពីប្រភពចំណូលនេះ សម្រាប់បំពេញមុខងារជាភ្នាក់ងាររបស់ក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពនានា តាមការកំណត់របស់លិខិតដ្ឋានគតិយុត្តជាធមាន ឬតាមកិច្ចព្រមព្រៀងរវាងក្រសួង ស្ថាប័ន រដ្ឋបាលខេត្ត មន្ទីរ និងអង្គភាពនានាជាមួយរដ្ឋបាលស្រុកដែលក្នុងនោះបានកំណត់ច្បាស់លាស់អំពីកិច្ចការដែលត្រូវធ្វើ ពេលវេលាដែលត្រូវអនុវត្ត និងលទ្ធផលដែលត្រូវសម្រេច។

រដ្ឋបាលស្រុកទទួល និងប្រមូលចំណូលពីប្រភពនានាខាងលើនេះ ទៅតាមបែបបទ នីតិវិធី និងបទប្បញ្ញត្តិនានាជាធរមាន។

NASLA

## ៣.៤. ទ្រព្យសម្បត្តិ

ទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុករួមមានពីរប្រភេទ៖

- ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ និង
- ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង រួមទាំងអំណោយផ្សេងៗ។

### ៣.៤.១. ទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ

រដ្ឋបាលស្រុកមានសិទ្ធិគ្រប់គ្រង ប្រើប្រាស់ និងទាញយកផលចំណូលពីទ្រព្យសម្បត្តិដែលរដ្ឋផ្ទេរឱ្យ សម្រាប់ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ហើយត្រូវថែរក្សា ការពារឱ្យបានគង់វង្ស និងគ្មានសិទ្ធិលក់ដូរ ជួល ផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ដោយគ្មានការយល់ព្រម ជាមុនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃបានឡើយ។

ក្រុមប្រឹក្សាអាចស្នើសុំការអនុញ្ញាតិពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈរដ្ឋមន្ត្រីក្រសួង មហាផ្ទៃ ដើម្បីកាត់ចេញពីបញ្ជីសារពើភ័ណ្ឌនូវទ្រព្យសម្បត្តិទាំងឡាយណាដែលរដ្ឋបានផ្ទេរឱ្យ ហើយលែង អាចប្រើប្រាស់បាន។ នៅពេលទទួលបានការអនុញ្ញាតិ ការកាត់ចេញនេះត្រូវធ្វើឡើងជាសាធារណៈប្រកប ដោយតម្លាភាព យុត្តិធម៌ និងការប្រកួតប្រជែង។

### ៣.៤.២. ទ្រព្យសម្បត្តិដែលរកបានដោយខ្លួនឯង

ទ្រព្យសម្បត្តិដែលរដ្ឋបាលស្រុករកបានដោយខ្លួនឯង គឺជាកម្មសិទ្ធិផ្ទាល់របស់រដ្ឋបាលស្រុកដែលរដ្ឋបាល ស្រុកមានសិទ្ធិស្វ័យសម្រេចក្នុងការគ្រប់គ្រងនិងប្រើប្រាស់ ដើម្បីទាញយកផលចំណូលពីទ្រព្យសម្បត្តិ ទាំងនោះ សម្រាប់ការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាននៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន នៅ ក្នុងក្របខ័ណ្ឌដែលត្រូវបានកំណត់ដោយច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។

រដ្ឋបាលស្រុកមានសិទ្ធិលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលរកបានដោយខ្លួន ឯង ដោយត្រូវអនុវត្តតាមគោលការណ៍ដូចខាងក្រោម ៖

- ក្រុមប្រឹក្សាស្រុកត្រូវបង្កើតគណៈកម្មការមួយដើម្បីដំណើរការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរ ការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការលក់ដូរ ឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិត្រូវជានាឱ្យមានតម្លាភាព និងបើកទូលាយដល់ការប្រកួតប្រជែងគ្នាជាសាធារណៈ
- ក្នុងការលក់ដូរឬផ្ទេរកម្មសិទ្ធិ ឬផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិ អភិបាលស្រុកត្រូវសម្រេច ដោយផ្អែកតាមអនុសាសន៍របស់គណៈកម្មការក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។

ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិរបស់រដ្ឋបាលស្រុកដែលបានមកពី អំណោយត្រូវគោរពទៅតាមលក្ខខណ្ឌដែលបានព្រមព្រៀងរវាងម្ចាស់អំណោយ និងរដ្ឋបាលស្រុក។ ក្នុង ករណីអំណោយគ្មានលក្ខខណ្ឌពីម្ចាស់អំណោយ ការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ត្រូវ អនុវត្តតាមនីតិវិធីនៃការលក់ដូរ ឬការផ្ទេរកម្មសិទ្ធិ ឬការផ្ទេរការប្រើប្រាស់ទ្រព្យសម្បត្តិដែលរដ្ឋបាលស្រុក រកបានដោយខ្លួនឯង។

NASLA

### ៣.៤.៣. ការរៀបចំបញ្ជីសារពើភណ្ឌ

រដ្ឋបាលស្រុក ដោយមានការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ជាសេនាធិការ ត្រូវធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិទាំងអស់ និងត្រូវធ្វើបច្ចុប្បន្នកម្មជារៀងរាល់ឆ្នាំ ហើយត្រូវបញ្ជូនទៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត ដើម្បីបញ្ចូលក្នុងបញ្ជីសារពើភណ្ឌរួមនៃទ្រព្យសម្បត្តិរដ្ឋតាមនីតិវិធីជាធរមាន។

NASLA

# ជំពូកទី៤

# ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាព

NASLA

# ជំពូកទី៤
# ទំនាក់ទំនងការងារ និងខ្សែគណនេយ្យភាព

## ៤.១.ទំនាក់ទំនងការងារ

ដើម្បីលើកកម្ពស់កិច្ចសហការ និងប្រសិទ្ធភាពការងាររបស់ខ្លួន រដ្ឋបាលស្រុកអាចមានទំនាក់ទំនងការងារជាមួយអ្នកពាក់ព័ន្ធដូចខាងក្រោម៖

- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព
- រដ្ឋបាលខេត្ត
- រដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក
- រដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត
- វិស័យឯកជន និងសង្គមស៊ីវិល។

### ៤.១.១.ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានារួមមាន៖

- ក្រសួង ស្ថាប័នមានតួនាទីត្រួតពិនិត្យនីត្យានុកូលភាពលើដីកា និងសេចក្តីសម្រេចនានារបស់រដ្ឋបាលស្រុក ស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាមានតួនាទីផ្តល់ការគាំទ្របច្ចេកទេស ការណែនាំ ការធ្វើអន្តរាគមន៍ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលស្រុកតាមការចាំបាច់
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាមានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ ធ្វើអធិការកិច្ច និងធ្វើសវនកម្មលើការបំពេញការងាររបស់រដ្ឋបាលស្រុក ពាក់ព័ន្ធតែនឹងវិស័យរបស់ក្រសួង ស្ថាប័នសាមីនីមួយៗស្របតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពនានាអាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាលើកិច្ចការចាំបាច់មួយចំនួនជាមួយរដ្ឋបាលស្រុក ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- រដ្ឋបាលស្រុកមានតួនាទីធ្វើសេចក្តីរាយការណ៍ជាទៀងទាត់ជូនក្រសួង ស្ថាប័នតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

រដ្ឋបាលស្រុកមានតួនាទីប្រតិបត្តិមុខងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពស្របតាមគោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងបទដ្ឋានបច្ចេកទេស ផ្អែកតាមស្ថានភាពជាក់ស្តែងរបស់ស្រុកនីមួយៗ ដើម្បីចូលរួមសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅនៃវិស័យនីមួយៗ ដែលកំណត់ដោយក្រសួង ស្ថាប័នជំនាញ។

NASLA

### ៤.១.២. ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលខេត្ត

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលខេត្តរួមមាន៖

- រដ្ឋបាលខេត្តមានតួនាទីត្រួតពិនិត្យនីត្យានុកូលភាពរាល់ដីកា និងសេចក្ដីសម្រេចនានារបស់រដ្ឋបាលស្រុក តាមការធ្វើប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន
- រដ្ឋបាលខេត្តមានតួនាទីផ្ដល់អនុលោមភាពទៅលើកិច្ចការជាក់លាក់មួយចំនួន របស់រដ្ឋបាលស្រុកតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រដ្ឋបាលខេត្តមានតួនាទីផ្ដល់ការគាំទ្របច្ចេកទេស ការធ្វើអន្តរាគមន៍ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលស្រុក តាមការស្នើសុំរបស់រដ្ឋបាលស្រុក និងតាមការចាំបាច់
- រដ្ឋបាលខេត្តមានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ចលើការអនុវត្តមុខងាររបស់រដ្ឋបាលស្រុកតាមការធ្វើប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន
- គណៈអភិបាលខេត្តត្រូវធ្វើការដឹកនាំ ណែនាំ សម្របសម្រួលដល់គណៈអភិបាលស្រុក ដើម្បីធានារក្សាសណ្ដាប់ធ្នាប់ សន្តិសុខសាធារណៈ ការគោរពសិទ្ធិមនុស្ស ការគោរពច្បាប់ នៅក្នុងដែនសមត្ថកិច្ចរបស់ស្រុកនីមួយៗ
- រដ្ឋបាលខេត្តអាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាលើកិច្ចការចាំបាច់មួយចំនួនជាមួយរដ្ឋបាលស្រុក ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាពនៃការផ្ដល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- រដ្ឋបាលស្រុកមានតួនាទីធ្វើរបាយការណ៍ជាទៀងទាត់ជូនរដ្ឋបាលខេត្តដើម្បីបូកសរុប និងរាយការណ៍ជូនក្រសួង ស្ថាប័ន តាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

ករណីមិនចុះសម្រុងគ្នារវាងរដ្ឋបាលខេត្តជាមួយរដ្ឋបាលស្រុក ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលដោះស្រាយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ៤.១.៣. ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុករួមមាន៖

- រដ្ឋបាលស្រុកមានតួនាទីត្រួតពិនិត្យនីត្យានុកូលភាពរាល់ដីកា និងសេចក្ដីសម្រេចនានារបស់រដ្ឋបាលឃុំ សង្កាត់ តាមការធ្វើប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន
- រដ្ឋបាលស្រុកមានតួនាទីផ្ដល់ការគាំទ្របច្ចេកទេស ការណែនាំ ការធ្វើអន្តរាគមន៍ និងការអភិវឌ្ឍសមត្ថភាពដល់រដ្ឋបាលឃុំ សង្កាត់តាមការស្នើសុំរបស់រដ្ឋបាលឃុំ សង្កាត់ និងតាមការចាំបាច់
- រដ្ឋបាលស្រុកមានតួនាទីតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើអធិការកិច្ចលើការអនុវត្តមុខងាររបស់រដ្ឋបាលឃុំ សង្កាត់តាមការធ្វើប្រតិភូកម្មអំណាចពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន

NASLA

- រដ្ឋបាលឃុំ សង្កាត់មានតួនាទីធ្វើរបាយការណ៍ជាទៀងទាត់ជូនរដ្ឋបាលស្រុក តាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន
- រដ្ឋបាលស្រុកអាចពិគ្រោះយោបល់ និងធ្វើកិច្ចសហប្រតិបត្តិការរួមគ្នាលើកិច្ចការចាំបាច់មួយចំនួនជាមួយរដ្ឋបាលឃុំ សង្កាត់ ដើម្បីធានាលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន
- គណៈអភិបាលស្រុកត្រូវធ្វើការដឹកនាំ និងណែនាំដល់ចៅសង្កាត់ និងមេឃុំក្នុងស្រុក ដើម្បីធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់

ក្នុងការអនុវត្តការងារខាងលើនេះ រដ្ឋបាលស្រុកត្រូវធានានូវសិទ្ធិអំណាចរបស់រដ្ឋបាលឃុំ សង្កាត់ដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

ក្នុងករណីមិនចុះសម្រុងគ្នារវាងរដ្ឋបាលស្រុក ជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលដោះស្រាយ។

### ៤.១.៤. ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀត

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតរួមមាន៖

- រដ្ឋបាលស្រុកអាចធ្វើការសម្របសម្រួល ការពិគ្រោះយោបល់ និងកិច្ចសហការរួមគ្នាជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតក្នុងការអនុវត្តមុខងារ គម្រោង កម្មវិធីនានា និងការដោះស្រាយតម្រូវការ និងបញ្ហាប្រឈមនានាដែលមានការពាក់ព័ន្ធគ្នាតាមរយៈការរៀបចំយន្តការគ្រប់គ្រងរួមគ្នា ឬការដាក់ចេញនូវដីកា ឬសេចក្តីសម្រេចរួមគ្នា
- រដ្ឋបាលស្រុកអាចធ្វើទំនាក់ទំនងការងារជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិដទៃទៀតក្នុងការចែករំលែកពីគ្នាទៅវិញទៅមកនូវព័ត៌មាន ចំណេះដឹង ជំនាញ និងមេរៀនបទពិសោធន៍នានា
- កិច្ចការទំនាក់ទំនងផ្សេងៗទៀតតាមការកំណត់នៃច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន និងតាមតម្រូវការចាំបាច់។

ក្នុងករណីមិនចុះសម្រុងគ្នារវាងរដ្ឋបាលស្រុក ជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក ក្រសួងមហាផ្ទៃត្រូវសម្របសម្រួលដោះស្រាយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### ៤.១.៥. ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយវិស័យឯកជន និងសង្គមស៊ីវិល

ទំនាក់ទំនងការងាររវាងរដ្ឋបាលស្រុកជាមួយវិស័យឯកជន និងសង្គមស៊ីវិលនានាដែលកំពុងប្រតិបត្តិការនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រួមមាន៖

- រដ្ឋបាលស្រុកអាចធ្វើការសម្របសម្រួល និងផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុងការចូលរួមរៀបចំ និងអនុវត្តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ(០៥)ឆ្នាំ

NASLA

កម្មវិធីវិនិយោគបី(០៣)ឆ្នាំរំកិល ផែនការ គម្រោង ឬកម្មវិធីនានារបស់រដ្ឋបាលស្រុក

- រដ្ឋបាលស្រុកអាចសម្របសម្រួលក្នុងការបង្កើតឡើងនូវភាពជាដៃគូជាមួយវិស័យឯកជន និងសង្គមស៊ីវិល ដើម្បីរួមគ្នាលើកកម្ពស់ការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋាន ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋ
- រដ្ឋបាលស្រុកអាចផ្តល់ការគាំទ្រដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានទៅតាមលទ្ធភាពធនធានរបស់រដ្ឋបាលស្រុក
- រដ្ឋបាលស្រុកផ្តល់ការលើកទឹកចិត្តដល់វិស័យឯកជន និងសង្គមស៊ីវិលនានាក្នុងការផ្តួចផ្តើមលើកឡើងនូវតម្រូវការ និងសំណើសំណូមពរនានារបស់ប្រជាពលរដ្ឋ ដើម្បីឱ្យរដ្ឋបាលស្រុកដាក់ចេញនូវដីកា ឬសេចក្តីសម្រេច ឬផ្តល់កិច្ចអន្តរាគមន៍ដោះស្រាយ
- រដ្ឋបាលស្រុកត្រូវរៀបចំកិច្ចប្រជុំជាទៀងទាត់ជាមួយវិស័យឯកជន និងសង្គមស៊ីវិលដើម្បីចូលរួមចំណែកក្នុងការដោះស្រាយបញ្ហាប្រឈមនានា។

NASLA

## ៤.២. ខ្សែគណនេយ្យភាព

នៅក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន រដ្ឋបាលស្រុកមានខ្សែគណនេយ្យភាពដូចខាងក្រោម៖

- គណនេយ្យភាពចំពោះប្រជាពលរដ្ឋ
- គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន
- គណនេយ្យភាពផ្ទៃក្នុង

### ៤.២.១. គណនេយ្យភាពចំពោះប្រជាពលរដ្ឋ

រដ្ឋបាលស្រុកត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋ ក្នុងការបំពេញតួនាទី ភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា។

ក្នុងការធ្វើគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានយន្តការ មធ្យោបាយ និងនីតិវិធីនៃការផ្តល់ព័ត៌មានជូនប្រជាពលរដ្ឋ ការទទួលព័ត៌មានត្រឡប់ពីប្រជាពលរដ្ឋ និងការពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋ ដើម្បីធានាថា រាល់សេចក្តីសម្រេចនានា និងរាល់សកម្មភាព ឬទង្វើរបស់រដ្ឋបាលស្រុកត្រូវឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព តម្លាភាព បរិយាប័ន្ន និងសមធម៌សង្គម។

### ៤.២.២. គណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន

រដ្ឋបាលស្រុកត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័នក្នុងការបំពេញតួនាទីភារកិច្ចក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ក្នុងការធ្វើគណនេយ្យភាពចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន រដ្ឋបាលស្រុកត្រូវធានាថារាល់សេចក្តីសម្រេចនានា និងរាល់សកម្មភាព ឬទង្វើរបស់រដ្ឋបាលស្រុកត្រូវអនុលោមទៅតាមគោលនយោបាយ ច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងស្តង់ដាសេវារបស់ថ្នាក់ជាតិ។

សេចក្តីសម្រេចទាំងឡាយណាដែលធ្វើឡើងមិនស្របតាមគោលនយោបាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សេចក្តីសម្រេចនោះពុំមានសុពលភាពឡើយ។ ក្នុងករណីចាំបាច់ ក្រសួងមហាផ្ទៃ ត្រូវណែនាំ ឬធ្វើអន្តរាគមន៍ ដើម្បីឱ្យរដ្ឋបាលស្រុកកែតម្រូវ ឬលុបចោលនូវសេចក្តីសម្រេចដែលធ្វើឡើងមិនស្របច្បាប់នោះ។

អភិបាលត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ននានាក្នុងការអនុវត្តមុខងារដែលទទួលបានការធ្វើប្រតិភូកម្មពីរាជរដ្ឋាភិបាល និងក្រសួង ស្ថាប័ន។

### ៤.២.៣. គណនេយ្យភាពផ្ទៃក្នុង

គណនេយ្យភាពផ្ទៃក្នុង គឺជាគណនេយ្យភាពនៅក្នុងអង្គការលេខ (រចនាសម្ព័ន្ធ) ដែលរួមមានដូចខាងក្រោម៖

- អភិបាល និងគណៈអភិបាលត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សារបស់ខ្លួនអំពីការអនុវត្តដីកា និងសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សា

- គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា និងការិយាល័យប្រជាពលរដ្ឋត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សារបស់ខ្លួន
- នាយករដ្ឋបាលត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះក្រុមប្រឹក្សា អភិបាល និងគណៈ-អភិបាលរបស់ខ្លួន
- ប្រធានការិយាល័យ និងប្រធានអង្គភាពនីមួយៗត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាល
- បុគ្គលិកទាំងអស់របស់រដ្ឋបាលស្រុកត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រធានការិយាល័យ និងប្រធានអង្គភាពផ្ទាល់របស់ខ្លួន និងត្រូវមានគណនេយ្យភាពដោយប្រយោលចំពោះនាយករដ្ឋបាល អភិបាល គណៈអភិបាល និងក្រុមប្រឹក្សាតាមឋានានុក្រម។

NASLA

# ជំពូកទី៥

# របៀបរបបការងារ

NASLA

# ជំពូកទី៥

# របៀបរបបការងារ

## ៥.១.ការងាររបៀប

### ៥.១.១. ការចរាចរលិខិត

**ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ**នៃរដ្ឋបាលស្រុក គឺជាច្រកតែមួយសម្រាប់ការចរាចរនូវរាល់លិខិតទាំងអស់( ទាំងលិខិតចូល និងលិខិតចេញ )របស់រដ្ឋបាលស្រុក លើកលែងតែមានការកំណត់ដោយឡែក។

នៅក្នុងការងាររបៀប ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុមានភារកិច្ចសំខាន់ៗដូចខាងក្រោម ៖

- ចរាចរលិខិតចូល និងលិខិតចេញ
- បោះត្រា ចុះលេខ និងចុះកាលបរិច្ឆេទលិខិតចូល និងលិខិតចេញ
- កត់ត្រាចូលសៀវភៅលិខិតចូល និងសៀវភៅលិខិតចេញ
- រក្សាទុកលិខិតចូល និងលិខិតចេញ
- រក្សាទុក និងគ្រប់គ្រងត្រា សៀវភៅលិខិតចូល និងសៀវភៅលិខិតចេញ។

### ៥.១.២. ការតាក់តែងលិខិតរបស់រដ្ឋបាលស្រុក

***ការរៀបចំសេចក្តីព្រាងលិខិត៖*** ការិយាល័យ អង្គភាពសាមីនីមួយៗចំណុះរដ្ឋបាលស្រុកត្រូវផ្តួចផ្តើមរៀបចំសេចក្តីព្រាងលិខិតទៅតាមទម្រង់ដែលបានកំណត់ ដោយបរិយាយខ្លឹមសារលិខិតឱ្យបានច្បាស់លាស់ និងមានអត្ថន័យគ្រប់គ្រាន់។

***ការត្រួតពិនិត្យដោយនាយករដ្ឋបាល៖*** តាមរយៈការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យអង្គភាពសាមីត្រូវដាក់ជូននាយករដ្ឋបាលនូវសេចក្តីព្រាងលិខិតរបស់ខ្លួន ដើម្បីត្រួតពិនិត្យ។ **<u>នាយករដ្ឋបាល</u>** គឺជាអ្នកទទួលខុសត្រូវត្រួតពិនិត្យនូវរាល់លិខិតទាំងអស់ ដើម្បីជានាភាពត្រឹមត្រូវនូវទម្រង់ ខ្លឹមសារ នីត្យានុកូលភាព អក្ខរាវិរុទ្ធ និងភាពមានរបៀបរៀបរយនៃលិខិត មុននឹងដាក់ជូនថ្នាក់ដឹកនាំពិនិត្យ និងសម្រេច។

***ការចុះហត្ថលេខាសង្ខេប៖*** មុនដាក់ជូនហត្ថលេខីចុះហត្ថលេខា លិខិតត្រូវចុះហត្ថលេខាសង្ខេបដោយហត្ថលេខីសង្ខេបដែលមានភារកិច្ច តាមលំដាប់លំដោយ។

***ការចុះហត្ថលេខា៖*** តាមរយៈការិយាល័យរដ្ឋបាលនិងហិរញ្ញវត្ថុ ការិយាល័យ អង្គភាពសាមីត្រូវដាក់ជូនលិខិតដែលបានចុះហត្ថលេខាសង្ខេបរួច ទៅហត្ថលេខីដែលត្រូវចុះហត្ថលេខាលើលិខិតនោះ។

| |
|---|
| *នីតិវិធីលម្អិតនៃការងាររបៀប សូមអានសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចលេខ១០០២៩ សសរ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ។* |

NASLA

## ៥.២.របបប្រជុំ

របបប្រជុំ គឺជាកិច្ចប្រជុំជាទៀងទាត់ ទៅតាមពេលវេលាកំណត់ជាក់លាក់ណាមួយ ដូចជាកិច្ចប្រជុំប្រចាំសប្តាហ៍ ប្រចាំអឌ្ឍមាស ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំជាដើម។

នៅរដ្ឋបាលស្រុករួមមានកិច្ចប្រជុំដូចជា៖

- កិច្ចប្រជុំក្រុមប្រឹក្សា
- កិច្ចប្រជុំគណៈកម្មាធិការនានា
- កិច្ចប្រជុំគណៈអភិបាល
- កិច្ចប្រជុំអន្តរការិយាល័យ អង្គភាព និង
- កិច្ចប្រជុំផ្ទៃក្នុងការិយាល័យ ឬអង្គភាព

ក្រៅពីកិច្ចប្រជុំខាងលើនេះ នៅរដ្ឋបាលស្រុកអាចមានកិច្ចប្រជុំមួយចំនួនទៀត ដូចជាកិច្ចប្រជុំជាមួយបុគ្គលិកក្រោមឱវាទទាំងអស់នៃរដ្ឋបាលស្រុក ដែលអភិបាលស្រុកជាអធិបតីអង្គប្រជុំ និងកិច្ចប្រជុំផ្សេងៗទៀតដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានាជាដើម។

### ៥.២.១.កិច្ចប្រជុំក្រុមប្រឹក្សា

កិច្ចប្រជុំក្រុមប្រឹក្សារួមមានកិច្ចប្រជុំសាមញ្ញ និងកិច្ចប្រជុំវិសាមញ្ញ[៥] ដែលត្រូវធ្វើឡើងជាសាធារណៈនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន លើកលែងតែរបៀបវារៈណាមួយដែលតម្រូវឱ្យមានការប្រជុំពិភាក្សាដោយសម្ងាត់។

ក្រុមប្រឹក្សាត្រូវប្រជុំសាមញ្ញយ៉ាងហោចណាស់ចំនួន**១២ដងក្នុងមួយឆ្នាំ** ទៅតាមប្រតិទិនប្រជុំដែលបានអនុម័តដោយក្រុមប្រឹក្សា។ កិច្ចប្រជុំសាមញ្ញក្រុមប្រឹក្សាត្រូវប្រារព្ធឡើងមិនឱ្យមុន**២៥ថ្ងៃ** ឬលើសពី**៣៥ថ្ងៃ** បន្ទាប់ពីកិច្ចប្រជុំសាមញ្ញលើកមុនឡើយ។

ក្រុមប្រឹក្សាត្រូវអនុម័តប្រតិទិននៃកិច្ចប្រជុំសាមញ្ញរបស់ខ្លួនសម្រាប់រយៈពេល**១២ខែ** មិនឱ្យហួសពីកិច្ចប្រជុំសាមញ្ញលើកទី២ និងសម្រាប់រយៈពេលជាបន្តបន្ទាប់ទៀត ក្នុងរយៈពេល១២ខែម្តងៗ ដោយបញ្ជាក់អំពីកាលបរិច្ឆេទ និងទីកន្លែងជាក់លាក់ ហើយត្រូវផ្សព្វផ្សាយប្រតិទិនប្រជុំសាមញ្ញនេះជាសាធារណៈ ដើម្បីប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានាដែលមានបំណងចូលរួម អាចមានឱកាសចូលរួមកិច្ចប្រជុំបាន។

ក្រៅពីកិច្ចប្រជុំសាមញ្ញ ក្រុមប្រឹក្សាអាចប្រជុំវិសាមញ្ញនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួនបានតាមការចាំបាច់ ដើម្បីដោះស្រាយបញ្ហាបន្ទាន់ ឬពិសេសណាមួយ តាមការស្នើឡើងរបស់ប្រធានក្រុមប្រឹក្សា ឬសមាជិកក្រុមប្រឹក្សាមួយភាគបីនៃសមាជិកក្រុមប្រឹក្សាទាំងមូល អភិបាល ឬគណៈអភិបាល។

កិច្ចប្រជុំក្រុមប្រឹក្សាត្រូវធ្វើឡើងស្របតាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សា។

[៥] មាត្រា៧៤ និងមាត្រា៧៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

សង្ខេបដំណើរការនៃកិច្ចប្រជុំក្រុមប្រឹក្សាមានដូចខាងក្រោម៖

| | |
|---|---|
| **របបប្រជុំ** | ប្រចាំខែ |
| **អ្នកកោះប្រជុំ** | ប្រធានក្រុមប្រឹក្សា |
| **អធិបតីប្រជុំ** | ប្រធានក្រុមប្រឹក្សា |
| **កូរ៉ុមប្រជុំ** | មានវត្តមានសមាជិកក្រុមប្រឹក្សាលើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល |
| **សំឡេងអនុម័ត** | លើសពីពាក់កណ្តាលនៃចំនួនសមាជិកក្រុមប្រឹក្សាទាំងមូល។ ក្នុងករណីសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។ |
| **ការរៀបចំប្រជុំ** | នាយករដ្ឋបាល ដោយមានជំនួយពីការិយាល័យលេខាធិការក្រុមប្រឹក្សា |
| **កំណត់ហេតុប្រជុំ** | នាយករដ្ឋបាល ដោយមានជំនួយពីការិយាល័យលេខាធិការក្រុមប្រឹក្សា |

ចំពោះនីតិវិធីលម្អិតពាក់ព័ន្ធការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា សូមមើល *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*។

### ៥.២.២.កិច្ចប្រជុំគណៈកម្មាធិការនានា

រដ្ឋបាលស្រុកមានគណៈកម្មាធិការជាកាតព្វកិច្ចចំនួន៣[៦] គឺគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ និងគណៈកម្មធិការលទ្ធកម្ម។ គណៈកម្មាធិការទាំងនេះមានរបបប្រជុំដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

### *ក.កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស*

គណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ត្រូវរៀបចំកិច្ចប្រជុំសាមញ្ញរបស់ខ្លួនឱ្យបានទៀងទាត់យ៉ាងតិច០២ខែម្តង[៧] និងអាចរៀបចំកិច្ចប្រជុំវិសាមញ្ញទៅតាមការចាំបាច់។

កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែរបៀបវារៈណាមួយដែលតម្រូវឱ្យមានការប្រជុំពិភាក្សាដោយសម្ងាត់។

---

[៦] *មាត្រា១១៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។*

[៧] *មាត្រា២៣ នៃអនុក្រឹត្យលេខ២១៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាខេត្ត គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាក្រុង គណៈកម្មាធិការសម្របសម្រួលបច្ចេកទេសក្រុមប្រឹក្សាស្រុក ។*



NASLA

សង្ខេបដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសមានដូចខាងក្រោម ៖

| | |
|---|---|
| **របបប្រជុំ** | ០២ខែ |
| **អ្នកកោះប្រជុំ** | ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស |
| **អធិបតីប្រជុំ** | ប្រធានគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស |
| **កូរ៉ុមប្រជុំ** | មានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសទាំងមូល |
| **សំឡេងអនុម័ត** | លើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសទាំងមូល។ ក្នុងករណីសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។ |
| **ការរៀបចំប្រជុំ** | នាយករដ្ឋបាល ដោយមានជំនួយពីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |
| **កំណត់ហេតុប្រជុំ** | នាយករដ្ឋបាល ដោយមានជំនួយពីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |

ចំពោះនីតិវិធីលម្អិតពាក់ព័ន្ធការរៀបចំកិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស សូមមើល *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*។

## *ខ.កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវ*

គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារត្រូវរៀបចំកិច្ចប្រជុំសាមញ្ញរបស់ខ្លួនជាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ[៨]។ ក្នុងករណីចាំបាច់ គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារអាចរៀបចំកិច្ចប្រជុំវិសាមញ្ញបាន តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ឬតាមសំណើរបស់ក្រុមប្រឹក្សា ឬតាមសំណើរបស់គណៈអភិបាល ឬតាមសំណើរបស់សមាជិកមួយភាគបី(១/៣)នៃចំនួនសមាជិកពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារទាំងមូល។

កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ ត្រូវធ្វើឡើងជាសាធារណៈ លើកលែងតែរបៀបវារៈណាមួយដែលតម្រូវឱ្យមានការប្រជុំពិភាក្សាដោយសម្ងាត់។

សង្ខេបដំណើរការនៃកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារមានដូចខាងក្រោម ៖

| | |
|---|---|
| **របបប្រជុំ** | ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ |
| **អ្នកកោះប្រជុំ** | ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |
| **អធិបតីប្រជុំ** | ប្រធានគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ |

*[៨] ប្រការ១៧ នៃប្រកាសលេខ៤២៧៥ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីការការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារនៅក្នុងក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ។*



NASLA

| | |
|---|---|
| **កូរ៉ុមប្រជុំ** | មានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារទាំងមូល |
| **សំឡេងអនុម័ត** | លើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារទាំងមូល។ ក្នុងករណីសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។ |
| **ការរៀបចំប្រជុំ** | អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការ ដោយមានជំនួយពីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |
| **កំណត់ហេតុប្រជុំ** | អនុប្រធានអចិន្ត្រៃយ៍នៃគណៈកម្មាធិការ ដោយមានជំនួយពីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |

ចំពោះនីតិវិធីលម្អិតពាក់ព័ន្ធការរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ សូមមើល *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*។

## *គ.កិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម*

គណៈកម្មធិការលទ្ធកម្មត្រូវរៀបចំកិច្ចប្រជុំរបស់ខ្លួន ទៅតាមតម្រូវការជាក់ស្តែងនៃរដ្ឋបាលស្រុកពាក់ព័ន្ធនឹងការងារលទ្ធកម្ម[៩]។

សង្ខេបដំណើរការនៃកិច្ចប្រជុំគណៈកម្មធិការលទ្ធកម្មមានដូចខាងក្រោម៖

| | |
|---|---|
| **របបប្រជុំ** | ពុំមាន (មានតែការប្រជុំទៅតាមតម្រូវការជាក់ស្តែងពាក់ព័ន្ធនឹងការងារលទ្ធកម្ម) |
| **អ្នកកោះប្រជុំ** | ប្រធានគណៈកម្មធិការលទ្ធកម្ម |
| **អធិបតីប្រជុំ** | ប្រធានគណៈកម្មធិការលទ្ធកម្ម |
| **កូរ៉ុមប្រជុំ** | មានវត្តមានសមាជិកលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មធិការលទ្ធកម្មទាំងមូល |
| **សំឡេងអនុម័ត** | លើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មធិការលទ្ធកម្មទាំងមូល។ ក្នុងករណីសំឡេងឆ្នោតស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។ |
| **ការរៀបចំប្រជុំ** | ការិយាល័យលទ្ធកម្ម |
| **កំណត់ហេតុប្រជុំ** | ការិយាល័យលទ្ធកម្ម |

ចំពោះនីតិវិធីលម្អិតពាក់ព័ន្ធការរៀបចំកិច្ចប្រជុំគណៈកម្មាធិការលទ្ធកម្ម សូមមើល *សៀវភៅណែនាំ*

[៩] *ប្រកាសអន្តរក្រសួងលេខ ៣២៤ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងមហាផ្ទៃ ស្តីពីនីតិវិធីនៃការបង្កើត ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការលទ្ធកម្ម និងអង្គភាពលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។*

*ស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។*

### ៥.២.៣.កិច្ចប្រជុំគណៈអភិបាល

កិច្ចប្រជុំរបស់គណៈអភិបាល គឺជាកិច្ចប្រជុំរវាងអភិបាល និងអភិបាលរងនៅក្នុងគណៈអភិបាលរបស់ខ្លួន។

គណៈអភិបាលត្រូវជួយប្រជុំជាទៀងទាត់ប្រចាំអឌ្ឍមាស។ ការប្រជុំអឌ្ឍមាសទី២នៃខែនីមួយៗ គឺជាការប្រជុំប្រចាំខែ។ ក្រៅពីការប្រជុំប្រចាំអឌ្ឍមាស និងការប្រជុំប្រចាំខែ គណៈអភិបាលអាចជួយប្រជុំតាមការចាំបាច់ ទៅតាមសំណើរបស់អភិបាល។

សង្ខេបដំណើរការនៃកិច្ចប្រជុំគណៈអភិបាលមានដូចខាងក្រោម៖

| | |
|---|---|
| **របបប្រជុំ** | ប្រចាំអឌ្ឍមាស(០២សប្តាហ៍) |
| **អ្នកកោះប្រជុំ** | អភិបាល |
| **អធិបតីប្រជុំ** | អភិបាល |
| **កូរ៉ុមប្រជុំ** | មានវត្តមានអភិបាល អភិបាលរងលើសពីពាក់កណ្តាលនៃសមាសភាពគណៈអភិបាល |
| **សំឡេងអនុម័ត** | លើសពីពាក់កណ្តាលនៃសមាសភាពគណៈអភិបាលទាំងមូល។ ក្នុងករណីមានចំនួនសំឡេងស្មើគ្នា សំឡេងរបស់អធិបតីអង្គប្រជុំមានឧត្តមានុភាព។ |
| **ការរៀបចំប្រជុំ** | នាយករដ្ឋបាល ដោយមានជំនួយពីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |
| **កំណត់ហេតុប្រជុំ** | នាយករដ្ឋបាល ដោយមានជំនួយពីការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ |

ចំពោះនីតិវិធីលម្អិតពាក់ព័ន្ធការរៀបចំកិច្ចប្រជុំគណៈអភិបាល សូមមើល *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។*

### ៥.២.៤.កិច្ចប្រជុំអន្តរការិយាល័យ អង្គភាពចំណុះរដ្ឋបាលស្រុក

កិច្ចប្រជុំអន្តរការិយាល័យ អង្គភាពគឺជាកិច្ចប្រជុំរវាងនាយករដ្ឋបាល នាយករងរដ្ឋបាល និងប្រធានអនុប្រធានការិយាល័យ អង្គភាពទាំងអស់ចំណុះរដ្ឋបាលស្រុក។

កិច្ចប្រជុំអន្តរការិយាល័យត្រូវរៀបចំជាទៀងទាត់ប្រចាំខែ។ ក្រៅពីកិច្ចប្រជុំប្រចាំខែ នាយករដ្ឋបាលអាចកោះប្រជុំអន្តរអង្គភាពតាមការចាំបាច់។ នាយករដ្ឋបាលត្រូវកំណត់កាលវិភាគ និងពេលវេលានៃកិច្ចប្រជុំប្រចាំខែសម្រាប់ឆ្នាំនីមួយៗ។

នាយករដ្ឋបាល គឺជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីនាយករដ្ឋបាលអវត្តមាន នាយករដ្ឋនបាលស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ គ្រប់កិច្ចប្រជុំអន្តរការិយាល័យត្រូវមានកំណត់ហេតុ ដែលរៀបចំឡើងដោយលេខាកត់ត្រា និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

NASLA

គោលបំណងនៃកិច្ចប្រជុំអន្តរការិយាល័យ អង្គភាព ដើម្បី៖

- ចាត់ចែងការអនុវត្តសេចក្តីសម្រេច និងអនុសាសន៍របស់ក្រុមប្រឹក្សា គណៈអភិបាល គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា
- ពិនិត្យលទ្ធផល និងបញ្ហាប្រឈមនានាក្នុងការអនុវត្តការងារ
- ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតឡើងក្នុងការអនុវត្តការងារ
- រៀបចំផែនការការងារ ឬទិសដៅការងារសម្រាប់ការិយាល័យនីមួយៗ
- លើកយោបល់ និងអនុសាសន៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រមពិនិត្យ និងដោះស្រាយ។

ចំពោះនីតិវិធីលម្អិតពាក់ព័ន្ធការរៀបចំកិច្ចប្រជុំអន្តរការិយាល័យ អង្គភាពចំណុះរដ្ឋបាលស្រុក សូមមើល *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*។

### ៥.២.៥.កិច្ចប្រជុំផ្ទៃក្នុងការិយាល័យ ឬអង្គភាពចំណុះរដ្ឋបាលស្រុក

កិច្ចប្រជុំផ្ទៃក្នុងការិយាល័យ ឬអង្គភាព គឺជាកិច្ចប្រជុំនៅក្នុងការិយាល័យ ឬអង្គភាពនីមួយៗចំណុះរដ្ឋបាលស្រុក។

កិច្ចប្រជុំផ្ទៃក្នុងការិយាល័យ ឬអង្គភាពត្រូវរៀបចំឡើងជាទៀងទាត់ប្រចាំខែ។ ប្រធានការិយាល័យ ឬអង្គភាពនីមួយៗត្រូវកំណត់កាលវិភាគ និងពេលវេលានៃកិច្ចប្រជុំប្រចាំខែសម្រាប់ឆ្នាំនីមួយៗ ដើម្បីឱ្យមន្ត្រីក្រោមឱវាទទាំងអស់អាចត្រៀមលក្ខណៈចូលរួមប្រជុំបានគ្រប់ៗគ្នា។

ប្រធានការិយាល័យ ឬអង្គភាព គឺជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ ក្នុងករណីប្រធានការិយាល័យ ឬអង្គភាពអវត្តមាន ប្រធានការិយាល័យ ឬអង្គភាពស្តីទីជាអ្នកកោះប្រជុំ និងជាអធិបតីនៃអង្គប្រជុំ។ គ្រប់កិច្ចប្រជុំផ្ទៃក្នុងការិយាល័យ ឬអង្គភាពត្រូវមានកំណត់ហេតុ ដែលរៀបចំឡើងដោយលេខាកត់ត្រា និងត្រូវចុះហត្ថលេខាដោយអធិបតីនៃអង្គប្រជុំ។

គោលបំណងនៃកិច្ចប្រជុំផ្ទៃក្នុងការិយាល័យ ឬអង្គភាព ដើម្បី៖

- ចាត់ចែង និងណែនាំអំពីការអនុវត្តសេចក្តីសម្រេច និងអនុសាសន៍នៃកិច្ចប្រជុំអន្តរការិយាល័យ អង្គភាព
- ពិនិត្យលទ្ធផល និងបញ្ហាប្រឈមនានាក្នុងការអនុវត្តការងារ
- ពិភាក្សា និងដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងក្នុងការអនុវត្តការងារ
- រៀបចំផែនការការងារ ឬទិសដៅការងារសម្រាប់អង្គភាពរបស់ខ្លួន
- លើកយោបល់ និងអនុសាសន៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រមពិនិត្យ និងដោះស្រាយ។

ចំពោះនីតិវិធីលម្អិតពាក់ព័ន្ធការរៀបចំកិច្ចប្រជុំផ្ទៃក្នុងការិយាល័យ ឬអង្គភាពចំណុះរដ្ឋបាលស្រុក សូមមើល *សៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ*។

NASLA

### ៥.២.៦. គន្លឹះក្នុងការលើកកម្ពស់ប្រសិទ្ធភាពនៃកិច្ចប្រជុំ

ដើម្បីធានាឱ្យកិច្ចប្រជុំមានប្រសិទ្ធភាព និងដំណើរការទៅដោយរលូន ប្រធានអង្គប្រជុំត្រូវយកចិត្តទុកដាក់លើចំណុចមួយចំនួនដូចខាងក្រោម៖

- កំណត់វិន័យ ដូចជាហាមជជែកគ្នា និងបិទសំលេងទូរស័ព្ទជាដើម
- ពន្យល់ឱ្យបានច្បាស់លាស់ពីគោលបំណងនៃកិច្ចប្រជុំ
- គ្រប់គ្រងការពិភាក្សាកុំឱ្យចាកប្រធានបទ
- ខិតខំបំផុសគំនិត និងជំរុញឱ្យសមាជិកអង្គប្រជុំគ្រប់រូបចូលរួមមតិយោបល់ ចៀសវាងបរិយាកាសនៃការពិភាក្សាដែលគ្របដណ្តប់ដោយអ្នកចូលរួមមួយចំនួនតូច
- គ្រប់គ្រងពេលវេលានៃការពិភាក្សាលើរបៀបវារៈនីមួយៗតាមពេលវេលាដែលបានកំណត់
- ចុងក្រោយត្រូវធ្វើការបូកសរុបឡើងវិញអំពីចំណុចសំខាន់ៗដែលជាលទ្ធផលនៃកិច្ចប្រជុំ។

| |
|---|
| នីតិវិធីលម្អិតនៃការរៀបចំកិច្ចប្រជុំ សូមអានសៀវភៅណែនាំស្តីពីកិច្ចការរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចលេខ១០០២៩ សសរ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ ២០១៥ របស់ក្រសួងមហាផ្ទៃ។ |

## ៥.៣.របាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលស្រុក

រដ្ឋបាលស្រុកត្រូវរៀបចំរបាយការណ៍ស្តីពីការអនុវត្តការងាររបស់រដ្ឋបាលខ្លួន ជាប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ទៅតាមទម្រង់ និងពេលវេលាដែលបានកំណត់[10]។

កិច្ចដំណើរការរៀបចំ និងអនុម័តរបាយការណ៍ មានដូចខាងក្រោម៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ ប្រមូលរបាយការណ៍ពីគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ការិយាល័យ អង្គភាពចំណុះរដ្ឋបាលស្រុក ការិយាល័យជំនាញដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចស្រុក និងពីរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក ដើម្បីរៀបចំសេចក្តីព្រាងរបាយការណ៍។
- គណៈអភិបាលស្រុកប្រជុំពិនិត្យ និងផ្តល់យោបល់ទៅលើសេចក្តីព្រាងរបាយការណ៍ មុននឹងដាក់ជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុកពិនិត្យ និងអនុម័ត។
- ក្រុមប្រឹក្សាស្រុកប្រជុំពិនិត្យ និងអនុម័តរបាយការណ៍។
- អភិបាលស្រុកចុះហត្ថលេខាលើរបាយការណ៍ បន្ទាប់ពីក្រុមប្រឹក្សាអនុម័តរួច ហើយផ្ញើរបាយការណ៍នេះ០១(មួយ)ច្បាប់ជូនរដ្ឋបាលខេត្ត។

រយៈពេលនៃការរៀបចំ និងកាលបរិច្ឆេទនៃការផ្ញើរបាយការណ៍ ត្រូវអនុវត្តដូចខាងក្រោម៖

- **របាយការណ៍ប្រចាំខែ៖** រដ្ឋបាលស្រុកត្រូវរៀបចំរបាយការណ៍ប្រចាំខែនីមួយៗក្នុងឆ្នាំ(១២ខែ) យ៉ាងហោចណាស់សម្រាប់រយៈពេលចំនួន២៥ថ្ងៃ ដោយចាប់ពីថ្ងៃទី១ដល់ថ្ងៃទី២៥ នៃខែ

[10] *សេចក្តីណែនាំលេខ ០៣៥ ស.ណ.ន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*



NASLA

នីមួយៗ ហើយត្រូវផ្ញើជូនរដ្ឋបាលខេត្តឱ្យបានមុនថ្ងៃទី៥នៃខែបន្ទាប់។

- **របាយការណ៍ប្រចាំត្រីមាស៖** រដ្ឋបាលស្រុកត្រូវរៀបចំរបាយការណ៍ត្រីមាសទី១ ចាប់ពីខែមករា ដល់ខែមីនា និងរបាយការណ៍ត្រីមាសទី៣ ចាប់ពីខែកក្កដា ដល់ខែកញ្ញា ហើយត្រូវផ្ញើជូនរដ្ឋបាលខេត្តឱ្យបានមុនថ្ងៃទី១០ នៃខែមេសា សម្រាប់របាយការណ៍ប្រចាំត្រីមាសទី១ និងឱ្យបានមុនថ្ងៃទី១០ នៃខែតុលា សម្រាប់របាយការណ៍ប្រចាំត្រីមាសទី៣។ ចំពោះរបាយការណ៍ប្រចាំត្រីមាសទី២ និងត្រីមាសទី៤ ពុំចាំបាច់រៀបចំឡើយ។
- **របាយការណ៍ឆមាស៖** រដ្ឋបាលស្រុកត្រូវរៀបចំរបាយការណ៍ប្រចាំឆមាសទី១ចាប់ពីខែមករាដល់ខែមិថុនា ហើយត្រូវផ្ញើជូនរដ្ឋបាលខេត្តឱ្យបានមុនថ្ងៃទី១០នៃខែកក្កដា។ ចំពោះរបាយការណ៍ឆមាសទី២ ពុំចាំបាច់រៀបចំឡើយ។
- **របាយការណ៍ប្រចាំឆ្នាំ ៖** រដ្ឋបាលស្រុកត្រូវរៀបចំរបាយការណ៍ប្រចាំឆ្នាំ ចាប់ពីខែមករាដល់ខែធ្នូនៃឆ្នាំនីមួយៗ ហើយត្រូវផ្ញើជូនរដ្ឋបាលខេត្តឱ្យបានមុនថ្ងៃទី១០ ខែកុម្ភៈនៃឆ្នាំបន្ទាប់។

នីតិវិធី និងទម្រង់របាយការណ៍ សូមមើល *សេចក្តីណែនាំលេខ០៣៥ ស.ណ.ន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ*។

## ៥.៤.របាយការណ៍ស្តីពីការអនុវត្តការងាររបស់បុគ្គលិករដ្ឋបាលស្រុក

អភិបាលស្រុកត្រូវណែនាំដល់បុគ្គលិករបស់រដ្ឋបាលស្រុក ឱ្យរៀបចំរបាយការណ៍ស្តីពីការអនុវត្តការងាររបស់ខ្លួន ទៅតាមទម្រង់ និងពេលវេលាដែលបានកំណត់[១១]។

របាយការណ៍ស្តីពីការអនុវត្តការងាររបស់បុគ្គលិក ត្រូវសរសេរអំពីលទ្ធផលនៃការអនុវត្តការងាររបស់បុគ្គលិកម្នាក់ៗ នៅរៀងរាល់ដំណាច់ខែនីមួយៗ ហើយត្រូវអនុវត្តដូចខាងក្រោម ៖

- នាយករដ្ឋបាលស្រុក ដាក់ជូនអភិបាលស្រុក ដើម្បីពិនិត្យ និងផ្តល់យោបល់
- នាយករងរដ្ឋបាលស្រុក ប្រធាន អនុប្រធានការិយាល័យនិងអង្គភាពនានា និងបុគ្គលិកដាក់ជូននាយករដ្ឋបាលស្រុក ដើម្បីពិនិត្យ និងផ្តល់យោបល់។

របាយការណ៍ស្តីពីការអនុវត្តការងាររបស់បុគ្គលិក ត្រូវបានប្រើប្រាស់ជាមូលដ្ឋានក្នុងការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក។

នីតិវិធី និងទម្រង់របាយការណ៍ សូមមើល *សេចក្តីណែនាំលេខ០៣៥ ស.ណ.ន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ*។

## ៥.៥.លក្ខខណ្ឌការងារ

បុគ្គលិកគ្រប់រូបនៃរចនាសម្ព័ន្ធរដ្ឋបាលស្រុក ដែលមានមុខតំណែងចាប់ពីនាយករដ្ឋបាលចុះក្រោមត្រូវមានលក្ខខណ្ឌការងាររបស់ខ្លួន។

---

[១១] *សេចក្តីណែនាំលេខ ០៣៥ ស.ណ.ន ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ របស់ក្រសួងមហាផ្ទៃ ស្តីពីការរៀបចំរបាយការណ៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ។*

ការរៀបចំឱ្យមានលក្ខខណ្ឌការងាររបស់បុគ្គលិកម្នាក់ គឺដើម្បីពង្រឹងគុណភាព ប្រសិទ្ធភាពការងារ និង ការទទួលខុសត្រូវរបស់បុគ្គលិក។

លក្ខខណ្ឌការងារត្រូវប្រើប្រាស់ជាមូលដ្ឋានសម្រាប់៖

- ការបំពេញតួនាទី ភារកិច្ចរបស់បុគ្គលិក
- ការអភិវឌ្ឍសមត្ថភាពបុគ្គលិក និង
- ការវាយតម្លៃការបំពេញការងាររបស់បុគ្គលិក។

កិច្ចដំណើរការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិក មានដូចខាងក្រោម៖

- ប្រធានការិយាល័យ អង្គភាពនីមួយៗ ត្រូវរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិកនៅក្នុង ការិយាល័យ អង្គភាពរបស់ខ្លួន
- ប្រធានការិយាល័យគ្រប់គ្រងធនធានមនុស្ស ត្រូវពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាង លក្ខខណ្ឌការងារ
- នាយករដ្ឋបាលត្រូវរៀបចំកិច្ចប្រជុំមួយដើម្បីពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងលក្ខ ខណ្ឌការងារ
- គណៈអភិបាលប្រជុំពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងលក្ខខណ្ឌការងារ
- ក្រុមប្រឹក្សាប្រជុំពិនិត្យ និងអនុម័តលើសេចក្តីព្រាងលក្ខខណ្ឌការងារ
- អភិបាលចុះហត្ថលេខាលើលក្ខខណ្ឌការងារ ដែលបានអនុម័តដោយក្រុមប្រឹក្សា។

លក្ខខណ្ឌការងារដែលបានចុះហត្ថលេខារួច មួយច្បាប់ត្រូវប្រគល់ឱ្យសាមីខ្លួន មួយច្បាប់ត្រូវតម្កល់ ទុកជាឯកសារនៅរដ្ឋបាលស្រុក និងមួយច្បាប់ផ្ញើជូនក្រសួងមហាផ្ទៃ។

លក្ខខណ្ឌការងារត្រូវធ្វើបច្ចុប្បន្នភាព ឬកែសម្រួលជាប្រចាំឱ្យកាន់តែមានភាពសមស្របទៅនឹង ស្ថានភាពជាក់ស្តែងនៃការងារ ភារកិច្ច ការទទួលខុសត្រូវ និងបុគ្គលិករបស់អង្គភាពនីមួយៗ។

នីតិវិធីលម្អិតក្នុងការរៀបចំលក្ខខណ្ឌការងាររបស់បុគ្គលិក សូមមើល *សៀវភៅណែនាំស្តីពីកិច្ចការ រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* ដែលដាក់ឱ្យប្រើប្រាស់ដោយសេចក្តីសម្រេចលេខ១០០២៩ សសរ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ។

## ៥.៦.ការគ្រប់គ្រងវត្តមានរបស់បុគ្គលិក

បុគ្គលិករបស់រដ្ឋបាលស្រុក ត្រូវអនុវត្តកាតព្វកិច្ចការងាររយៈពេល**០៨(ប្រាំបី)ម៉ោង**ក្នុងមួយថ្ងៃ និង **០៥(ប្រាំ)ថ្ងៃ**ក្នុងមួយសប្តាហ៍ ចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ និងឈប់សម្រាកនៅថ្ងៃសៅរ៍ ថ្ងៃអាទិត្យ និងថ្ងៃ ឈប់សម្រាកផ្លូវការដែលកំណត់ដោយរាជរដ្ឋាភិបាលតាមរយៈអនុក្រឹត្យ[១២]។

[១២] *អនុក្រឹត្យលេខ ៥៦ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការគ្រប់គ្រងមន្ត្រីរាជការស៊ីវិល និងមន្ត្រីកិច្ចសន្យា។*

ជាទូទៅ ម៉ោងធ្វើការត្រូវបានកំណត់ដូចខាងក្រោម ៖

- ពេលព្រឹក ចាប់ពីម៉ោង០៧:០០ ដល់ម៉ោង១១:៣០
- ពេលរសៀល ចាប់ពីម៉ោង១៤:០០ ដល់ម៉ោង១៧:៣០

ទោះជាយ៉ាងនេះក្តី ក្រុមប្រឹក្សាអាចកំណត់ពេលម៉ោងចាប់ផ្តើម និងបញ្ចប់ការងារនៃរដ្ឋបាលរបស់ខ្លួនទៅតាមស្ថានភាពជាក់ស្តែង ដោយគោរពតាមគោលការណ៍៨ម៉ោងក្នុងមួយថ្ងៃ ដើម្បីធានាបាននូវនិរន្តភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

ក្នុងករណីមានតម្រូវការឱ្យបុគ្គលិកបំពេញការងារលើសម៉ោងកំណត់ក្នុងមួយថ្ងៃ ឬឱ្យបំពេញការងារក្នុងថ្ងៃឈប់សម្រាកផ្លូវការតាមប្រតិទិនរបស់រាជរដ្ឋាភិបាល ដើម្បីធានានិរន្តរភាពការងារ បុគ្គលិកនោះត្រូវបានអនុញ្ញាតឱ្យឈប់សម្រាកសងទៅតាមរយៈពេលដែលបំពេញការងារលើសម៉ោងកំណត់នោះ នៅថ្ងៃបន្ទាប់ណាមួយ។

រដ្ឋបាលស្រុកត្រូវរៀបចំឱ្យមានបញ្ជីសម្រង់វត្តមានប្រចាំថ្ងៃ ទាំងព្រឹក និងទាំងរសៀលនៃថ្ងៃធ្វើការសម្រាប់បុគ្គលិកចុះវត្តមាន។

បុគ្គលិកត្រូវចុះវត្តមាននៅរៀងរាល់ពេលចូលធ្វើការ និងពេលចេញពីធ្វើការ។ បុគ្គលិកដែលបានចុះវត្តមានរួចហើយ ប៉ុន្តែមិននៅបំពេញការងារ ត្រូវចាត់ទុកថា អវត្តមានគ្មានច្បាប់អនុញ្ញាត។

## ៥.៧.ការឈប់សម្រាកផ្លូវការ ច្បាប់ឈប់ប្រចាំឆ្នាំ និងច្បាប់ឈប់រយៈពេលខ្លី

### ៥.៧.១.ការឈប់សម្រាកផ្លូវការ

បុគ្គលិកមានសិទ្ធិទទួលបាននូវការឈប់សម្រាកជាផ្លូវការ(បុណ្យជាតិ) ទៅតាមប្រតិទិនឈប់សម្រាកផ្លូវការរបស់រាជរដ្ឋាភិបាលកម្ពុជា។

### ៥.៧.២.ច្បាប់ឈប់ប្រចាំឆ្នាំ

បុគ្គលិកមានសិទ្ធិទទួលបានច្បាប់ឈប់សម្រាកប្រចាំឆ្នាំមានប្រាក់បៀវត្ស ចំនួន**១៥ថ្ងៃ**នៃថ្ងៃធ្វើការក្នុង០១ឆ្នាំ។ បុគ្គលិកអាចទទួលបានច្បាប់ឈប់ប្រចាំឆ្នាំចំនួន**៣០ថ្ងៃ**នៃថ្ងៃធ្វើការ ប្រសិនបើបុគ្គលិកនោះបានបម្រើការងារចំនួន០២ឆ្នាំជាប់គ្នា។

បុគ្គលិកដែលមានបំណងឈប់សម្រាកប្រចាំឆ្នាំ ត្រូវដាក់ពាក្យសុំច្បាប់ឈប់សម្រាកឱ្យបានយ៉ាងតិច **០៥ថ្ងៃមុន** លើកលែងតែក្នុងករណីពិសេស។ ច្បាប់ឈប់សម្រាកប្រចាំឆ្នាំ ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតច្បាប់ឱ្យឈប់ដូចខាងក្រោម ៖

- អភិបាលស្រុកត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតច្បាប់ឱ្យឈប់ពីអភិបាលខេត្ត
- អភិបាលរងស្រុក និងមន្ត្រីបម្រើការងារក្នុងរចនាសម្ព័ន្ធរដ្ឋបាលស្រុក ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតច្បាប់ឱ្យឈប់ពីអភិបាលស្រុក។

### ៥.៧.៣.ច្បាប់ឈប់រយៈពេលខ្លី

មន្ត្រីរាជការស៊ីវិលមានសិទ្ធិស្នើសុំច្បាប់ឈប់រយៈពេលខ្លីសរុបចំនួន**១៥ថ្ងៃនៃថ្ងៃធ្វើការក្នុង០១ឆ្នាំ**។

ក្នុងករណីចាំបាច់ មន្ត្រីរាជការស៊ីវិលអាចទទួលបានការអនុញ្ញាតច្បាប់ឈប់លើសពី១៥ថ្ងៃ ប៉ុន្តែចំនួនថ្ងៃដែលលើសនោះ ត្រូវយកទៅកាត់ចេញពីចំនួនថ្ងៃនៃច្បាប់ឈប់ប្រចាំឆ្នាំ។

មន្ត្រីរាជការស៊ីវិលដែលមានបំណងឈប់សម្រាករយៈពេលខ្លី ត្រូវដាក់ពាក្យសុំច្បាប់ឈប់សម្រាក ឱ្យបានយ៉ាងតិច**០៥ថ្ងៃ**មុន លើកលែងតែក្នុងករណីពិសេស។

ច្បាប់ឈប់រយៈពេលខ្លីត្រូវមានការយល់ព្រម ដោយចេញលិខិតអនុញ្ញាតច្បាប់ឱ្យឈប់ដូចខាងក្រោម៖

#### *ក.ចំពោះច្បាប់ឈប់សម្រាករយៈពេលខ្លី ពី០១ថ្ងៃ ដល់០៥ថ្ងៃ*

- អភិបាលស្រុកត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតច្បាប់ឱ្យឈប់ពីអភិបាលខេត្ត
- អភិបាលរង នាយករដ្ឋបាល នាយករងរដ្ឋបាល និងប្រធានការិយាល័យ អង្គភាពចំណុះរដ្ឋបាល ស្រុក ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតច្បាប់ឱ្យឈប់ពីអភិបាលស្រុក
- អនុប្រធានការិយាល័យ អង្គភាព និងបុគ្គលិកដែលបម្រើការក្នុងរចនាសម្ព័ន្ធរដ្ឋបាលស្រុក ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតច្បាប់ឱ្យឈប់ ពីប្រធានការិយាល័យ អង្គភាពរបស់ខ្លួន។

#### *ខ.ចំពោះច្បាប់ឈប់សម្រាករយៈពេលខ្លីចាប់ពី០៦ថ្ងៃឡើងទៅ*

- អភិបាលស្រុកត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតច្បាប់ឱ្យឈប់ពីអភិបាលខេត្ត
- អភិបាលរង នាយក-នាយករងរដ្ឋបាល ប្រធាន-អនុប្រធានការិយាល័យ អង្គភាព និងបុគ្គលិកទាំងអស់ដែលបម្រើការក្នុងរចនាសម្ព័ន្ធរដ្ឋបាលស្រុក ត្រូវមានការយល់ព្រមដោយចេញលិខិតអនុញ្ញាតច្បាប់ឱ្យឈប់ ពីអភិបាលស្រុក។

ក្រៅពីការឈប់សម្រាកទាំងបីខាងលើនេះ បុគ្គលិកមានសិទ្ធិស្នើសុំច្បាប់ឈប់សម្រាកលំហែមាតុភាព (សម្រាប់បុគ្គលិកជាស្ត្រី) ច្បាប់ឈប់សម្រាកព្យាបាលជំងឺ ច្បាប់ឈប់សម្រាកដោយមានភារកិច្ចផ្ទាល់ខ្លួន ការសុំអនុញ្ញាតស្ថិតនៅក្រៅក្របខ័ណ្ឌដើម និងការសុំអនុញ្ញាតស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស។

នីតិវិធីលម្អិតក្នុងការសុំច្បាប់ឈប់សម្រាកទាំងនេះ សូមមើល *សៀវភៅណែនាំស្ដីពីកិច្ចការរដ្ឋបាល រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ* ដែលដាក់ឱ្យប្រើប្រាស់ដោយសេចក្ដីសម្រេចលេខ១០០២៩ សសរ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ របស់ក្រសួងមហាផ្ទៃ។

NASLA

## ៥.៨.ការបំពេញបេសកកម្ម

ក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួន សមាជិកក្រុមប្រឹក្សា អភិបាល អភិបាលរង និងបុគ្គលិករបស់ក្រុមប្រឹក្សាទាំងអស់ អាចត្រូវទៅបំពេញបេសកកម្មជាផ្លូវការ។ ក្នុងការបំពេញបេសកកម្មជាផ្លូវការនេះ អ្នកបំពេញបេសកកម្មនឹងទទួលបានប្រាក់បេសកកម្មទៅតាមការកំណត់នៅក្នុងអនុក្រឹត្យលេខ២១៦ អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ ស្តីពីប្រាក់បេសកកម្មនៅក្នុង និងក្រៅប្រទេសសម្រាប់រដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

រាល់ការបំពេញបេសកកម្មជាផ្លូវការ អ្នកបំពេញបេសកកម្មត្រូវមានលិខិតបញ្ជាបេសកកម្ម ដែលត្រូវចុះហត្ថលេខាដោយ៖

- អភិបាលស្រុក ចំពោះលិខិតបញ្ជាបេសកកម្មរបស់សមាជិកក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិកនៃរដ្ឋបាលស្រុក ក្នុងការបំពេញបេសកកម្មនៅក្នុងប្រទេស
- រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ចំពោះលិខិតបញ្ជាបេសកកម្មរបស់សមាជិកក្រុមប្រឹក្សា គណៈអភិបាល និងបុគ្គលិកនៃរដ្ឋបាលស្រុក ក្នុងការ**បំពេញបេសកកម្មនៅក្រៅប្រទេស** លើកលែងតែក្នុងករណីមានការកំណត់ផ្សេងពីនេះ។

## ៥.៩.ការអនុវត្តទណ្ឌកម្មខាងវិន័យចំពោះមន្ត្រីរាជការ

មន្ត្រីរាជការបំពេញការងារនៅរដ្ឋបាលស្រុក ត្រូវគោរពកាតព្វកិច្ច និងអនុវត្តច្បាប់ ដីកា បទបញ្ជា និងការណែនាំថ្នាក់លើរបស់ខ្លួន។

មន្ត្រីរាជការត្រូវទទួលខុសត្រូវចំពោះថ្នាក់លើអំពីកិច្ចការដែលត្រូវបំពេញក្នុងមុខតំណែងរបស់ខ្លួន និងអំពើដែលអាចធ្វើឲ្យប៉ះពាល់ទៅលើសេចក្តីថ្លៃថ្នូរ និងកិត្តិយសរបស់ខ្លួន ព្រមទាំងអង្គភាព។

មន្ត្រីរាជការដែលប្រព្រឹត្តផ្ទុយពីមាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ មាត្រា៣៧ មាត្រា៣៨ និងមាត្រា៣៩ នៃច្បាប់សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវចាត់ទុកជាកំហុស និងការធ្ដាំធ្ដងក្នុងវិជ្ជាជីវៈ។

កំហុស និងការធ្ដាំធ្ដងក្នុងវិជ្ជាជីវៈ ត្រូវយកទណ្ឌកម្មខាងវិន័យទៅអនុវត្ត។

ទណ្ឌកម្មខាងវិន័យបែងចែកជា០២ថ្នាក់ ៖

### *ក.ទណ្ឌកម្មថ្នាក់ទី១*

- ស្តីបន្ទោស
- ស្តីបន្ទោសដោយមានចំណារក្នុងសំណុំលិខិតផ្ទាល់ខ្លួន
- ផ្លាស់ដោយបង្ខំតាមវិធានការខាងវិន័យ
- លុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់។

## *ខ.ទណ្ឌកម្មថ្នាក់ទី២*

- ស្តីបន្ទោសជាទម្ងន់បណ្តាលឱ្យលុបឈ្មោះចេញពីតារាងឡើងឋានន្តរស័ក្តិ ឬថ្នាក់ ប្រសិនបើមានចុះឈ្មោះហើយ ឬធ្វើឱ្យយឺតក្នុងការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់ក្នុងចិរវេលាមួយមានកំណត់ តែមិនត្រូវឱ្យលើសពី០២ឆ្នាំ ក្នុងការដំឡើងឋានន្តរស័ក្តិ ឬថ្នាក់តាមវេនជ្រើសរើស ឬតាមវេនអតីតភាពឡើយ
- ដាក់ឱ្យទំនេរគ្មានបៀវត្សមិនឱ្យលើសពី០១ឆ្នាំ
- បន្ថយឋានន្តរស័ក្តិ ឬថ្នាក់មួយថ្នាក់ ឬច្រើនថ្នាក់
- ដាក់ឱ្យចូលនិវត្តន៍មុនកំណត់ ឬបញ្ឈប់ពីការងាររាជការដោយបង្ខំ
- បណ្តេញចេញពីមុខតំណែងមន្ត្រីរាជការ។

នៅពេលដែលមានការចោទប្រកាន់ មន្ត្រីរាជការមានសិទ្ធិប្តឹងតវ៉ាចំពោះការដាក់វិន័យ ដោយអាចទាមទាររកមូលហេតុនៃការដាក់វិន័យដូចខាងក្រោម ៖

- សិទ្ធិក្នុងការពិនិត្យសំណុំឯកសាររបស់ខ្លួន
- សិទ្ធិសំអាងសាក្សី
- សិទ្ធិក្នុងការជ្រើសរើសអ្នកការពារខ្លួន
- សិទ្ធិក្នុងការពន្យល់ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់។

សាមីខ្លួនដែលត្រូវបានចោទប្រកាន់ អាចពិនិត្យសំណុំឯកសាររបស់ខ្លួនបាន ក្នុងរយៈពេល១៥ថ្ងៃ បន្ទាប់ពីបានទទួលការជូនដំណឹងពីអភិបាល។

សាមីខ្លួនអាចធ្វើលិខិតតវ៉ាចំពោះសេចក្តីសម្រេចនោះ ទៅអភិបាលក្នុងរយៈពេល**១៥ថ្ងៃ** ក្រោយពីបានពិនិត្យមើលសំណុំរឿងរួច។ ការស៊ើបអង្កេតត្រូវធ្វើឡើងមិនឱ្យយឺតជាង០២ខែ បន្ទាប់ពីទទួលបានការតវ៉ា។

## ៥.១០.ការរៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់ការបំពេញការងាររបស់បុគ្គលិក

រដ្ឋបាលស្រុកត្រូវរៀបចំបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងការបំពេញការងាររបស់បុគ្គលិកខ្លួន ដើម្បីជានាសណ្តាប់ធ្នាប់ វិន័យ និងប្រសិទ្ធភាពការងារ។

*ការិយាល័យគ្រប់គ្រងធនធានមនុស្ស* ត្រូវផ្តួចផ្តើមរៀបចំបទបញ្ជាផ្ទៃក្នុងនេះ ដោយពិគ្រោះពិភាក្សាជាមួយការិយាល័យ អង្គភាពនានាចំណុះរដ្ឋបាលស្រុក ហើយដាក់ជូន៖

- នាយករដ្ឋបាលពិនិត្យ និងផ្តល់យោបល់
- គណៈអភិបាលពិនិត្យ និងឯកភាព
- ក្រុមប្រឹក្សាពិនិត្យ និងអនុម័ត
- អភិបាលចុះហត្ថលេខា បន្ទាប់ពីទទួលបានការអនុម័តពីក្រុមប្រឹក្សា។

*ការិយាល័យគ្រប់គ្រងធនធានមនុស្ស* ត្រូវចែកជូនគ្រប់បុគ្គលិកទាំងអស់ និងបិទនៅក្តារព័ត៌មាន និង

អង្គភាពនីមួយៗនៃរដ្ឋបាលស្រុកនូវបទបញ្ជាផ្ទៃក្នុងសម្រាប់គ្រប់គ្រងការបំពេញការងាររបស់បុគ្គលិកដែលបានចុះហត្ថលេខាដោយអភិបាល។

## ៥.១១.កាតព្វកិច្ចមន្ត្រីរាជការ

បុគ្គលិកក្រុមប្រឹក្សាដែលជាមន្ត្រីរាជការត្រូវប្រកាន់ខ្ជាប់នូវកាតព្វកិច្ចរបស់ខ្លួនដែលបានកំណត់នៅក្នុងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ទាំងនៅពេលម៉ោងបំពេញការងារ ឬនៅក្រៅពេលម៉ោងបំពេញការងារ។

គណៈអភិបាលត្រូវចាត់ចែងធ្វើការផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅក្នុងចំណោមបុគ្គលិកទាំងអស់ អំពីកាតព្វកិច្ចមួយចំនួនរបស់មន្ត្រីរាជការ ដែលមានខ្លឹមសារដូចខាងក្រោម៖

- **កាតព្វកិច្ចប្រតិបត្តិការងារ៖** មន្ត្រីរាជការគ្រប់រូបត្រូវប្រតិបត្តិដោយស្មារតីទទួលខុសត្រូវខ្ពស់ចំពោះការងារ មានគំនិតច្នៃប្រឌិត ដើម្បីឱ្យការងាររីកចម្រើន និងប្រកបដោយគុណភាព ពោលគឺមិនមែនគ្រាន់តែធ្វើការងារដើម្បីរួចខ្លួន ដោយមិនមានការទទួលខុសត្រូវចំពោះការងារនោះទេ។
- **កាតព្វកិច្ចគោរពតាមឋានានុក្រម៖** មន្ត្រីរាជការគ្រប់រូបត្រូវទទួលខុសត្រូវចំពោះថ្នាក់លើអំពីកិច្ចការរបស់ខ្លួន ហើយត្រូវគោរពបញ្ជារបស់ថ្នាក់លើតាមឋានានុក្រម។ មន្ត្រីគ្រប់រូបមានសិទ្ធិលើកសំណើ ឬផ្តល់យោបល់ទៅថ្នាក់លើរបស់ខ្លួន ប៉ុន្តែការសម្រេចគឺជាសិទ្ធិរបស់ថ្នាក់លើ។
- **កាតព្វកិច្ចអព្យាក្រឹតភាព៖** ត្រូវមានអព្យាក្រឹតភាពក្នុងការបំពេញការងារ ដោយមិនត្រូវមានភាពលម្អៀងចំពោះបុគ្គល ឬក្រុមណាមួយឡើយ និងហាមដាច់ខាតនូវការប្រើប្រាស់មុខងាររបស់ខ្លួន និងសម្ភារៈរបស់រដ្ឋ ដើម្បីបម្រើសកម្មភាពនយោបាយ។
- **កាតព្វកិច្ចរក្សាការសម្ងាត់វិជ្ជាជីវៈ៖** នៅក្នុងការបំពេញការងារ មានការងារខ្លះទាមទារឱ្យមន្ត្រីរាជការត្រូវរក្សាការសម្ងាត់ ដោយត្រូវគោរពទៅតាមលិខិតបទដ្ឋានពាក់ព័ន្ធជាធរមាន។
- **កាតព្វកិច្ចគិតគូរប្រយោជន៍ទូទៅ៖** មិនត្រូវយកពេលវេលាធ្វើការរដ្ឋ ឬប្រើប្រាស់សម្ភាររបស់រដ្ឋ សម្រាប់ទាញយកប្រយោជន៍ផ្ទាល់ខ្លួនជាដាច់ខាត។
- **កាតព្វកិច្ចគោរពលក្ខខណ្ឌការងារ៖** មិនត្រូវបំពេញការងារដោយរំលោភបំពានដល់តួនាទីភារកិច្ចរបស់មន្ត្រី ឬស្ថាប័នមានសមត្ថកិច្ចផ្សេងៗឡើយ។
- **កាតព្វកិច្ចប្រកាន់ខ្ជាប់នូវឥរិយាបទវិជ្ជមាន៖** មិនត្រូវបំពារបំពានដោយពាក្យសំដី កាយវិការ និងសកម្មភាព ដែលនាំឱ្យប៉ះពាល់ដល់អារម្មណ៍ កិត្តិយស សេចក្តីថ្លៃថ្នូររបស់បុគ្គលណាម្នាក់ឡើយ ជាពិសេសស្ត្រី ជនពិការ ជនជាតិដើមភាគតិច និងក្រុមងាយរងគ្រោះផ្សេងៗទៀត។

NASLA

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធទី១ ÷ មុខងារ និងមុខងាររងពាក់ព័ន្ធការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

| **មុខងារ** | **មុខងាររង ឬសកម្មភាព** |
|---|---|
| ១. ការងារនីត្យានុកូលកម្ម | ១. ការបញ្ជាក់ភាពត្រឹមត្រូវតាមច្បាប់ដើមលើឯកសារនានាដូចខាងក្រោមៈ<br>– វិញ្ញាបនបត្របញ្ជាក់ការសិក្សា<br>– វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាកម្រិត១ ឬមធ្យមសិក្សាបឋមភូមិ វិញ្ញាបនបត្របណ្ដោះអាសន្នមធ្យមសិក្សាកម្រិត២ ឬមធ្យមសិក្សាទុតិយភូមិ និងវិញ្ញាបនបត្របញ្ជាក់ការសិក្សាថ្នាក់ទី១២<br>– វិញ្ញាបនបត្រចុះបញ្ជីអាករលើតម្លៃបន្ថែម វិញ្ញាបនបត្រប្រកបអាជីវកម្ម និងប័ណ្ណប៉ាតង់<br>– លិខិតផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដែលមិនទាន់ចុះបញ្ជី<br>– លិខិតបញ្ជាក់លទ្ធផលនៃការប្រលងសញ្ញាបត្រមធ្យមសិក្សាកម្រិត១<br>– សញ្ញាបត្រមធ្យមសិក្សាកម្រិត២ សញ្ញាបត្រមធ្យម (បំពេញវិជ្ជា) សិក្សាទុតិយភូមិ សញ្ញាបត្រមធ្យមសិក្សាគរុកោសល្យ សញ្ញាបត្រមធ្យមសិក្សាបឋមភូមិ និងសញ្ញាបត្រគ្រូបង្រៀនកម្រិតឧត្តម<br>– ព្រឹត្តិបត្រលទ្ធផលប្រលងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ<br>– សញ្ញាបត្របរិញ្ញាបត្រ និងបរិញ្ញាបត្ររង<br>– វិញ្ញាបនបត្របណ្ដោះអាសន្នថ្នាក់បរិញ្ញាបត្រ និងថ្នាក់បរិញ្ញាបត្ររង<br>– លិខិតបញ្ជាក់ការសិក្សា<br>– អត្តសញ្ញាណប័ណ្ណ សៀវភៅស្នាក់នៅ និងសៀវភៅគ្រួសារ<br>– ប័ណ្ណសំគាល់យានយន្ត និងប័ណ្ណបើកបររថយន្ត<br>– ព្រឹត្តិបត្រពិន្ទុ<br>– ពាក្យសុំបញ្ជាក់សញ្ញាបត្រមធ្យមសិក្សាកម្រិត២ ចំណេះដឹងទូទៅ។ |
| **២. ការងាររដ្ឋបាល** | ១. ការចេញលិខិតអនុញ្ញាតបំពេញអាចម៍ដីកម្មសិទ្ធិឯកជនក្រោម ១០,០០០ម៉ែត្រការ៉េ។ |
| **៣. ការងារអត្រានុកូលដ្ឋាន** | ១. សេចក្ដីចម្លងសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត<br>២. សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ ឬសំបុត្របញ្ជាក់អាពាហ៍ពិពាហ៍<br>៣. សេចក្ដីចម្លងសំបុត្រមរណភាព ឬសំបុត្របញ្ជាក់មរណភាព។ |

NASLA

## ឧបសម្ព័ន្ធទី២ ៖ មុខងារ និងមុខងាររងពាក់ព័ន្ធការិយាល័យអប់រំ យុវជន និងកីឡា (លើកលែងស្រុកក្នុងខេត្តបាត់ដំបង)

| **មុខងារ** | **មុខងាររង ឬសកម្មភាព** |
|---|---|
| ១. ការគ្រប់គ្រងការអប់រំកុមារតូច | ១. ការគ្រប់គ្រងបុគ្គលិកមត្តេយ្យសិក្សា<br>– ពិនិត្យ និងផ្តល់យោបល់លើការផ្ទេរគ្រូមត្តេយ្យសិក្សាក្នុងខេត្ត និងឆ្លងខេត្ត តម្រូវការគ្រូមត្តេយ្យសិក្សា ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ការផ្តល់មេដាយ ប័ណ្ណសរសើរ និងការលើកទឹកចិត្តផ្សេងទៀតដល់បុគ្គលិកអប់រំ<br>– ពិនិត្យ និងសម្រេចលើការផ្លាស់ប្តូរគ្រូមត្តេយ្យសិក្សានៅក្នុងស្រុក<br>– លើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមុខតំណែងគណៈគ្រប់គ្រងសាលា<br>– ពិនិត្យ និងសម្រេចលើការស្នើសុំច្បាប់ឈប់សម្រាក លំហែមាតុភាព និងការសម្រាកព្យាបាលជំងឺដល់គណៈគ្រប់គ្រងសាលា និងបុគ្គលិកអប់រំតាមគោលការណ៍កំណត់<br>– តាមដាន ត្រួតពិនិត្យលើការបង្រៀនរបស់គ្រូមត្តេយ្យសិក្សា និងការគ្រប់គ្រងសាលាមត្តេយ្យសិក្សា<br>– គ្រប់គ្រងបុគ្គលិកអប់រំតាមប្រព័ន្ធព័ត៌មានវិទ្យា<br>– ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំកុមារតូចនៅតាមសាលារៀន<br>– ត្រួតពិនិត្យលើការគ្រប់គ្រងវត្តមាន និងសម្រេចដាក់ទណ្ឌកម្មខាងវិន័យថ្នាក់ទី១<br>– ពិនិត្យ ផ្តល់យោបល់ និងលើកសំណើដាក់ទណ្ឌកម្មខាងវិន័យថ្នាក់ទី២ទៅមន្ទីរអប់រំ យុវជន និងកីឡា។ |
| | ២. ការគ្រប់គ្រងសិស្សមត្តេយ្យសិក្សា<br>– ជំរុញ សម្របសម្រួល ណែនាំ គាំទ្រ និងបូកសរុបការងារពាក់ព័ន្ធនឹងការធ្វើយុទ្ធនាការប្រមូលសិស្សចូលរៀន ការរៀបចំស្រង់ស្ថិតិសិស្ស ការរៀបចំផែនទីខ្នងផ្ទះ និងការតាមដានវត្តមានសិស្ស<br>– ណែនាំលើការរៀបចំសិស្ស និងគ្រូតាមថ្នាក់ស្របតាមនិយាម<br>– រៀបចំ បូកសរុប និងគ្រប់គ្រងទិន្នន័យសិស្សជាប់ ធ្លាក់ សិស្សបោះបង់ សិស្សក្រីក្រ សិស្សជួបការលំបាក សិស្សពិការភាព និងសិស្សឆ្លងភូមិសិក្សាក្នុងដែនសមត្ថកិច្ច។ |

NASLA

| | |
|---|---|
| | ៣. ការរៀបចំផែនការ<br>– ពិនិត្យ និងឯកភាពលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន )៥ឆ្នាំ និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននីមួយៗ ( រួចបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននីមួយៗ។ |
| | ៤. ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ<br>– ជំរុញ សម្របសម្រួល គាំទ្រ និងផ្ទៀងផ្ទាត់ការរៀបចំផែនការថវិការបស់សាលារៀន<br>– ពិនិត្យ តាមដានការអនុវត្តថវិការបស់សាលារៀន<br>– ពិនិត្យ បូកសរុបរបាយការណ៍ហិរញ្ញវត្ថុរបស់សាលារៀន<br>– ពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជូនបញ្ជីសារពើភ័ណ្ឌរបស់សាលារៀនទៅមន្ទីរអប់រំ យុវជន និងកីឡា។ |
| | ៥. ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានា<br>– រៀបចំបញ្ជីសម្រង់ឈ្មោះសាលាមត្តេយ្យសិក្សា<br>– ប្រមូល និងបូកសរុបបញ្ជីតម្រូវការសាងសង់ និងជួសជុលសាលារៀន<br>– លើកសំណើសាងសង់ និងជួសជុលធំ ផ្អែកតាមតម្រូវការរបស់សាលារៀន<br>– សម្របសម្រួល គាំទ្រ និងត្រួតពិនិត្យលើការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំមត្តេយ្យសិក្សា។ |
| | ៦. ការគ្រប់គ្រងកម្មវិធីមត្តេយ្យសិក្សារដ្ឋ<br>– លើកសំណើសុំពង្រីកសាលា/ថ្នាក់មត្តេយ្យសិក្សា<br>– ជំរុញ សម្របសម្រួល តាមដាន និងគាំទ្រកម្មវិធីមត្តេយ្យសិក្សារដ្ឋ<br>– រៀបចំបូកសរុបរបាយការណ៍ស្តីពីកម្មវិធីមត្តេយ្យសិក្សារដ្ឋ។ |
| | ៧. ការគ្រប់គ្រងកម្មវិធីមត្តេយ្យសិក្សាឯកជន<br>– ជំរុញ សម្របសម្រួល តាមដាន និងគាំទ្រកម្មវិធីមត្តេយ្យសិក្សាឯកជន |

NASLA

| | |
|---|---|
| | – ពិនិត្យ និងសម្រេចលើការស្នើសុំអាជ្ញាប័ណ្ណសម្រាប់ការបើក ការបន្តសុពលភាព ការផ្អាកជាបណ្ដោះអាសន្ន និងការដកហូតអាជ្ញាប័ណ្ណសាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជនកម្មវិធីសិក្សាជាតិ និងកម្មវិធីសិក្សាអន្តរជាតិ<br>– ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្ត ក្របខ័ណ្ឌច្បាប់របស់សាលាមត្តេយ្យសិក្សាឯកជន<br>– រៀបចំបូកសរុបរបាយការណ៍ស្ដីពីកម្មវិធីមត្តេយ្យសិក្សាឯកជន។ |
| | ៨. ការគ្រប់គ្រងកម្មវិធីអប់រំបញ្ចូលគ្នា និងកម្មវិធីពហុភាសា (សម្រាប់រដ្ឋបាលស្រុកដែលមានជនជាតិដើមភាគតិច)<br>– សម្របសម្រួលក្នុងការបង្កើតឱ្យមានកម្មវិធីពហុភាសា និងស្វែងរកគ្រូបង្រៀនសម្រាប់ជនជាតិដើមភាគតិច<br>– សម្របសម្រួលក្នុងការបង្កើតឱ្យមានកម្មវិធីអប់រំបញ្ចូលគ្នាកម្រិតមត្តេយ្យសិក្សា<br>– តាមដាន និងគាំទ្រការអនុវត្តកម្មវិធីពហុភាសា និងកម្មវិធីអប់រំបញ្ចូលគ្នា។ |
| | ៩. ការគ្រប់គ្រងកម្មវិធីអាហារូបត្ថម្ភ<br>– ប្រមូល និងបូកសរុបសំណើសុំស្បៀងសម្រាប់កម្មវិធីអាហារូបត្ថម្ភតាមសាលារៀន<br>– ពិនិត្យ និងតាមដានការអនុវត្តកម្មវិធីអាហារូបត្ថម្ភតាមសាលារៀន<br>– កៀរគរអ្នកពាក់ព័ន្ធនានាដើម្បីគាំទ្រកម្មវិធីអាហារូបត្ថម្ភតាមសាលារៀន។ |
| | ១០. ការគ្រប់គ្រងកម្មវិធីជួយកុមារក្រីក្រតាមសាលា<br>– សម្របសម្រួល តាមដាន និងគាំទ្រកម្មវិធីជួយកុមារក្រីក្រតាមសាលារៀន<br>– ប្រមូលទិន្នន័យ និងបូកសរុបរបាយការណ៍អំពីការអនុវត្តកម្មវិធីជួយកុមារក្រីក្រតាមសាលារៀន<br>– កៀរគរការគាំទ្រពីអ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្តកម្មវិធីជួយកុមារក្រីក្រតាមសាលារៀន។ |
| | ១១. ការគ្រប់គ្រងកម្មវិធីអប់រំមាតា បិតាផ្សារភ្ជាប់នឹងកម្មវិធីមត្តេយ្យសិក្សារដ្ឋ និងកម្មវិធីមត្តេយ្យសិក្សាសហគមន៍ |

NASLA

| | |
|---|---|
| | – សម្របសម្រួល និងគាំទ្រការអនុវត្តកម្មវិធីអប់រំមាតា បិតាផ្សារភ្ជាប់នឹងកម្មវិធីមត្តេយ្យសិក្សារដ្ឋ និងកម្មវិធីមត្តេយ្យសិក្សាសហគមន៍។ |
| ២. ការគ្រប់គ្រងការអប់រំបឋមសិក្សា | – ១. ការគ្រប់គ្រងបុគ្គលិកអប់រំបឋមសិក្សា<br>– ពិនិត្យ និងផ្តល់យោបល់លើការផ្ទេរបុគ្គលិកបឋមសិក្សាក្នុងខេត្ត និងឆ្លងខេត្ត តម្រូវការគ្រូបឋមសិក្សា ការដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ការផ្តល់មេដាយ ប័ណ្ណសរសើរ និងការលើកទឹកចិត្តផ្សេងទៀតដល់បុគ្គលិកអប់រំ<br>– ពិនិត្យសម្រេចលើការផ្លាស់ប្តូរគ្រូបឋមសិក្សានៅក្នុងស្រុក<br>– លើកសំណើតែងតាំង ផ្លាស់ប្តូរ និងបញ្ចប់ភារកិច្ចមុខតំណែងគណៈគ្រប់គ្រងសាលា<br>– ពិនិត្យ សម្រេចលើការស្នើសុំច្បាប់ឈប់សម្រាកគ្រប់ប្រភេទតាមគោលការណ៍កំណត់ ដល់គណៈគ្រប់គ្រងសាលា និងបុគ្គលិកអប់រំ<br>– គ្រប់គ្រងបុគ្គលិកអប់រំតាមប្រព័ន្ធព័ត៌មានវិទ្យា<br>– ផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធនឹងការគ្រប់គ្រងការអប់រំបឋមសិក្សានៅតាមសាលារៀន<br>– ត្រួតពិនិត្យលើការគ្រប់គ្រងវត្តមាន និងសម្រេចដាក់ទណ្ឌកម្មខាងវិន័យថ្នាក់ទី១<br>– ពិនិត្យ ផ្តល់យោបល់ និងលើកសំណើដាក់ទណ្ឌកម្មខាងវិន័យថ្នាក់ទី២ទៅមន្ទីរអប់រំ យុវជន និងកីឡា។ |
| | ២. ការគ្រប់គ្រងគ្រូបង្រៀនបឋមសិក្សាជាប់កិច្ចសន្យា<br>– ពិនិត្យ និងផ្តល់យោបល់លើតម្រូវការគ្រូបឋមសិក្សាជាប់កិច្ចសន្យា និងសំណើសុំក្របខ័ណ្ឌគ្រូបឋមសិក្សាជាប់កិច្ចសន្យា<br>– រៀបចំ និងសម្រេចលើការជ្រើសរើស និងការបញ្ចប់កិច្ចសន្យាគ្រូបឋមសិក្សាជាប់កិច្ចសន្យា<br>– ពិនិត្យ និងសម្រេចលើការស្នើសុំច្បាប់ឈប់សម្រាកគ្រប់ប្រភេទតាមគោលការណ៍កំណត់<br>– រៀបចំ តាមដាន គាំទ្រ និងបំប៉នគ្រូបឋមសិក្សាជាប់កិច្ចសន្យា។ |

NASLA

| | |
|---|---|
| | ៣. ការគ្រប់គ្រងសិស្ស<br>– ជំរុញ សម្របសម្រួល ណែនាំ គាំទ្រ និងបូកសរុបការងារពាក់ព័ន្ធនឹងការធ្វើយុទ្ធនាការប្រមូលកុមារចូលរៀន ការរៀបចំស្រង់ស្ថិតិសិស្ស ការរៀបចំផែនទីខ្នងផ្ទះ និងការតាមដានវត្តមានសិស្ស<br>– ណែនាំលើការរៀបចំសិស្ស និងគ្រូតាមថ្នាក់ស្របតាមនិយាម<br>– រៀបចំ បូកសរុប និងគ្រប់គ្រងទិន្នន័យសិស្សជាប់មធ្យមភាគ ធ្លាក់មធ្យមភាគ សិស្សបោះបង់ការសិក្សា សិស្សក្រីក្រ សិស្សជួបការលំបាក សិស្សមានពិការភាព និងសិស្សឆ្លងភូមិសិក្សាក្នុងដែនសមត្ថកិច្ច។ |
| | ៤ .ការរៀបចំផែនការ<br>– ពិនិត្យ និងឯកភាពលើផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន (០៥ឆ្នាំ)និងផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននីមួយៗ រួចបញ្ជូនទៅ មន្ទីរអប់រំ យុវជន និងកីឡា<br>– ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំរបស់សាលារៀននីមួយៗ។ |
| | ៥. ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ<br>– ជំរុញ សម្របសម្រួល គាំទ្រ និងផ្ទៀងផ្ទាត់ការរៀបចំផែនការថវិការបស់សាលារៀន<br>– ពិនិត្យ តាមដានការអនុវត្តថវិការបស់សាលារៀន<br>– ពិនិត្យ និងបូកសរុបរបាយការណ៍ហិរញ្ញវត្ថុរបស់សាលារៀន<br>– ពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជូនបញ្ជីសារពើភណ្ឌសាលារៀនទៅមន្ទីរអប់រំ យុវជន និងកីឡា។ |
| | ៦. ការផ្គត់ផ្គង់សៀវភៅសិក្សាគោល<br>– ប្រមូល បូកសរុប និងបញ្ជូនតម្រូវការសៀវភៅសិក្សាគោលរបស់សាលារៀនទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– សម្របសម្រួលបែងចែកសៀវភៅសិក្សាគោលទៅសាលារៀន<br>– ពិនិត្យលើការប្រើប្រាស់ និងការថែទាំសៀវភៅសិក្សាគោលតាមសាលារៀន។ |
| | ៧. ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានា<br>– រៀបចំបញ្ជីសម្រង់ឈ្មោះសាលារៀនបឋមសិក្សា |

NASLA

| | |
|---|---|
| | – ប្រមូល និងបូកសរុបបញ្ជីតម្រូវការសាងសង់ និងជួសជុលសាលារៀន<br>– លើកសំណើសាងសង់ និងជួសជុលធំ ផ្អែកតាមតម្រូវការរបស់សាលារៀន<br>– សម្របសម្រួល គាំទ្រ និងត្រួតពិនិត្យលើការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានានៃការអប់រំបឋមសិក្សា។ |
| | ៨. ការគ្រប់គ្រងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន<br>– ជំរុញ គាំទ្រ និងពិនិត្យ សម្រេចលើការបង្កើតគណៈកម្មការគ្រប់គ្រងសាលារៀន<br>– តាមដាន និងគាំទ្រកិច្ចដំណើរការរបស់គណៈកម្មការគ្រប់គ្រងសាលារៀន។ |
| | ៩. ការគ្រប់គ្រងគណៈកម្មការអភិវឌ្ឍកម្រងសាលារៀន<br>– ដឹកនាំ សម្របសម្រួលការរៀបចំបង្កើត និងលុបកម្រងសាលារៀន<br>– ដឹកនាំការរៀបចំ និងបោះឆ្នោតជ្រើសរើសប្រធានកម្រង<br>– តាមដាន និងគាំទ្រលើការអនុវត្តតួនាទីរបស់គណៈកម្មការអភិវឌ្ឍកម្រងសាលារៀន<br>– ត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលសិក្សាក្នុងកម្រងសាលារៀន<br>– រៀបចំ និងត្រួតពិនិត្យការប្រឡងប្រណាំង រវាងកម្រង និងកម្រង និងរវាងសាលារៀន និងសាលារៀន។ |
| | ១០. ការផ្តល់អាជ្ញាប័ណ្ណ<br>– ពិនិត្យ និងផ្តល់យោបល់លើការស្នើសុំអាជ្ញាប័ណ្ណសម្រាប់ការបើក ការបន្តសុពលភាព ការផ្អាកជាបណ្តោះអាសន្ន និងការដកហូតអាជ្ញាប័ណ្ណសាលាបឋមសិក្សាឯកជន<br>– ពិនិត្យ តាមដាន វាយតម្លៃលើការអនុវត្តក្របខ័ណ្ឌច្បាប់ និងកិច្ចដំណើរការរបស់សាលាបឋមសិក្សាឯកជន។ |
| | ១១. ការគ្រប់គ្រងកម្មវិធីសាលាកុមារមេត្រី<br>– ជំរុញ សម្របសម្រួល និងគាំទ្រដល់សាលារៀនក្នុងការអនុវត្តកម្មវិធីសាលាកុមារមេត្រី<br>– គ្រប់គ្រង និងគាំទ្រក្រុមបំប៉ន និងពិនិត្យតាមដានថ្នាក់ស្រុក។ |

NASLA

| | |
|---|---|
| | ១២. ការគ្រប់គ្រងកម្មវិធីពហុភាសា (សម្រាប់ស្រុកដែលមានជនជាតិដើម ភាគតិច)<br>– សម្របសម្រួលក្នុងការបង្កើតឱ្យមានកម្មវិធីពហុភាសា និងការស្វែងរកគ្រូបង្រៀនសម្រាប់ជនជាតិដើមភាគតិច<br>– តាមដាន និងគាំទ្រការអនុវត្តកម្មវិធីពហុភាសា។ |
| | ១៣. ការគ្រប់គ្រងកម្មវិធីពន្លឿនការសិក្សា<br>– សម្របសម្រួលជាមួយសាលារៀន ដើម្បីប្រមូល និងគ្រប់គ្រងស្ថិតិសិស្ស ឬកុមារឱ្យចូលរៀន និងការរៀបចំថ្នាក់សម្រាប់សិស្ស<br>– តាមដាន និងគាំទ្រកម្មវិធីពន្លឿនការសិក្សា។ |
| | ១៤. ការគ្រប់គ្រងកម្មវិធីស្បៀងអាហារតាមសាលារៀន<br>– ប្រមូល និងបូកសរុបសំណើសុំស្បៀងសម្រាប់កម្មវិធីស្បៀងអាហារតាមសាលារៀន<br>– ពិនិត្យ និងតាមដានការអនុវត្តកម្មវិធីស្បៀងអាហារតាមសាលារៀន<br>– កៀរគរអ្នកពាក់ព័ន្ធនានា ដើម្បីគាំទ្រកម្មវិធីស្បៀងអាហារតាមសាលារៀន។ |
| | ១៥. ការគ្រប់គ្រងកម្មវិធីអប់រំពិសេស<br>– សម្របសម្រួល និងគាំទ្រកិច្ចដំណើរការអនុវត្តកម្មវិធីអប់រំពិសេស<br>– ប្រមូល និងបូកសរុបរបាយការណ៍អំពីកម្មវិធីអប់រំពិសេស។ |
| | ១៦. ការគ្រប់គ្រងកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ<br>– កំណត់អត្តសញ្ញាណសិស្សក្រីក្រ និងលើកសំណើសុំអាហារូបករណ៍ទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– សម្របសម្រួល តាមដាន និងគាំទ្រកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ<br>– ប្រមូល និងបូកសរុបរបាយការណ៍អំពីកម្មវិធីអាហារូបករណ៍សិស្សក្រីក្រ។ |
| | ១៧. ការគ្រប់គ្រងកម្មវិធីអប់រំសុខភាព និងអនាម័យ<br>– សម្របសម្រួល តាមដាន និងគាំទ្រការអនុវត្តកម្មវិធីអប់រំសុខភាព អនាម័យ និងសុវត្ថិភាព<br>– ប្រមូល និងបូកសរុបរបាយការណ៍អំពីកម្មវិធីអប់រំសុខភាព អនាម័យ និងសុវត្ថិភាព។ |

NASLA

| | |
|---|---|
| ៣. ការគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ | ១. ការគ្រប់គ្រងបុគ្គលិក<br>– ជ្រើសរើស និងចាត់តាំងគ្រូបង្គោល (គ្រូបង្គោល០១នាក់ក្នុងមួយឃុំ សង្កាត់ ជាគ្រូក្របខ័ណ្ឌដែលជ្រើសរើសចេញពីក្របខ័ណ្ឌគ្រូបឋមសិក្សា ឬគ្រូអនុវិទ្យាល័យ)<br>– សម្របសម្រួល និងជំរុញលើការងារអប់រំក្រៅប្រព័ន្ធ។ |
| | ២. ការជ្រើសរើស និងការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យា<br>– លើកសំណើអំពីតម្រូវការគ្រូជាប់កិច្ចសន្យាជូនមន្ទីរអប់រំ យុវជន និងកីឡា<br>– រៀបចំ និងសម្រេចលើការជ្រើសរើស និងបញ្ចប់កិច្ចសន្យាគ្រូជាប់កិច្ចសន្យា (អក្ខរកម្ម កម្មវិធីចូលរៀនឡើងវិញ និងគ្រូមជ្ឈមណ្ឌលសិក្សាសហគមន៍ គ្រូកម្មវិធីសមមូលបឋម)<br>– ធ្វើសំណើប្រើប្រាស់គ្រូជាប់កិច្ចសន្យា ដោយភ្ជាប់មកជាមួយនូវស្វ័យប្រកាស ប្រវត្តិរូបគ្រូកិច្ចសន្យា លេខគណនីធនាគារ ស្របតាមគោលការណ៍ណែនាំ<br>– ពិនិត្យ និងសម្រេចលើការស្នើសុំច្បាប់ឈប់សម្រាកគ្រប់ប្រភេទតាមគោលការណ៍កំណត់<br>– រៀបចំ តាមដាន គាំទ្រ និងបំប៉នដល់គ្រូជាប់កិច្ចសន្យា។ |
| | ៣. ការប្រមូល ការគ្រប់គ្រងសិស្ស អ្នកសិក្សា និងអ្នកចូលរួម<br>– បូកសរុបស្ថិតិអនក្ខរជន និងសិស្សបោះបង់ចោលការសិក្សាបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– ជំរុញ សម្របសម្រួល ណែនាំ គាំទ្រ និងបូកសរុបការងារពាក់ព័ន្ធការធ្វើយុទ្ធនាការប្រមូលសិស្សចូលរៀនកម្មវិធីអប់រំក្រៅប្រព័ន្ធ<br>– រៀបចំសិស្ស និងគ្រូតាមថ្នាក់ស្របតាមនិយាម<br>– ចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សាៈ កម្មវិធីអក្ខរកម្ម កម្មវិធីចូលរៀនឡើងវិញ និងកម្មវិធីបង្កើនប្រាក់ចំណូល<br>– ពិនិត្យ និងបូកសរុបបញ្ជីវត្តមាន លទ្ធផលធ្វើតេស្ត លទ្ធផលប្រឡង និងរៀបចំរបាយការណ៍ពាក់ព័ន្ធនឹងកម្មវិធីការអប់រំក្រៅប្រព័ន្ធតាមគោលការណ៍កំណត់។ |
| | ៤. ការរៀបចំផែនការសកម្មភាព<br>– រៀបចំ និង/ឬពិនិត្យ និងសម្រេចលើផែនការសម្រាប់អភិវឌ្ឍន៍ការអប់រំក្រៅប្រព័ន្ធ (៥ឆ្នាំ) រួចបញ្ជូនទៅមន្ទីរអប់រំ យុវជន និងកីឡា ដើម្បីផ្តល់ការគាំទ្រថវិកា និងបច្ចេកទេស |

NASLA

| | |
|---|---|
| | – ពិនិត្យ និងសម្រេចលើការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំរបស់កម្មវិធីអប់រំក្រៅប្រព័ន្ធ។ |
| | ៥. ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ<br>– ជំរុញ សម្របសម្រួល គាំទ្រ និងផ្ទៀងផ្ទាត់ការរៀបចំផែនការថវិកាសម្រាប់ដំណើរការមជ្ឈមណ្ឌលសិក្សាសហគមន៍<br>– ពិនិត្យផ្ទៀងផ្ទាត់ និងបញ្ជូនបញ្ជីសារពើភណ្ឌរបស់មជ្ឈមណ្ឌលសិក្សាសហគមន៍ទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– រៀបចំ គ្រប់គ្រង និងកៀរគរមូលនិធិសម្រាប់ដំណើរការកម្មវិធីអប់រំក្រៅប្រព័ន្ធ<br>– រៀបចំសម្របសម្រួលបង្កើត និងគាំទ្រមជ្ឈមណ្ឌលសិក្សាសហគមន៍។ |
| | ៦ការផ្តល់អាជ្ញាប័ណ្ណ .<br>– ពិនិត្យ និងសម្រេចលើការស្នើសុំអាជ្ញាប័ណ្ណសម្រាប់ការបើក ការបន្តសុពលភាព ការផ្អាកជាបណ្តោះអាសន្ន និងការដកហូតអាជ្ញាប័ណ្ណថ្នាក់បណ្តុះបណ្តាលជំនាញ មុខរបរ និងភាសាបរទេសរយៈពេលតិចជាង០១ឆ្នាំ<br>– ពិនិត្យ តាមដាន និងវាយតម្លៃលើការអនុវត្តក្របខ័ណ្ឌច្បាប់។ |
| | ៧. ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានា<br>– រៀបចំបញ្ជីសម្រង់ឈ្មោះមជ្ឈមណ្ឌលសិក្សាសហគមន៍<br>– ប្រមូល និងបូកសរុបបញ្ជីតម្រូវការសាងសង់ និងជួសជុលមជ្ឈមណ្ឌលសិក្សាសហគមន៍<br>– លើកសំណើសាងសង់ និងជួសជុលធំសម្រាប់មជ្ឈមណ្ឌលសិក្សាសហគមន៍<br>– សម្របសម្រួល គាំទ្រ និងត្រួតពិនិត្យលើការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំ ហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានា។ |
| | ៨. ការគ្រប់គ្រងកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ<br>– សម្របសម្រួលក្នុងការបង្កើតកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ និងស្វែងរកគ្រូបង្រៀន |

NASLA

| | |
|---|---|
| | – តាមដាន និងគាំទ្រការអនុវត្តកម្មវិធីអក្ខរកម្មវិជ្ជាជីវៈពិនិត្យ និងបូកសរុបរបាយការណ៍កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ។ |
| | ៩. ការគ្រប់គ្រងកម្មវិធីក្រោយអក្ខរកម្ម<br>– សម្របសម្រួល តាមដាន និងគាំទ្រការបង្កើតបណ្ណាល័យ និងមណ្ឌលអាន។ |
| | ១០. ការគ្រប់គ្រងកម្មវិធីសមមូលបឋមសិក្សា និងបំពេញវិជ្ជា<br>– សម្របសម្រួលក្នុងការបង្កើតកម្មវិធីសមមូលបឋមសិក្សា និងបំពេញវិជ្ជា<br>– តាមដាន បូកសរុប និងគាំទ្រការអនុវត្តកម្មវិធីសមមូលបឋមសិក្សា និងបំពេញវិជ្ជា។ |
| | ១១. ការគ្រប់គ្រងកម្មវិធីបង្កើនប្រាក់ចំណូល<br>– សម្របសម្រួលក្នុងការបង្កើតកម្មវិធីបង្កើនប្រាក់ចំណូល<br>– តាមដាន និងគាំទ្រការអនុវត្តកម្មវិធីបង្កើនប្រាក់ចំណូល។ |
| | ១២. ការគ្រប់គ្រងកម្មវិធីចូលរៀនឡើងវិញ<br>– ប្រមូលទិន្នន័យ សម្របសម្រួល និងបង្កើតថ្នាក់ចូលរៀនឡើងវិញនៅតាមសាលាបឋមសិក្សា និងធ្វើសមាហរណកម្មសិស្សដែលរៀនចប់ដោយជោគជ័យចូលទៅក្នុងប្រព័ន្ធអប់រំចំណេះទូទៅ<br>– តាមដាន និងគាំទ្រការអនុវត្តកម្មវិធីចូលរៀនឡើងវិញនៅតាមសាលាបឋមសិក្សា។ |
| ៤. ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ | ១. ការងាររដ្ឋបាល<br>– ផ្សព្វផ្សាយគោលការណ៍ណែនាំ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយដល់សាលារៀន<br>– ណែនាំសាលារៀនក្នុងការរៀបចំ និងគ្រប់គ្រងសៀវភៅកត់ត្រាលិខិតចេញ ចូល វត្តមានបុគ្គលិក និងសៀវភៅ រដ្ឋបាលផ្សេងៗទៀត<br>– ផ្តល់យោបល់ និងគាំទ្រការរៀបចំការងារបរិស្ថាន ប្លង់សាលារៀន ការងារអនាម័យនៅតាមសាលារៀន<br>– គ្រប់គ្រងស្ថិតិគ្រូ និងសិស្សតាមសាលាមធ្យមសិក្សា<br>– ជំរុញការប្រឡងប្រណាំងសាលារៀនស្អាត នាយកល្អ គ្រូបង្រៀនល្អ |

NASLA

| | |
|---|---|
| | – រៀបចំលិខិតចាត់តាំង និងត្រួតពិនិត្យលើការចាត់តាំងគ្រូចេញថ្មី គ្រូផ្ទេរចូលទៅបម្រើការងារនៅសាលារៀនផ្អែកតាមលិខិតឧទ្ទេសនាមរបស់មន្ទីរអប់រំ យុវជន និងកីឡា<br>– ពិនិត្យតាមដានការបំពេញការងាររបស់គ្រូបង្រៀន<br>– បូកសរុបរបាយការណ៍នៅតាមសាលាមធ្យមសិក្សាតាមគោលការណ៍កំណត់<br>– ត្រួតពិនិត្យមើលការងារប្រឡងធមាស<br>– សម្របសម្រួល និងគាំទ្រដល់សាលាមធ្យមសិក្សា។ |
| | – ២. ការគ្រប់គ្រងបុគ្គលិក<br>– លើកសំណើតែងតាំង និងបញ្ចប់មុខតំណែងគណៈគ្រប់គ្រងសាលា<br>– ពិនិត្យ វាយតម្លៃ និងលើកសំណើដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ផ្តល់មេដាយ ប័ណ្ណសរសើរ និងការលើកទឹកចិត្តផ្សេងទៀត គ្រូល្អនាយកល្អ មកមន្ទីរអប់រំ យុវជន និងកីឡា<br>– ពិនិត្យ និងបញ្ជូនសំណើលំហែមាតុភាព ចូលនិវត្តន៍ ឈប់ពីការងារ ផ្លាស់ប្តូរទីកន្លែងបម្រើការងារ សម្រាកព្យាបាលជំងឺ ទំនេរគ្មានបៀវត្ស គ្រោះថ្នាក់ក្នុងពេលបម្រើការងារ  មរណភាព សុំច្បាប់ឈប់សម្រាកចាប់ពី៧(ប្រាំពីរ)ថ្ងៃទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– ពិនិត្យ និងអនុញ្ញាតច្បាប់ឈប់សម្រាកក្រោម៧ថ្ងៃ<br>– ប្រមូលបូកសរុបតម្រូវការគ្រូ និងធ្វើសំណើមកមន្ទីរអប់រំ យុវជន និងកីឡា<br>– ពិនិត្យសំណើ និងផ្តល់យោបល់លើការដាក់ទណ្ឌកម្មខាងវិន័យរដ្ឋបាលដល់បុគ្គលិកអប់រំមធ្យមសិក្សា<br>– គ្រប់គ្រងទិន្នន័យបុគ្គលិកមធ្យមសិក្សា និងធ្វើរបាយការណ៍អំពីស្ថានភាពបុគ្គលិកទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– ពិនិត្យតាមដានការបំពេញការងាររបស់គ្រូបង្រៀន<br>– ពិនិត្យ និងផ្ទៀងផ្ទាត់លើតារាងប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ។ |
| | ៣. ការងារផែនការ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ<br>– ណែនាំសាលារៀនធ្វើផែនការអភិវឌ្ឍសាលារៀន និងផែនការថវិកា |

| | |
|---|---|
| | – ពិនិត្យ និងបូកសរុបផែនការប្រតិបត្តិរបស់សាលារៀនទូទាំងស្រុកជូនមន្ទីរអប់រំ យុវជន និងកីឡា<br>– ណែនាំអំពីនីតិវិធី ឬគោលការណ៍នៃការប្រើប្រាស់ថវិកា (មាតិកាចំណាយ កិច្ចបញ្ជិកា នីតិវិធីទូទាត់... )<br>– ពិនិត្យតាមដានការប្រើប្រាស់ថវិកាដំណើរការសាលារៀន<br>– ប្រមូល និងធ្វើរបាយការណ៍សមិទ្ធកម្មតាមគោលការណ៍កំណត់<br>– បែងចែក និងប្រជុំផ្សព្វផ្សាយតារាងថវិកាតាមជំហាននីមួយៗផ្អែកលើតារាងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា<br>– រៀបចំសំណើសុំប្រាក់អាហារូបករណ៍សិស្សក្រីក្រទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– បូកសរុបរបាយការណ៍ចំណូល-ចំណាយរបស់សាលារៀនជូនមន្ទីរអប់រំ យុវជន និងកីឡា<br>– ពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជូនបញ្ជីសារពើភណ្ឌសាលារៀនជូនទៅមន្ទីរអប់រំ យុវជន និងកីឡា។ |
| ៥. ការអភិវឌ្ឍយុវជន | ១. ការអភិវឌ្ឍយុវជន<br>– ផ្សព្វផ្សាយគោលការណ៍ណែនាំ ច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធនឹងការអភិវឌ្ឍយុវជន<br>– ត្រួតពិនិត្យ ណែនាំ និងជំរុញសាលារៀនឱ្យរៀបចំបង្កើត និងដំណើរការក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សា យុវជនកម្ពុជា<br>– ផ្តល់ការណែនាំអំពីតួនាទី ភារកិច្ចរបស់នាយកសាលា គ្រូបង្រៀន និងសិស្សដែលទទួលបន្ទុកការងារក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា<br>– កៀរគរ សម្របសម្រួល និងសហការជាមួយដៃគូដើម្បីបណ្តុះបណ្តាលជំនាញ និងបំណិនផ្សេងៗដល់សមាជិកក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា<br>– ដោះស្រាយបញ្ហានានាពាក់ព័ន្ធយុវជន កុមារតាមសាលារៀនដូចជា៖ ការបោះបង់ អវត្តមាន ការពាក់ព័ន្ធគ្រឿងញៀន<br>– ប្រមូល និងគ្រប់គ្រងទិន្នន័យក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា ដើម្បីបូកសរុបការងារ និងចងក្រងឯកសាររបាយការណ៍តាមគោលការណ៍កំណត់<br>– សម្របសម្រួល និងដឹកនាំសិស្សចូលរួមសកម្មភាពផ្លាស់ប្តូរ |

NASLA

| | |
|---|---|
| | បទពិសោធន៍ ទាំងកម្រិតជាតិ និងអន្តរជាតិ<br>– ជំរុញសាលារៀនឱ្យបង្កើតក្លឹបសិក្សាសម្រាប់ក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា<br>– ប្រមូលតម្រូវការអភិវឌ្ឍយុវជនក្នុងសហគមន៍ និងធ្វើសំណើទៅមន្ទីរអប់រំ យុវជន និងកីឡា។ |
| ៦. ការងារអប់រំកាយ និងកីឡា | ១ .ការងារអប់រំកាយ និងកីឡា<br>– ជំរុញការអនុវត្តការងារអប់រំកាយក្នុងម៉ោងសិក្សា និងការងារកីឡាក្រៅម៉ោងសិក្សាតាមគ្រឹះស្ថានសិក្សា<br>– រៀបចំ និងអនុវត្តការហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពរបស់មហាជនតាមសហគមន៍<br>– ជំរុញ សម្របសម្រួល និងសហការរៀបចំសម្ភារ ជួសជុលទីលានកីឡាតាមសាលារៀន និងសហគមន៍<br>– ជំរុញ និងសហការឱ្យយុវជនលេងកីឡាមួយប្រភេទយ៉ាងតិចក្នុងសាលារៀន និងសហគមន៍<br>– ផ្សព្វផ្សាយ និងណែនាំអំពីគោលការណ៍ លិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធនឹងការងារអប់រំកាយ និងកីឡា<br>– ប្រមូល និងរៀបចំស្ថិតិទីលានកីឡា ក្លឹបកីឡា មន្ត្រីជំនាញ កីឡាករ កីឡាការិនី មហាជនហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាព កីឡាពាក់កណ្តាលអាជីព និងកីឡាអាជីព<br>– ជំរុញ និងសហការរៀបចំប្រកួតកីឡានៅតាមសាលារៀនថ្នាក់ស្រុក និងចូលរួមប្រកួតថ្នាក់ខេត្ត និងថ្នាក់ជាតិ<br>– ប្រមូលតម្រូវការគ្រូអប់រំកាយ និងគ្រូកីឡាជំនាញ និងធ្វើសំណើទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– កៀរគរស្វែងរកមូលនិធិអភិវឌ្ឍកីឡាពីអ្នកពាក់ព័ន្ធនានា<br>– តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍ការងារអប់រំកាយ និងកីឡានៅតាមសាលារៀន និងសហគមន៍តាមគោលការណ៍កំណត់<br>– ពិនិត្យ និងសម្រេចលើការស្នើសុំអាជ្ញាប័ណ្ណសម្រាប់ការបើក ការបន្តសុពលភាព ក្លឹបហាត់ប្រាណ និងអាជីវកម្មលក់សម្ភារកីឡា។ |

NASLA

**ឧបសម្ព័ន្ធទី២ក ៖ មុខងារ និងមុខងាររងពាក់ព័ន្ធការិយាល័យអប់រំ យុវជន និងកីឡាដែលប្រគល់ និងធ្វើប្រតិភូកម្មទៅឱ្យរដ្ឋបាលស្រុកនៃខេត្តបាត់ដំបង**

| មុខងារ | មុខងាររង/សកម្មភាព |
| --- | --- |
| **មុខងារដែលប្រគល់** | |
| ១. ការគ្រប់គ្រងការអប់រំកុមារតូច | ១. ការគ្រប់គ្រងបុគ្គលិកអប់រំ<br>– អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| | ២. ការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យា<br>– អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| | ៣. ការគ្រប់គ្រងសិស្ស<br>– គ្រប់គ្រងទិន្នន័យកុមារអាយុ០៣ឆ្នាំដល់ក្រោម០៦ឆ្នាំ<br>– រៀបចំផែនទីសិក្សាសម្រាប់ការអប់រំកុមារតូច<br>– រៀបចំសិស្សទៅតាមនិយាម និងតាមកម្រិតអាយុ<br>– ពិនិត្យសុខភាព និងអនាម័យស្របតាមស្តង់ដាអប្បបរមាផ្នែកសុខភាពសិក្សា<br>– តាមដាន និងទំនាក់ទំនងជាមួយឪពុកម្តាយ អ្នកអាណាព្យាបាលកុមារ<br>– តាមដានលទ្ធផលការអភិវឌ្ឍកុមារតូច |
| | ៤. ការរៀបចំផែនការ<br>– ដាក់បញ្ចូលផែនការអប់រំកុមារតូចទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលស្រុក<br>– រៀបចំផែនការផ្អែកលើលទ្ធផលស្តីពីការគាំពារ និងអភិវឌ្ឍកុមារតូច |
| | ៥. ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ<br>– លើកគម្រោងផែនការយុទ្ធសាស្ត្ររយៈពេលខ្លី មធ្យម និងរយៈពេលវែង<br>– លើកគម្រោងផែនការថវិកាប្រចាំឆ្នាំ<br>– គ្រប់គ្រងកិច្ចបញ្ជិការគណនេយ្យ<br>– រៀបចំបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំរបស់សាលារៀន |



NASLA

| | |
|---|---|
| | – រៀបចំបញ្ជីសារពើភ័ណ្ឌគោលសម្រាប់រយៈពេល៥ឆ្នាំរបស់រដ្ឋបាលស្រុក<br>– រៀបចំបញ្ជីតាមដានសម្ភារ បរិក្ខារក្នុងអង្គភាពឱ្យបានចំនួន២ដងក្នុងមួយឆ្នាំ<br>– រៀបចំតារាងតាមដានការកើនឡើង ថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ<br>– រៀបចំកិច្ចបញ្ជិកាសម្ភារតាមនីតិវិធីឃ្លាំង<br>– លើកគម្រោងតម្រូវការសម្ភារប្រចាំឆ្នាំ |
| | ៦. ការគ្រប់គ្រងទំនិញ សំណង់ អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានា<br>– ធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំ<br>– ធ្វើផែនការកែតម្រូវប្រចាំឆ្នាំ<br>– ធ្វើរបាយការណ៍ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ និងបញ្ជូនមកតាមមុខសញ្ញាពាក់ព័ន្ធ |
| | ៧. ការផ្តល់អាជ្ញាប័ណ្ណសម្រាប់បើក បន្តសុពលភាព ផ្អាកជាបណ្តោះអាសន្ន និងដកហូតអាជ្ញាប័ណ្ណ សាលា ឬថ្នាក់មត្តេយ្យសិក្សាឯកជន កម្មវិធីសិក្សាជាតិ និងកម្មវិធីសិក្សាអន្តរជាតិ<br>– អនុលោមសេចក្តីណែនាំលេខ១៩ អយក.សសន ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ របស់ក្រសួងអប់រំ យុវជន និងកីឡា |
| | ៨. ការគ្រប់គ្រងកម្មវិធីមត្តេយ្យសិក្សារដ្ឋ<br>– ស្រង់ទិន្នន័យកុមារពីអាយុ០៣ឆ្នាំដល់ក្រោម០៦ឆ្នាំ(រកកុមារដែលបានចូលរៀន និងកុមារដែលមិនបានចូលរៀននៅតាមភូមិ)<br>– សាងសង់អគារ ជួសជុលអគារតាមស្តង់ដា<br>– រៀបចំផែនការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំ<br>– រៀបចំ និងគាំទ្រដំណើរការគណៈកម្មការទ្រទ្រង់សាលា និងក្រុមផ្សេងៗប្រចាំសាលា<br>– រៀបចំទីធ្លា និងល្បែងក្រៅថ្នាក់តាមស្តង់ដា<br>– រៀបចំប្រជុំថ្ងៃព្រហស្បតិ៍ឱ្យបានទៀងទាត់តាមការកំណត់<br>– ផលិតសម្ភារឧបទេសតាមកម្មវិធីប្រចាំខែ<br>– ទំនាក់ទំនង និងជំរុញឪពុកម្តាយកុមារដែលមានកូនដល់អាយុចូលរៀន ដើម្បីឱ្យបញ្ជូនកូនមកសាលារៀន និងរៀនឱ្យបានទៀងទាត់ និងឧបត្ថម្ភគាំទ្រសាលាតាមលទ្ធភាព |

NASLA

| | |
|---|---|
| | – ការចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តការងាររបស់គ្រូបង្រៀន<br>– រៀបចំរបាយការណ៍ស្តីពីវឌ្ឍនភាព និងស្ថានភាពហិរញ្ញវត្ថុតាមការកំណត់ |
| | ៩. កម្មវិធីមត្តេយ្យសិក្សាឯកជន<br>– ធ្វើផែនការអភិវឌ្ឍន៍សាលារៀនប្រចាំឆ្នាំសម្រាប់មត្តេយ្យសិក្សា<br>– គ្រប់គ្រងទិន្នន័យសិស្សមត្តេយ្យសិក្សាប្រចាំឆ្នាំ<br>– ជ្រើសរើសគ្រូបង្រៀនដែលមានសមត្ថភាពគរុកោសល្យសមស្របដោយមិនមានការរើសអើង<br>– ជ្រើសរើសសិស្សឱ្យចូលរៀនតាមលក្ខណៈវិនិច្ឆ័យនិងគោលការណ៍របស់សាលារៀន<br>– ធានាដំណើរការបង្រៀននិងរៀនឱ្យប្រកបដោយគុណភាពនិងប្រសិទ្ធភាព<br>– គោរព និងអនុវត្តសារាចរ សេចក្តីណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា<br>– ធានាសណ្តាប់ធ្នាប់សង្គម និងសុវត្ថិភាពផ្លូវកាយ និងផ្លូវចិត្តចំពោះសិស្ស<br>– ចុះពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តរបស់សាលារៀន<br>– ធ្វើរបាយការណ៍ស្តីពីវឌ្ឍនភាពជូនក្រសួងអប់រំ យុវជន និងកីឡា |
| | ១០. កម្មវិធីអប់រំបញ្ចូលគ្នា និងកម្មវិធីពហុភាសា<br>– ស្រង់ទិន្នន័យកុមារពិការស្រាលៗ និងកុមារជនជាតិដើមភាគតិច<br>– កំណត់ជ្រើសរើសកុមារ និងជ្រើសរើសសាលា/ថ្នាក់ដើម្បីអនុវត្ត<br>– ផលិតសម្ភារឧបទេសតម្រូវទៅតាមកុមារពិការ កុមារជនជាតិដើមភាគតិច<br>– ចុះពិនិត្យតាមដាន និងវាយតម្លៃការអនុវត្តរបស់គ្រូបង្រៀន<br>– រៀបចំរបាយការណ៍ស្តីពីវឌ្ឍន៍ភាពតាមការកំណត់ |
| | ១១. កម្មវិធីអាហារូបត្ថម្ភ |

NASLA

| | |
|---|---|
| | – ទំនាក់ទំនងជាមួយអង្គការដៃគូអភិវឌ្ឍពាក់ព័ន្ធ និងអ្នកពាក់ព័ន្ធដើម្បីកៀរគរធនធាន<br>– កំណត់ចំនួនកុមារដែលត្រូវទទួលអាហារូបត្ថម្ភ<br>– ជំរុញសហគមន៍ និងឪពុកម្ដាយកុមារឱ្យចូលរួមដាំដំណាំចិញ្ចឹមសត្វ ចូលរួមជាថវិកា សម្ភារនិងចំណាយពេលជួយចម្អិនអាហារ<br>– ទំនាក់ទំនងជាមួយមន្ទីរពេទ្យបង្អែក/មណ្ឌលសុខភាពដើម្បីស្វែងយល់ពីក្បួនធ្វើអាហារូបត្ថម្ភ |
| | ១២. កម្មវិធីជួយកុមារក្រីក្រតាមសាលា<br>– ចងក្រងទិន្នន័យកុមារក្រីក្រតាមសាលា<br>– កំណត់ជ្រើសរើសកុមារក្រីក្រតាមសាលា<br>– ទំនាក់ទំនងអ្នកពាក់ព័ន្ធ ដើម្បីប្រមូលធនធាន(អង្គការដៃគូសប្បុរសជន សហគមន៍ ព្រះសង្ឃ ស្ថាប័ននានា)<br>– កំណត់ពេលវេលាត្រូវផ្ដល់ធនធានឱ្យកុមារក្រីក្រ (អាច១ឆ្នាំផ្ដល់ឱ្យ១ដង ឬ១ឆ្នាំផ្ដល់ឱ្យ២ដង តាមលទ្ធភាពដែលមាន)<br>– រៀបចំរបាយការណ៍ស្ដីពីលទ្ធផលការជួយកុមារក្រីក្រ |
| | ១៣. កម្មវិធីអប់រំមាតាបិតា ផ្សារភ្ជាប់នឹងកម្មវិធីមត្តេយ្យសិក្សារដ្ឋ និងកម្មវិធីមត្តេយ្យសិក្សាសហគមន៍<br>– កំណត់និងជ្រើសរើសសាលាដែលត្រូវអនុវត្ត<br>– រៀបចំចងក្រងក្រុមមាតាបិតានៅតាមសាលា/ថ្នាក់គោលដៅ<br>– រៀបចំការប្រជុំតាមការណែនាំ( ១ខែប្រជុំម្ដង )<br>– ចុះពិនិត្យតាមដានការអនុវត្តរបស់មាតាបិតាបង្គោលប្រធានក្រុមម្ដាយ និងមាតាបិតាកុមារ<br>– រៀបចំរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីមាតាបិតាផ្សារភ្ជាប់នឹងកម្មវិធីមត្តេយ្យសិក្សារដ្ឋ និងមត្តេយ្យសិក្សាសហគមន៍( ការប្រែប្រួល )ផ្ដល់ឱ្យអ្នកពាក់ព័ន្ធ។ |
| ២. ការអប់រំបឋមសិក្សា | ១. ការគ្រប់គ្រងបុគ្គលិកអប់រំ<br>– អនុលោមព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| | ២. ការគ្រប់គ្រងគ្រូបង្រៀនបឋមសិក្សាជាប់កិច្ចសន្យា<br>– អនុលោមព្រះរាជក្រឹត្យស្ដីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| | ៣. ការគ្រប់គ្រងសិស្ស |

| | |
|---|---|
| | – យុទ្ធនាការប្រមូលសិស្សចូលរៀន<br>– រៀបចំស្រង់ស្ថិតិ<br>– ផែនទីខ្នងផ្ទះ (រៀបចំ និងធ្វើបច្ចុប្បន្នភាព)<br>– រៀបចំសិស្ស និងគ្រូតាមថ្នាក់តាមនិយាម<br>– តាមដានវត្តមានសិស្ស |
| | ៤. ការរៀបចំផែនការ<br>– រៀបចំផែនការអភិវឌ្ឍន៍សាលារៀន<br>– បែងចែកតួនាទី ភារកិច្ចរបស់មន្ត្រីអប់រំ<br>– បញ្ចូលផែនការអភិវឌ្ឍន៍សាលារៀនទៅក្នុងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់រដ្ឋបាលស្រុក<br>– បែងចែកកម្មវិធីសិក្សាតាមកម្រិតថ្នាក់<br>– លើកគម្រោងថវិកាទៅតាមតម្រូវការផែនការអភិវឌ្ឍន៍ |
| | ៥. ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ<br>– រៀបចំតារាងតម្លាភាព<br>– រៀបចំបញ្ជីតាមដានថវិកា<br>– បែងចែកថវិកាតាមខ្ទង់គណនី<br>– រៀបចំរបាយការណ៍ហិរញ្ញវត្ថុ<br>– រៀបចំបញ្ជី និងជម្រះបញ្ជីសារពើភណ្ឌតាមឆ្នាំ<br>– បិទស្លាកលើសម្ភារតាមប្រភពថវិកា<br>– រៀបចំបញ្ជីទទួល និងបែងចែកសម្ភារ |
| | ៦. ការផ្គត់ផ្គង់សៀវភៅសិក្សាគោល<br>– លើកតម្រូវការសៀវភៅសិក្សាតាមឆ្នាំសិក្សា<br>– ស្នើសុំថវិកាសម្រាប់ទិញសៀវភៅសិក្សា<br>– បែងចែកដល់សិស្ស គ្រូតាមតម្រូវការ<br>– រៀបចំស្ថិតិគ្រប់គ្រង ថែរក្សាសៀវភៅសិក្សា<br>– ធ្វើរបាយការណ៍បូកសរុបពាក់ព័ន្ធនឹងសៀវភៅសិក្សា |
| | ៧. ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានា<br>– រៀបចំបញ្ជីសម្រង់ឈ្មោះសាលារៀនបឋមសិក្សា<br>– រៀបចំបញ្ជីតម្រូវការសាងសង់ និងជួសជុល<br>– រៀបចំផែនការថវិកាសម្រាប់ការសាងសង់ និងជួសជុល<br>– រៀបចំប្លង់សាងសង់ ប្លង់ជួសជុលលម្អិតបច្ចេកទេស បញ្ជីប៉ាន់តម្លៃ ប្រតិទិនការងារសាងសង់ និងជួសជុល |

NASLA

| | |
|---|---|
| | – រៀបចំប្លង់ទីតាំង (ប្លង់សាងសង់តាមស្តង់ដារបស់ក្រសួងអប់រំ យុវជន និងកីឡា)<br>– រៀបចំផែនការសម្រាប់តាមដាន និងត្រួតពិនិត្យការសាងសង់ និងការជួសជុល<br>– រៀបចំផែនការលទ្ធកម្ម<br>– ធ្វើផែនការកែតម្រូវ<br>– រៀបចំរបាយការណ៍ ប្រចាំត្រីមាស ឆមាស និងឆ្នាំដើម្បីផ្ញើទៅអង្គភាពដែលពាក់ព័ន្ធ |
| | ៨. ការគ្រប់គ្រងដំណើរការគណៈកម្មការគ្រប់គ្រងសាលារៀន<br>– ជ្រើសរើសគណៈកម្មការទ្រទ្រង់សាលារៀន<br>– សម្របសម្រួលការប្រជុំ (៣ដងក្នុង១ឆ្នាំ)<br>– ចូលរួមកសាង និងអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន<br>– ប្រមូល និងជំរុញកុមារឱ្យចូលរៀន<br>– តាមដានការរៀនរបស់សិស្ស និងការបង្រៀនរបស់គ្រូ<br>– កៀរគរថវិកាដើម្បីអភិវឌ្ឍសាលារៀន<br>– ចូលរួមកសាង ថែទាំ ជួសជុលហេដ្ឋារចនាសម្ព័ន្ធសាលារៀន<br>– ចូលរួមទប់ស្កាត់រាល់បាតុភាពមិនប្រក្រតីទាំងក្នុង និងក្រៅសាលា<br>– វាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍សាលារៀន |
| | ៩. គណៈកម្មាការអភិវឌ្ឍន៍កម្រងសាលារៀន<br>– បង្កើត លុបកម្រងសាលារៀន<br>– សម្របសម្រួលយន្តការកម្រងសាលារៀន<br>– សម្របសម្រួលការប្រជុំបច្ចេកទេសក្នុងកម្រងសាលារៀន<br>– សម្របសម្រួលការចែករំលែកធនធាន សម្ភាររវាងកម្រងមួយទៅកម្រងមួយ និងរវាងសាលាមួយទៅសាលាមួយទៀត<br>– ពិនិត្យតាមដានការអនុវត្តតួនាទីភារកិច្ចរបស់គណៈកម្មការ និងក្រុមប្រឹក្សាកម្រងសាលារៀន<br>– តាមដានលទ្ធផលសិក្សាក្នុងកម្រង<br>– ការប្រឡងប្រណាំង រវាងកម្រងនិងកម្រង និងរវាងសាលានិងសាលា |
| | ១០. ការផ្តល់អាជ្ញាប័ណ្ណសម្រាប់ការបើក ការបន្តសុពលភាព ការ |

NASLA

| | |
|---|---|
| | ផ្អាកជាបណ្ដោះ អាសន្ន និងការដកហូតអាជ្ញាប័ណ្ណ សាលាបឋមសិក្សាឯកជនកម្មវិធីសិក្សាជាតិ<br>– អនុលោមសេចក្តីណែនាំលេខ១០ អយក.សណន ចុះថ្ងៃទី ២៩ ខែមករា ឆ្នាំ២០១៤ |
| | ១១. កម្មវិធីពហុភាសា<br>– រៀបចំថ្នាក់រៀនដែលស្ថិតនៅតំបន់ជនជាតិដើមភាគតិច<br>– ប្រមូលសិស្សជនជាតិដើមភាគតិចដែលមានតម្រូវការ<br>– រៀបចំផែនការដើម្បីបណ្ដុះបណ្ដាលគណៈកម្មការគ្រប់គ្រង និងគ្រូ សម្រាប់ការបង្រៀនពហុភាសា<br>– ជំរុញការអនុវត្តកម្មវិធីសិក្សាថ្នាក់ពហុភាសា<br>– រៀបចំរបាយការណ៍បូកសរុបការអនុវត្តដំណើរការបង្រៀនពហុភាសា |
| | ១២. កម្មវិធីពន្លឿនការសិក្សា<br>– ប្រមូល និងគ្រប់គ្រងស្ថិតិសិស្ស ឬកុមារលើសអាយុ<br>– រៀបចំថ្នាក់ និងគ្រូសម្រាប់ការបង្រៀនកម្មវិធីពន្លឿនការសិក្សា<br>– ជំរុញការអនុវត្ត និងធ្វើរបាយការណ៍លទ្ធផល |
| | ១៣. កម្មវិធីស្បៀងអាហារតាមសាលារៀន<br>– រៀបចំកន្លែងចម្អិនអាហារ( ផ្ទះបាយតាមសាលារៀន ) និងចុងភៅដោយកៀរគរធនធានពីសហគមន៍<br>– រៀបចំតារាងបញ្ជីឈ្មោះសិស្សតាមវេន ដែលត្រូវទទួលអាហារ<br>– ធ្វើសំណើសុំស្បៀងដើម្បីប្រើប្រាស់ទៅតាមត្រីមាស ដែលផ្អែកលើចំនួនសិស្សដែលបានប៉ាន់ស្មាន<br>– រៀបចំទុកដាក់ស្បៀងអាហារឱ្យបានត្រឹមត្រូវតាមបច្ចេកទេស<br>– បែងចែកស្បៀង និងចម្អិនអាហារឱ្យសិស្សហូប<br>– កៀរគរធនធានពីសហគមន៍ដើម្បីឧបត្ថម្ភចុងភៅ<br>– រៀបចំរបាយការណ៍ |
| | ១៤. កម្មវិធីអប់រំពិសេស<br>– កំណត់អត្តសញ្ញាណសិស្សពិការ<br>– សម្របសម្រួល និងផ្តល់នូវការគាំទ្រដល់សិស្សពិការ<br>– រៀបចំសិស្សពិការឱ្យចូលរៀនជាមួយសិស្សធម្មតា |

NASLA

| | |
|---|---|
| | – អភិវឌ្ឍសមត្ថភាពគ្រូលើការអប់រំបរិយាប័ន្ន |
| | ១៥. កម្មវិធីអាហារូបករណ៍សិស្សក្រីក្រ<br>– បង្កើតគណៈកម្មការ<br>– ជ្រើសរើសសិស្សអាហាររូបករណ៍(ផ្អែកតាមការណែនាំរបស់ក្រសួង)<br>– រៀបចំផែនការថវិកា និងសំណើសុំអាហារូបករណ៍<br>– បែងចែកថវិកាដល់សិស្សអាហារូបករណ៍ដែលបានជ្រើសរើស<br>– តាមដានការសិក្សារបស់សិស្សដែលទទួលបានអាហារូបករណ៍<br>– រៀបចំរបាយការណ៍បូកសរុប។ |
| | ១៦. កម្មវិធីអប់រំសុខភាព និងអនាម័យ<br>– សាលារៀនសុវត្ថិភាព បំប៉នក្រុមបំប៉ន និងពិនិត្យតាមដានរដ្ឋបាលស្រុក  គ្រូបង្រៀនសហគមន៍ និងអ្នកពាក់ព័ន្ធអំពីការបង្ការគ្រោះថ្នាក់ផ្សេងៗ គ្រោះថ្នាក់ដោយធម្មជាតិ និងដោយសារគ្រាប់សំណល់ពីសង្គ្រាម ធ្វើរបងព័ទ្ធជុំវិញស្រះទឹក អណ្តូងទឹកនៅក្នុងសាលារៀន<br>– បង្កើតគណៈកម្មការសុខភាពសិក្សាតាមសាលារៀន<br>– ត្រួតពិនិត្យមើលសុខភាពរបស់កុមារមុនចាប់ផ្តើមចូលរៀន (ពិនិត្យសុខភាព និងកាយសម្បទាកុមារថ្នាក់ទី១ នៅពេលចាប់ផ្តើមឆ្នាំសិក្សាដំបូង។ ផ្តល់វ៉ាក់សាំងថ្នាំបង្ការ ផ្តល់វីតាមីន ផ្តល់ថ្នាំទម្លាក់ព្រូនពីរដង ក្នុងមួយឆ្នាំដល់បុគ្គលិកអប់រំ និងអ្នកសិក្សា)<br>– ការពិនិត្យចំណីអាហារនៅក្នុងសាលារៀន ការបំពាក់សម្ភាររូបវន្ត ផ្អែកអនាម័យតាមសាលារៀន (ផ្គត់ផ្គង់ទឹកស្អាត បង្គន់អនាម័យ កន្លែងលាងសម្អាតដៃ ផ្តល់ប្រអប់សង្គ្រោះបឋម និងសម្ភារៈបម្រុង គ្រប់គ្រងកាកសំណល់រឹង រាវ និងរៀបចំ និងរក្សាទុកព័ត៌មានសុខភាពរបស់សិស្សនៅគ្រប់ភូមិសិក្សា)<br>– ការអប់រំសុខភាព(ផ្តល់ការអប់រំអំពីសុខភាពបន្តពូជ សុខភាពផ្លូវភេទ រួមបញ្ចូលទាំងការអប់រំ បង្ការជំងឺអេដស៍ គ្រឿងញៀន ការអប់រំសុខភាព អនាម័យ សុវត្ថិភាពចំណីអាហារ អាហាររូបត្ថម្ភ វិធីសង្គ្រោះបឋម គ្រឿងស្រវឹង បារី សុខភាព |

NASLA

| | |
|---|---|
| | ភ្នែក សុខភាពមាត់ធ្មេញ ព្រមទាំងការអប់រំបង្ការជំងឺមិនឆ្លង និងជំងឺឆ្លងនានា)<br>– ការអប់រំអំពីសង្គម និងបរិស្ថាន(បំប៉នគ្រូបង្រៀន សិស្ស និងអ្នកពាក់ព័ន្ធអំពីវិធានការបង្ការទប់ស្កាត់ គ្រោះមហន្តរាយ គ្រោះថ្នាក់ផ្សេងៗ បម្រែបម្រួលអាកាសធាតុ ការដាំដើមឈើឡើងវិញ និងការថែរក្សាបរិស្ថាន ។ |
| | ១៧. ការងារក្រុមប្រឹក្សាកុមារ<br>– រៀបចំយន្តការ ការគ្រប់គ្រង និងការជ្រើសរើសក្រុមប្រឹក្សាកុមារ<br>– គាំទ្រដល់ដំណើរការរបស់ក្រុមប្រឹក្សាកុមារ<br>– លើកទឹកចិត្តដល់ក្រុមប្រឹក្សាកុមារផ្តោតលើចលនាបីល្អ |
| | ១៨. ការអប់រំកាយ និងកីឡា<br>– ជំរុញ និងតាមដានសកម្មភាពកាយសិក្សានៅតាមសាលាបឋមសិក្សាសាធារណៈ និងឯកជន<br>– អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធកីឡានៅតាមសាលាបឋមសិក្សាសាធារណៈ និងឯកជន |
| ៣. ការអប់រំក្រៅប្រព័ន្ធ | ១. ការគ្រប់គ្រងបុគ្គលិក<br>– អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| | ២. ការជ្រើសរើសនិងការគ្រប់គ្រងគ្រូបង្រៀនជាប់កិច្ចសន្យា<br>– អនុលោមព្រះរាជក្រឹត្យស្តីពីលក្ខន្តិកៈដោយឡែកសម្រាប់បុគ្គលិករដ្ឋបាលថ្នាក់ក្រោមជាតិ |
| | ៣. ការប្រមូល ការគ្រប់គ្រងសិស្ស អ្នកសិក្សា និងអ្នកចូលរួម<br>– ផ្សព្វផ្សាយកម្មវិធីអប់រំក្រៅប្រព័ន្ធដល់អ្នកពាក់ព័ន្ធ<br>– ពិនិត្យ ស្រង់ស្ថិតិ និងប្រមូលក្រុមមុខសញ្ញា<br>– រៀបចំឯកសារ និងសម្ភារសម្រាប់ដំណើរការរៀន<br>– ពិនិត្យតាមដានការរៀនរបស់សិស្ស<br>– រៀបចំការប្រឡង និងបញ្ជូនសិស្ស<br>– ចេញប័ណ្ណអក្ខរកម្ម វិញ្ញាបនបត្របញ្ជាក់ការសិក្សាតាមកម្មវិធី |
| | ៤. ការរៀបចំផែនការសកម្មភាព<br>– រៀបចំផែនទីសិក្សាពាក់ព័ន្ធកម្មវិធីអប់រំក្រៅប្រព័ន្ធ<br>– រៀបចំផែនការតម្រូវការគ្រូបង្រៀនជាប់កិច្ចសន្យាតាមឆ្នាំ |

NASLA

| | |
|---|---|
| | – សិក្សាតម្រូវការឱ្យឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ក្រុមមុខសញ្ញា<br>– ចូលរួមវគ្គបំប៉នទាក់ទងនឹងការរៀបចំផែនការសកម្មភាព<br>– រៀបចំផែនការការងារលម្អិតតាមខែ<br>– រៀបចំផែនការការងារប្រចាំឆ្នាំ |
| | ៥. ការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ<br>– បង្កើតគណៈកម្មការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ<br>– រៀបចំផែនការចំណាយប្រចាំឆ្នាំ ប្រចាំខែ<br>– រៀបចំការបែងចែកថវិកាទៅកម្មវិធីអប់រំក្រៅប្រព័ន្ធ<br>– រាល់ការចំណាយត្រូវមានការឯកភាពតាមគណៈកម្មការនីមួយៗ និងតម្លាភាព<br>– រៀបចំកិច្ចបញ្ជិកាគណនេយ្យ<br>– រៀបចំបញ្ជីសារពើភ័ណ្ឌប្រចាំឆ្នាំរបស់សាលា<br>– រៀបចំបញ្ជីសារពើភ័ណ្ឌគោល<br>– តាមដានការកើនឡើង ការថយចុះទ្រព្យសម្បត្តិរដ្ឋប្រចាំឆ្នាំ<br>– ធ្វើការពិនិត្យតាមដានសម្ភារបរិក្ខាររបស់ខ្លួន<br>– រៀបចំកិច្ចបញ្ជិកាសម្ភារ<br>– លើកគម្រោងតម្រូវការសម្ភារប្រចាំឆ្នាំ<br>– រៀបចំសៀវភៅបញ្ជីតាមដានការប្រើប្រាស់សម្ភារ |
| | ៦. ការផ្តល់អាជ្ញាប័ណ្ណសម្រាប់ការបើក ការបន្តសុពលភាព ការផ្អាកជាបណ្តោះអាសន្ន និងការដកហូតអាជ្ញាប័ណ្ណមជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញមុខរបរ និងភាសាបរទេសរយៈពេលតិចជាង០១(មួយ)ឆ្នាំ<br>– អនុលោមសេចក្តីណែនាំលេខ១៩ អយក.សសន ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១២ |
| | ៧. ការគ្រប់គ្រងទំនិញ សំណង់អគារ ការសាងសង់ ការជួសជុល ការថែទាំហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មនានា<br>– រៀបចំបញ្ជីសម្រង់ឈ្មោះមជ្ឈមណ្ឌលសិក្សាសហគមន៍<br>– រៀបចំបញ្ជីតម្រូវការសាងសង់ និងជួសជុល<br>– រៀបចំផែនការថវិកាសម្រាប់ការសាងសង់ ការជួសជុល<br>– រៀបចំប្លង់សាងសង់ ប្លង់ជួសជុលលម្អិតបច្ចេកទេស បញ្ជីប៉ាន់តម្លៃ ប្រតិទិនការងារសាងសង់ និងជួសជុល<br>– រៀបចំប្លង់ទីតាំង (ប្លង់សាងសង់កំណត់តាមស្តង់ដាររបស់ |

NASLA

| | |
|---|---|
| | ក្រសួងអប់រំ យុវជន និងកីឡា)<br>– រៀបចំផែនការសម្រាប់តាមដាន និងត្រួតពិនិត្យការសាងសង់ និងជួសជុល<br>– រៀបចំផែនការលទ្ធកម្ម<br>– ធ្វើផែនការកែតម្រូវ<br>– របាយការណ៍ ប្រចាំត្រីមាស ឆមាស និងឆ្នាំដើម្បីផ្ញើទៅអង្គភាពពាក់ព័ន្ធ |
| | ៨. កម្មវិធីអក្ខរកម្មវិជ្ជាជីវៈ<br>– បើកថ្នាក់អក្ខរកម្មតាមភូមិឬមជ្ឈមណ្ឌលសិក្សាសហគមន៍ តាមរោងចក្រសហគ្រាស<br>– ផ្គត់ផ្គង់សម្ភារទ្រទ្រង់ដំណើរការថ្នាក់<br>– ពង្រឹងកិច្ចសហការជាមួយដៃគូអភិវឌ្ឍន៍នានា<br>– ផ្ដល់អាហារូបករណ៍ដល់សិស្សអក្ខរកម្ម<br>– ផ្ដល់ការអប់រំអក្ខរកម្មពីរភាសាសម្រាប់ជនជាតិដើមភាគតិច<br>– ផ្ដល់រង្វាន់លើកទឹកចិត្តដល់សិស្សអក្ខរកម្មដែលសិក្សាបានល្អ<br>– ពិនិត្យតាមដាន និងកែលម្អឱ្យបានជាប្រចាំ<br>– ប្រារព្ធទិវាអក្ខរកម្មជាតិ អន្តរជាតិ៨កញ្ញា |
| | ៩. កម្មវិធីក្រោយអក្ខរកម្ម<br>– ផ្ដល់ថវិកាដំណើរការបណ្ណាល័យ និងមណ្ឌលអាន<br>– សាកល្បងតេស្តថ្នាក់ក្រោយអក្ខរកម្មសម្រាប់អ្នកដែលបានបញ្ចប់ការសិក្សា<br>– ពិនិត្យតាមដានដំណើរការបណ្ណាល័យ និងមណ្ឌលអាន |
| | ១០. កម្មវិធីសមមូលបឋមសិក្សា និងបំពេញវិជ្ជា<br>– ផ្សព្វផ្សាយកម្មវិធីសមមូលបឋមសិក្សា និងបំពេញវិជ្ជា<br>– ផ្ដល់សម្ភារដំណើរការ<br>– ចូលរួមវគ្គបំប៉នគ្រូបង្រៀនជាប់កិច្ចសន្យា<br>– ពិនិត្យតាមដានលើការអនុវត្តកម្មវិធី<br>– រៀបចំការប្រឡង និងបញ្ជីឈ្មោះសិស្ស<br>– ចេញវិញ្ញាបនបត្របញ្ជាក់ការសិក្សា |
| | ១១. កម្មវិធីបង្កើនប្រាក់ចំណូល<br>– ផ្សព្វផ្សាយពីសារៈប្រយោជន៍នៃមជ្ឈមណ្ឌលសិក្សាសហគមន៍ និងកម្មវិធីបំណិនជីវិត |

NASLA

| | |
|---|---|
| | – ពង្រឹងសកម្មភាពមជ្ឈមណ្ឌលសហគមន៍តាមតម្រូវការជាក់ស្តែង<br>– ប្រជុំប្រចាំខែ ត្រីមាស ឆមាស ឆ្នាំ និងរៀបចំរបាយការណ៍<br>– កំណត់អាទិភាពបណ្តុះបណ្តាលជំនាញមុខរបរឱ្យឆ្លើយតបទៅនឹងតម្រូវការទីផ្សារ<br>– ផ្តល់ទុន ឬប្រាក់កម្ចី ឬសម្ភារដល់អ្នករៀននៅពេលបញ្ចប់ការសិក្សា<br>– ពិនិត្យតាមដានកែលម្អជាប្រចាំពីអ្នកពាក់ព័ន្ធនានា<br>– បើកថ្នាក់បង្រៀនថ្នាក់ជំនាញមុខរបរនៅតាមមជ្ឈមណ្ឌលសហគមន៍<br>– ជំរុញការអនុវត្តកម្មវិធីអប់រំក្រៅប្រព័ន្ធផ្សេងៗក្នុងមជ្ឈមណ្ឌលសិក្សាសហគមន៍<br>– ប្រើប្រាស់ស្តង់ដាវាយតម្លៃគ្រប់សកម្មភាព ស្ថានភាពមជ្ឈមណ្ឌលសិក្សាសហគមន៍<br>– ចូលរួមទស្សនកិច្ចសិក្សាដើម្បីផ្លាស់ប្តូរបទពិសោធន៍<br>– សហការជាមួយសហគមន៍ពិនិត្យទីតាំងសមស្របសម្រាប់កសាងមជ្ឈមណ្ឌលសិក្សាសហគមន៍ |
| | ១២. កម្មវិធីចូលរៀនឡើងវិញ<br>– ផ្តល់ការគាំទ្រគណៈកម្មការប្រមូលសិស្ស<br>– ផ្តល់សម្ភារសម្រាប់ដំណើរការថ្នាក់<br>– ចូលរួមវគ្គបំប៉ន |
| **មុខងារដែលត្រូវបានធ្វើប្រតិភូកម្ម** | |
| ១. ការងាររដ្ឋបាលគាំទ្រគ្រឹះស្ថានមធ្យមសិក្សាចំណេះទូទៅ | ១. ការងាររដ្ឋបាល<br>- ផ្សព្វផ្សាយគោលការណ៍ណែនាំ លិខិតបទដ្ឋានគតិយុត្ត និងគោលនយោបាយដល់សាលារៀន<br>- ណែនាំសាលារៀនក្នុងការរៀបចំ និងគ្រប់គ្រងសៀវភៅកត់ត្រាលិខិតចេញ ចូល វត្តមានបុគ្គលិក និងសៀវភៅរដ្ឋបាលផ្សេងៗទៀត<br>- ផ្តល់យោបល់ និងគាំទ្រការរៀបចំការងារបរិស្ថាន ប្លង់សាលារៀន ការងារអនាម័យនៅតាមសាលារៀន<br>- គ្រប់គ្រងស្ថិតិគ្រូ និងសិស្សតាមសាលាមធ្យមសិក្សា<br>- ជំរុញការប្រឡងប្រណាំងសាលារៀនស្អាត នាយកល្អ គ្រូ |

NASLA

| | |
|---|---|
| | បង្រៀនល្អ<br>- រៀបចំលិខិតចាត់តាំង និងត្រួតពិនិត្យលើការចាត់តាំងគ្រូចេញថ្មី គ្រូផ្ទេរចូលទៅបម្រើការងារនៅសាលារៀនផ្អែកតាមលិខិតឧទ្ទេសនាមរបស់មន្ទីរអប់រំ យុវជន និងកីឡា<br>- ពិនិត្យតាមដានការបំពេញការងាររបស់គ្រូបង្រៀន<br>- បូកសរុបរបាយការណ៍នៅតាមសាលាមធ្យមសិក្សាតាមគោលការណ៍កំណត់<br>- ត្រួតពិនិត្យមើលការងារប្រឡងធមាស<br>– សម្របសម្រួល និងគាំទ្រដល់សាលាមធ្យមសិក្សា។ |
| | ២. ការគ្រប់គ្រងបុគ្គលិក<br>- លើកសំណើតែងតាំង និងបញ្ចប់មុខតំណែងគណៈគ្រប់គ្រងសាលា<br>- ពិនិត្យ វាយតម្លៃ និងលើកសំណើដំឡើងថ្នាក់ និងឋានន្តរស័ក្តិ ផ្តល់មេដាយ ប័ណ្ណសរសើរ និងការលើកទឹកចិត្តផ្សេងទៀត គ្រូល្អ នាយកល្អ មកមន្ទីរអប់រំ យុវជន និងកីឡា<br>- ពិនិត្យ និងបញ្ជូនសំណើលំហែមាតុភាព ចូលនិវត្តន៍ ឈប់ពីការងារ ផ្លាស់ប្តូរទីកន្លែងបម្រើការងារ សម្រាកព្យាបាលជំងឺ ទំនេរគ្មានបៀវត្ស គ្រោះថ្នាក់ក្នុងពេលបម្រើការងារ មរណភាព សុំច្បាប់ឈប់សម្រាកចាប់ពី៧(ប្រាំពីរ)ថ្ងៃទៅមន្ទីរអប់រំ យុវជន និងកីឡា<br>- ពិនិត្យ និងអនុញ្ញាតច្បាប់ឈប់សម្រាកក្រោម៧ថ្ងៃ<br>- ប្រមូលបូកសរុបតម្រូវការគ្រូ និងធ្វើសំណើមកមន្ទីរអប់រំ យុវជន និងកីឡា<br>- ពិនិត្យសំណើ និងផ្តល់យោបល់លើការដាក់ទណ្ឌកម្មខាងវិន័យរដ្ឋបាលដល់បុគ្គលិកអប់រំមធ្យមសិក្សា<br>- គ្រប់គ្រងទិន្នន័យបុគ្គលិកមធ្យមសិក្សា និងធ្វើរបាយការណ៍អំពីស្ថានភាពបុគ្គលិកទៅមន្ទីរអប់រំ យុវជន និងកីឡា<br>- ពិនិត្យតាមដានការបំពេញការងាររបស់គ្រូបង្រៀន<br>– ពិនិត្យ និងផ្ទៀងផ្ទាត់លើតារាងប្រាក់បៀវត្សមូលដ្ឋាន ប្រាក់បន្ទាប់បន្សំនៃបៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗ។ |
| | ៣.ការងារផែនការ ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ<br>– ណែនាំសាលារៀនធ្វើផែនការអភិវឌ្ឍន៍សាលារៀន និងផែនការថវិកា |

NASLA

| | |
|---|---|
| | – ពិនិត្យ និងបូកសរុបផែនការប្រតិបត្តិរបស់សាលារៀនទូទាំងស្រុកជូនមន្ទីរអប់រំ យុវជន និងកីឡា<br>– ណែនាំអំពីនីតិវិធី ឬគោលការណ៍នៃការប្រើប្រាស់ថវិកា (មាតិកាចំណាយ កិច្ចបញ្ជិកា នីតិវិធីទូទាត់... )<br>– ពិនិត្យតាមដានការប្រើប្រាស់ថវិកាដំណើរការសាលារៀន<br>– ប្រមូល និងធ្វើរបាយការណ៍សមិទ្ធកម្មតាមគោលការណ៍កំណត់<br>– បែងចែក និងប្រជុំផ្សព្វផ្សាយតារាងថវិកាតាមជំហាននីមួយៗផ្អែកលើតារាងថវិការបស់មន្ទីរអប់រំ យុវជន និងកីឡា<br>– រៀបចំសំណើសុំប្រាក់អាហារូបករណ៍សិស្សក្រីក្រទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– បូកសរុបរបាយការណ៍ចំណូល-ចំណាយរបស់សាលារៀនជូនមន្ទីរអប់រំ យុវជន និងកីឡា<br>– ពិនិត្យ ផ្ទៀងផ្ទាត់ និងបញ្ជូនបញ្ជីសារពើភណ្ឌសាលារៀនជូនទៅមន្ទីរអប់រំ យុវជន និងកីឡា។ |
| ២. ការអភិវឌ្ឍយុវជន | ១. ការអភិវឌ្ឍយុវជន<br>– ផ្សព្វផ្សាយគោលការណ៍ណែនាំ ច្បាប់ លិខិតបទដ្ឋានពាក់ព័ន្ធនឹងការអភិវឌ្ឍយុវជន<br>– ត្រួតពិនិត្យ ណែនាំ និងជំរុញសាលារៀនឱ្យរៀបចំបង្កើត និងដំណើរការក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា<br>– ផ្តល់ការណែនាំអំពីតួនាទី ភារកិច្ចរបស់នាយកសាលា គ្រូបង្រៀន និងសិស្សដែលទទួលបន្ទុកការងារក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា<br>– កៀរគរ សម្របសម្រួល និងសហការជាមួយដៃគូដើម្បីបណ្តុះបណ្តាលជំនាញ និងបំណិនផ្សេងៗដល់សមាជិកក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា<br>– ដោះស្រាយបញ្ហានានាពាក់ព័ន្ធយុវជន កុមារតាមសាលារៀន ដូចជា៖ ការបោះបង់ អវត្តមាន ការពាក់ព័ន្ធគ្រឿងញៀន<br>– ប្រមូល និងគ្រប់គ្រងទិន្នន័យក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា ដើម្បីបូកសរុបការងារ និងចងក្រងឯកសាររបាយការណ៍តាមគោលការណ៍កំណត់ |

NASLA

| | |
|---|---|
| | – សម្របសម្រួល និងដឹកនាំសិស្សចូលរួមសកម្មភាពផ្លាស់ប្តូរបទពិសោធន៍ ទាំងកម្រិតជាតិ និងអន្តរជាតិ<br>– ជំរុញសាលារៀនឱ្យបង្កើតក្លឹបសិក្សាសម្រាប់ក្រុមប្រឹក្សាកុមារកម្ពុជា និងក្រុមប្រឹក្សាយុវជនកម្ពុជា<br>– ប្រមូលតម្រូវការអភិវឌ្ឍយុវជនក្នុងសហគមន៍ និងធ្វើសំណើទៅមន្ទីរអប់រំ យុវជន និងកីឡា។ |
| ៣. ការងារអប់រំកាយ និងកីឡា | ១. ការងារអប់រំកាយ និងកីឡា<br>– ជំរុញការអនុវត្តការងារអប់រំកាយក្នុងម៉ោងសិក្សា និងការងារកីឡាក្រៅម៉ោងសិក្សាតាមគ្រឹះស្ថានសិក្សា<br>– រៀបចំ និងអនុវត្តការហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាពរបស់មហាជនតាមសហគមន៍<br>– ជំរុញ សម្របសម្រួល និងសហការរៀបចំសម្ភារ ជួសជុលទីលានកីឡាតាមសាលារៀន និងសហគមន៍<br>– ជំរុញ និងសហការឱ្យយុវជនលេងកីឡាមួយប្រភេទយ៉ាងតិចក្នុងសាលារៀន និងសហគមន៍<br>– ផ្សព្វផ្សាយ និងណែនាំអំពីគោលការណ៍ លិខិតបទដ្ឋានគតិយុត្ត និងបច្ចេកទេសពាក់ព័ន្ធនឹងការងារអប់រំកាយ និងកីឡា<br>– ប្រមូល និងរៀបចំស្ថិតិទីលានកីឡា ក្លឹបកីឡា មន្ត្រីជំនាញកីឡាករ កីឡាការិនី មហាជនហាត់ប្រាណ និងលេងកីឡាដើម្បីសុខភាព កីឡាពាក់កណ្តាលអាជីព និងកីឡាអាជីព<br>– ជំរុញ និងសហការរៀបចំប្រកួតកីឡានៅតាមសាលារៀនថ្នាក់ស្រុក និងចូលរួមប្រកួតថ្នាក់ខេត្ត និងថ្នាក់ជាតិ<br>– ប្រមូលតម្រូវការគ្រូអប់រំកាយ និងគ្រូកីឡាជំនាញ និងធ្វើសំណើទៅមន្ទីរអប់រំ យុវជន និងកីឡា<br>– កៀរគរស្វែងរកមូលនិធិអភិវឌ្ឍកីឡាពីអ្នកពាក់ព័ន្ធនានា<br>– តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍ការងារអប់រំកាយ និងកីឡានៅតាមសាលារៀន និងសហគមន៍តាមគោលការណ៍កំណត់<br>– ពិនិត្យ និងសម្រេចលើការស្នើសុំអាជ្ញាប័ណ្ណសម្រាប់ការបើកការបន្តសុពលភាព ក្លឹបហាត់ប្រាណ និងអាជីវកម្មលក់សម្ភារកីឡា។ |

NASLA

## ឧបសម្ព័ន្ធទី៣ ៖ មុខងារ និងមុខងាររងពាក់ព័ន្ធការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាល

| **មុខងារ** | **មុខងាររង ឬសកម្មភាព** |
|---|---|
| ១. ការងាររៀបចំដែនដី និងនគរូបនីយកម្ម | ១. ការរៀបចំប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ប្លង់គោលប្រើប្រាស់ដីទីប្រជុំជន ផែនការប្រើប្រាស់ដីទីប្រជុំជន និងប្លង់លម្អិត នគរូបនីយកម្មនៃតំបន់ណាមួយនៅក្នុងស្រុក។ |
| ២. ការងារភូមិបាល | ១. ការផ្ទេរសិទ្ធិកាន់កាប់អចលនវត្ថុដែលមិនទាន់ចុះបញ្ជី<br>២. កិច្ចការពារដីសាធារណៈ និងដីឯកជនរបស់រដ្ឋ ដោយចាត់វិធានការទប់ស្កាត់ការបំពាន ឬការចូលទន្ទ្រានកាន់កាប់ដីរដ្ឋ។ |
| ៣. ការងារសំណង់ | ១. ការផ្តល់លិខិតអនុញ្ញាតសាងសង់ ជួសជុល រុះរើ ឬបើកការដ្ឋាន និងផ្តល់វិញ្ញាបនបត្រប្រើប្រាស់សំណង់ ចំពោះបណ្តាសំណង់លំនៅឋានដែលមានផ្ទៃក្រឡាកម្រាលសំណង់សរុបមិនលើសពី ៥០០ ម៉ែត្រក្រឡា និងមានកម្ពស់មិនលើសពី៤ ជាន់ រួមទាំងជាន់ផ្ទាល់ដី ( Eo E1 E2 E3 )<br>២. លិខិតអនុញ្ញាតសាងសង់ ជួសជុល ឬរុះរើ របងដែលមានកម្ពស់មិនលើសពី៣ម៉ែត្រគិតពីកម្រិតកម្ពស់ដីនៅជើងរបង<br>៣. ការបន្តសុពលភាពលិខិតអនុញ្ញាតសាងសង់ រុះរើ ជួសជុល លិខិតអនុញ្ញាតបើកការដ្ឋាន និងវិញ្ញាបនបត្រប្រើប្រាស់សំណង់ សម្រាប់សំណង់មានផ្ទៃក្រឡាមិនលើសពី៥០០ ម៉ែត្រក្រឡា និងមានកម្ពស់មិនលើសពី៤ ជាន់ រួមទាំងជាន់ផ្ទាល់ដី ( Eo E1 E2 E3 )<br>៤. លិខិតផ្អាកការសាងសង់ចំពោះរាល់សកម្មភាពសាងសង់ដែលមិនគោរពតាមបទប្បញ្ញត្តិជាធរមាន។ |
| **៤. ការងារលំនៅឋាន** | ១. ពិនិត្យផ្តល់យោបល់លើផែនការសម្បទានដីសង្គមកិច្ចថ្នាក់មូលដ្ឋាន<br>២. ការបង្ការ និងទប់ស្កាត់សំណង់បណ្តោះអាសន្នលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅក្នុងស្រុក។ |

NASLA

**ឧបសម្ព័ន្ធទី៤ ÷ មុខងារ និងមុខងាររងពាក់ព័ន្ធការិយាល័យកសិកម្ម ធនធានធម្មជាតិ និងបរិស្ថាន**

| **មុខងារ** | **មុខងាររង ឬសកម្មភាព** |
|---|---|
| **វិស័យកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ** | |
| ១.ការងារកសិកម្ម | ១. ការងារផ្សព្វផ្សាយបច្ចេកទេសកសិកម្ម( ស្រូវ ដំណាំ បន្លែ )<br>– ផ្សព្វផ្សាយបច្ចេកទេសដាំដុះដំណាំដែលបានរៀបចំ និងទទួលស្គាល់ដោយអង្គភាពជំនាញថ្នាក់ជាតិ<br>– សម្របសម្រួល និងគាំទ្រដល់ការរៀបចំក្រុម និងសហគមន៍កសិកម្ម។ |
| | ២. ការអនុវត្តការងារក្សេត្រសាស្ត្រ និងការគ្រប់គ្រងដីសម្រាប់ការដាំដុះ<br>– ប្រមូល និងគ្រប់គ្រងស្ថិតិដីដាំដុះដំណាំគ្រប់ប្រភេទ<br>– វាយតម្លៃផ្ទៃដីដាំដុះដែលប៉ះពាល់ និងខូចខាតដោយគ្រោះធម្មជាតិ<br>– តាមដាន អង្កេត និងផ្តល់ព័ត៌មានស្តីពីបញ្ហានៃការបំផ្លាញរបស់សមាសភាពចង្រៃលើដំណាំ។ |
| | ៣. ការអនុវត្តការងារដំណាំកសិ-ឧស្សាហកម្ម<br>– ប្រមូល និងគ្រប់គ្រងស្ថិតិផ្ទៃដីដាំដុះដំណាំកសិឧស្សាហកម្ម។- |
| ២. ការងារសុខភាពសត្វ និងផលិតកម្មសត្វ | ១. ការអនុវត្តការងារសុខភាពសត្វ និងផលិតកម្មសត្វ<br>– តាមដានសុខភាពសត្វ ដើម្បីកំណត់វិធានការអន្តរាគមន៍ ការពារទប់ស្កាត់ និងជួយសង្គ្រោះពេលមានគ្រោះធម្មជាតិ<br>– តាមដាន និងជំរុញសកម្មភាពផលិតកម្មសត្វ និងបសុព្យាបាល<br>– ប្រមូល និងធ្វើបច្ចុប្បន្នភាពស្ថិតិសត្វ ស្ថិតិកសិដ្ឋានចិញ្ចឹមសត្វ ដេប៉ូលក់ចំណីសត្វ បសុឱសថ សត្តឃាតដ្ឋាន និងភ្នាក់ងារសុខភាពសត្វភូមិ និងអង្កេតទិន្នន័យស្ថិតិសត្វគ្រប់ប្រភេទ<br>– ផ្សព្វផ្សាយបច្ចេកទេសផលិតកម្ម និងបសុព្យាបាលចំណីសត្វ ឡជីវឧស្ម័នដល់អ្នកចិញ្ចឹមសត្វ<br>– តាមដានការធ្វើអាជីវកម្មសត្វ ចំណីសត្វ បសុឱសថ និងផលិតផលមានដើមកំណើតពីសត្វតាមសត្តឃាតដ្ឋាន ទីកន្លែងកែច្នៃផលិតផលមានដើមកំណើតពីសត្វ និងកសិដ្ឋានចិញ្ចឹមសត្វ<br>– គ្រប់គ្រងគ្លីនីកសត្វ<br>– គ្រប់គ្រងព័ត៌មានជំងឺសត្វ និងការអនុវត្តវិធានសុវត្ថិភាពបឋម។ |
| ៣. ការងារព្រៃឈើ | ១. ការអនុវត្តការងារព្រៃឈើ |

| | |
|---|---|
| | – អប់រំផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការគ្រប់គ្រង ការថែរក្សា ការពារ និងការអភិវឌ្ឍធនធានព្រៃឈើ<br>– បង្កើត គ្រប់គ្រង និងគាំទ្រសហគមន៍ព្រៃឈើ<br>– គ្រប់គ្រងលើការប្រកបរបរចម្ការពនេចរមានលក្ខណៈប្រពៃណីរបស់សហគមន៍មូលដ្ឋានលើដីកម្មសិទ្ធិសមូហភាពរបស់សហគមន៍ជនជាតិដើមភាគតិចដែលបានចុះបញ្ជិកា<br>– បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសព្រៃឈើ។ |
| ៤. ការងារជលផល | ១. ការអនុវត្តការងារជលផល<br>– បង្ការ ទប់ស្កាត់ និងបង្ក្រាបបទល្មើសជលផល<br>– អប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋអំពីសារៈសំខាន់នៃការគ្រប់គ្រង ការអភិរក្ស និងការអភិវឌ្ឍធនធានជលផលប្រកបដោយនិរន្តរភាព<br>– បង្កើត គាំទ្រ និងគ្រប់គ្រងសហគមន៍ជលផល។ |
| ៥. ការផ្តល់សេវារដ្ឋបាល | ១. ផ្នែកកសិកម្ម<br>– គ្រប់គ្រង និងផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មលក់ដុំ រាយសម្ភារកសិកម្ម។<br>**២. ផ្នែកអនាម័យសត្វ**<br>– គ្រប់គ្រង និងផ្តល់វិញ្ញាបនបត្រអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ។<br>៣. ផ្នែកទឹកសាប<br>– ធ្វើវារីវប្បកម្មក្នុងស្រះមានផ្ទៃក្រឡាលើសពី ៥,០០០ម៉ែត្រការ៉េ ដល់ ១០,០០០ម៉ែត្រការ៉េ<br>– ធ្វើវារីវប្បកម្មក្នុងបៃមានផ្ទៃក្រឡាលើសពី ១៥ម៉ែត្រការ៉េ ដល់៥០ម៉ែត្រការ៉េ<br>– ធ្វើវារីវប្បកម្មក្នុងស៊ងមានផ្ទៃក្រឡាលើសពី ២,០០០ម៉ែត្រការ៉េ ដល់ ៥,០០០ម៉ែត្រការ៉េ<br>– ធ្វើវារីវប្បកម្មចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោរក្នុងស្រះមានផ្ទៃក្រឡាលើសពី ២០០ម៉ែត្រការ៉េ ដល់១,០០០ម៉ែត្រការ៉េ<br>– ធ្វើវារីវប្បកម្មចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោរក្នុងស៊ងមានផ្ទៃក្រឡាលើសពី ១០០ម៉ែត្រការ៉េ ដល់៥០០ម៉ែត្រការ៉េ<br>– ធ្វើវារីវប្បកម្មចិញ្ចឹមត្រីរ៉ស់ ត្រីឆ្តោរក្នុងបៃមានផ្ទៃក្រឡាលើសពី ១៥ម៉ែត្រការ៉េ ដល់១៥០ម៉ែត្រការ៉េ |

NASLA

| | |
|---|---|
| | – ធ្វើវារីវប្បកម្មចិញ្ចឹមត្រីរស់ ត្រីឆ្តោរពី ៥,០០០ក្បាល ដល់១០,០០០ក្បាល។<br><br>៤. ផ្នែកសមុទ្រ<br>– ធ្វើវារីវប្បកម្មក្នុងបែមានផ្ទៃក្រឡាលើសពី ២០ម៉ែត្រការ៉េ ដល់៥០ម៉ែត្រការ៉េ<br>– ធ្វើវារីវប្បកម្មស្រែបង្គា ឬស្រះមានផ្ទៃក្រឡាលើសពី ៥,០០០ម៉ែត្រការ៉េ ដល់១០,០០០ម៉ែត្រការ៉េ<br>– ធ្វើវារីវប្បកម្មវារីរុក្ខជាតិគ្រប់ប្រភេទមានផ្ទៃក្រឡាលើសពី ៥,០០០ម៉ែត្រការ៉េ ដល់១០,០០០ម៉ែត្រការ៉េ<br>– ធ្វើវារីវប្បកម្មវារីសត្វគ្រប់ប្រភេទមានផ្ទៃក្រឡាលើសពី ៣,៥០០ម៉ែត្រការ៉េ ដល់១០,០០០ម៉ែត្រការ៉េ។ |
| **វិស័យធនធានទឹក** | |
| ១. ការងារជារាសាស្ត្រ | ១. ការគ្រប់គ្រង ការសាងសង់ ការជួសជុល និងការថែទាំប្រឡាយជើងក្អែប<br>២. ការសាងសង់ ការជួសជុល និងការថែទាំប្រព័ន្ធជារាសាស្ត្រខ្នាតតូច<br>៣. ការបង្កើត និងការគ្រប់គ្រងសហគមន៍កសិករអ្នកប្រើប្រាស់ទឹកក្នុងប្រព័ន្ធជារាសាស្ត្រខ្នាតតូច។ |
| ២. ការងារគ្រប់គ្រងដីចំណីទន្លេ ស្ទឹង ព្រែក ប្រឡាយ ទំនប់ទឹក | ១. ការគ្រប់គ្រង ការការពារដីចំណីទន្លេ ស្ទឹង ព្រែក ប្រឡាយ ទំនប់ទឹក។ |
| ៣. ការងារគ្រប់គ្រងស្ថានីយ៍បូមទឹក | ១. ការបង្កើត និងការគ្រប់គ្រងស្ថានីយ៍បូមទឹកស្រោចស្រព។ |
| **វិស័យបរិស្ថាន និងធនធានធម្មជាតិ** | |
| ១. គ្រប់គ្រងប្រព័ន្ធតំបនការពារធម្មជាតិ | ១ ការគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ .<br>– រៀបចំ និងអនុវត្តផែនការសកម្មភាពគ្រប់គ្រងប្រព័ន្ធតំបន់ការពារធម្មជាតិ |

NASLA

| | |
|---|---|
| | – ចាត់វិធានការ ដើម្បីត្រួតពិនិត្យ ទប់ស្កាត់ ស្រាវជ្រាវ និងបង្ក្រាបបទល្មើសធនធានធម្មជាតិ សកម្មភាពធ្វើឱ្យខូច ឬប៉ះពាល់អរិជ្ជមាន និងភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ<br>– ត្រួតពិនិត្យរាល់ការនាំចេញ ការនាំចូលនូវប្រភេទសត្វ រុក្ខជាតិ គ្រាប់រុក្ខជាតិ និងសំណាកក្នុងតំបន់ការពារធម្មជាតិ<br>– ប្រមូល និងផ្តល់ទិន្នន័យទាក់ទងនឹងវិស័យសេដ្ឋកិច្ច សង្គម និងបរិស្ថានក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះសម្រាប់រៀបចំផែនទីប្រើប្រាស់ដីធ្លី<br>– ចូលរួមកំណត់ព្រំប្រទល់ បោះបង្គោលព្រំ ថែទាំបង្គោលព្រំ កំណត់បែងចែកតំបន់គ្រប់គ្រង និងរៀបចំអនុវត្តផែនការគ្រប់គ្រងតំបន់ការពារធម្មជាតិក្នុងភូមិសាស្ត្រស្រុក<br>– ចូលរួមសិក្សាស្រាវជ្រាវ និងកំណត់ពីសក្តានុពល និងស្នើសុំបង្កើតតំបន់ការពារធម្មជាតិថ្មី<br>– កៀរគរធនធាន និងធ្វើកិច្ចសហប្រតិបត្តិការជាមួយអ្នកពាក់ព័ន្ធនានាដើម្បីគាំទ្រដល់ការការពារ ការអភិរក្ស និងការស្តារជីវៈចម្រុះ ព្រមទាំងការអភិវឌ្ឍសមត្ថភាពគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍធនធានធម្មជាតិ។ |
| ២. ការគ្រប់គ្រង សហគមន៍ តំបន់ការពារធម្មជាតិ | ២. ការបង្កើត ការគ្រប់គ្រង និងការគាំទ្រសហគមន៍តំបន់ការពារធម្មជាតិ<br>– សិក្សាសក្តានុពលដើម្បីរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ផ្តល់គោលការណ៍អនុញ្ញាត និងទទួលស្គាល់លើការបង្កើតសហគមន៍តំបន់ការពារធម្មជាតិក្នុងតំបន់ប្រើប្រាស់ដោយចីរភាព និងតំបន់សហគមន៍ដែលទទួលបានការ ឯកភាពពីក្រសួងបរិស្ថាន ព្រមទាំងសម្របសម្រួលរៀបចំរចនាសម្ព័ន្ធ និងលក្ខន្តិកៈសហគមន៍តំបន់ការពារធម្មជាតិ<br>– គ្រប់គ្រង និងអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ និងទេសចរណ៍ធម្មជាតិ<br>– គាំទ្រ តាមដាន ត្រួតពិនិត្យ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពសហគមន៍តំបន់ការពារធម្មជាតិ<br>– សិក្សា វាយតម្លៃ និងកំណត់តំបន់ដែលមានសក្តានុពលក្នុងការរៀបចំសហគមន៍ទេសចរណ៍ធម្មជាតិ<br>– ការពារ និងអភិរក្សបេតិកភណ្ឌវប្បធម៌ក្នុងតំបន់ការពារធម្មជាតិ<br>– ពិនិត្យ តាមដាន និងរាយការណ៍អំពីស្ថានភាពតំបន់បេតិកភណ្ឌធម្មជាតិ |

NASLA

| | |
|---|---|
| | – ជំរុញ និងបង្កើនការចូលរួមថែរក្សាប្រពៃណី ទំនៀមទម្លាប់ និងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់សហគមន៍ជនជាតិដើមភាគតិចដែលរស់នៅក្នុង និងក្បែរតំបន់ការពារធម្មជាតិ<br>– ធ្វើបច្ចុប្បន្នភាព គ្រប់គ្រងទិន្នន័យ និងតាមដាន ត្រួតពិនិត្យការអនុវត្តសកម្មភាពគម្រោងវិនិយោគទេសចរណ៍ធម្មជាតិ<br>– ផ្សព្វផ្សាយច្បាប់ គោលការណ៍ណែនាំ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងគម្រោងវិនិយោគទេសចរណ៍ធម្មជាតិដល់អ្នកពាក់ព័ន្ធ<br>– សហការជំរុញឱ្យមានការគាំទ្រ និងលើកទឹកចិត្តដល់សហគមន៍មូលដ្ឋានក្នុងការរៀបចំគម្រោងអភិវឌ្ឍន៍សហគមន៍ទេសចរណ៍ធម្មជាតិ<br>– សហការសិក្សា និងរៀបចំការកំណត់ព្រំប្រទល់ សម្របសម្រួលបោះបង្គោលព្រំដីនៃគម្រោងវិនិយោគទេសចរណ៍ ធម្មជាតិ។ |
| ៣. ការងារគាំពារបរិស្ថាន | ១. ការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់<br>២. ការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន។ |
| ៤ .ការងារផ្សព្វផ្សាយ | ១. ការផ្សព្វផ្សាយច្បាប់ និងការបង្កើនចំណេះដឹងបរិស្ថាន<br>– ផ្សព្វផ្សាយច្បាប់ គោលការណ៍ លិខិតបទដ្ឋានគតិយុត្ត និងព័ត៌មាននានាពាក់ព័ន្ធនឹងតំបន់ការពារធម្មជាតិ និង បរិស្ថានដល់ប្រជាពលរដ្ឋ និងអ្នកពាក់ព័ន្ធនានា<br>– សម្របសម្រួល និងចលនាអនុវត្តសកម្មភាពមេត្រីភាពបរិស្ថាននៅតាមគ្រឹះស្ថានសិក្សា អង្គភាព និងអាជ្ញាធរ មូលដ្ឋាន ដូចជាសាលាមេត្រីបរិស្ថាន អារាមមេត្រីបរិស្ថាន ឃុំសង្កាត់មេត្រីបរិស្ថាន មន្ទីរពេទ្យមេត្រីបរិស្ថាន<br>– សម្រួបសម្រួល និងដឹកនាំការរៀបចំព្រឹត្តិការណ៍បរិស្ថាននានា។ |
| ៥. ការងារអភិវឌ្ឍដោយចីរភាព | ១. ការអភិវឌ្ឍដោយចីរភាព<br>– បញ្ជ្រាបភាពធន់នឹងអាកាសធាតុ<br>– បញ្ជ្រាបការងារអភិវឌ្ឍន៍ទីក្រុងនិរន្តរភាព និងទស្សនទានការអភិវឌ្ឍបៃតងទៅក្នុងដំណើរការរៀបចំផែនការទីប្រជុំជន<br>– ត្រួតពិនិត្យ និងវាយតម្លៃលើការងារអភិវឌ្ឍន៍ស្រុកនិរន្តរភាព និងការអភិវឌ្ឍបៃតង និងចូលរួមក្នុងកម្មវិធីប្រឡងប្រណាំងស្រុកស្អាត និងស្រុកនិរន្តរភាព<br>– ប្រមូល និងគ្រប់គ្រងទិន្នន័យជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងជីវសុវត្ថិភាព<br>– បញ្ជ្រាបការយល់ដឹង និងពង្រឹងការអនុវត្តលិខិតបទដ្ឋានគតិយុត្តគោលនយោបាយ ដើម្បីជានាមុខងារ សេវាកម្ម និងតម្លៃជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី។ |

NASLA

**ឧបសម្ព័ន្ធទី៥ ÷ មុខងារ និងមុខងាររងពាក់ព័ន្ធការិយាល័យសេដ្ឋកិច្ច និងអភិវឌ្ឍន៍សហគមន៍**

| **មុខងារ** | **មុខងាររង ឬសកម្មភាព** |
|---|---|
| **វិស័យសាធារណការ និងដឹកជញ្ជូន** | |
| ១. ការងារផ្លូវថ្នល់ | ១. ការគ្រប់គ្រងដីចំណីផ្លូវជាតិ និងផ្លូវខេត្តដែលស្ថិតនៅក្នុងទីប្រជុំជន<br>២. ការសាងសង់ ការជួសជុល និងការថែទាំផ្លូវស្រុក និងផ្លូវទីប្រជុំជននានាក្នុងស្រុក។ |
| ២. ការផ្តល់សេវារដ្ឋបាល | ១. ការគ្រប់គ្រង ការចុះបញ្ជី និងការផ្តល់លិខិតអនុញ្ញាតធ្វើអាជីវកម្មយានដ្ឋានជួសជុល កែច្នៃ ដំឡើងទោចក្រយានយន្ត<br>២. ការគ្រប់គ្រង និងផ្តល់លិខិតអនុញ្ញាតជរចម្លង<br>៣. សេវាកម្មម៉ូតូ (ចុះបញ្ជី ប្តូរ ទុតិយតា និងតតិយតាបណ្ណសម្គាល់ ប្តូរ ទុតិយតា និងតតិយតាផ្លាកលេខ)<br>៤. សេវាកម្មត្រីចក្រយានយន្ត និងរ៉ឺម៉កទោចក្រយានយន្ត (ចុះបញ្ជីត្រីចក្រយានយន្ត ចុះបញ្ជីរ៉ឺម៉ក ទោចក្រយានយន្ត ប្តូរ ទុតិយតា និងតតិយតាបណ្ណសម្គាល់ត្រីចក្រយានយន្ត ប្តូរ ទុតិយតា តតិយតាផ្លាកលេខត្រីចក្រយានយន្ត និងរ៉ឺម៉កទោចក្រយានយន្ត)<br>៥. ការត្រួតពិនិត្យលក្ខណៈបច្ចេកទេសត្រីចក្រយានយន្ត និងទោចក្រយានយន្តសណ្តោងរ៉ឺម៉ក (ប្រគល់ ទុតិយតា និងតតិយតាវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេស)។ |
| **វិស័យឧស្សាហកម្ម និងសិប្បកម្ម** | |
| ១. ការងារផ្គត់ផ្គង់ទឹកស្អាត | ១. ការគ្រប់គ្រងអាជីវកម្មផ្គត់ផ្គង់ទឹកស្អាតតាមទុយោ (បន្ទាប់ពីមានអាជ្ញាប័ណ្ណពីក្រសួងឧស្សាហកម្ម និងសិប្បកម្ម)។ |
| ២.ការងារផ្តល់សេវារដ្ឋបាល | ១. ការគ្រប់គ្រង និងការចុះបញ្ជីសិប្បកម្ម សហគ្រាសធុនតូចដែលគ្មានហានិភ័យ និងមានទុនវិនិយោគសមមូល៨០លានរៀលចុះក្រោម (ការបង្កើតឬការចុះបញ្ជី ការចេញវិញ្ញាបនបត្រអនុញ្ញាតដំណើរការ ការបន្ថែមមុខផលិតផលថ្មី ការពង្រីកផលិតកម្ម ការប្តូរទីតាំងសិប្បកម្ម ការប្តូរម្ចាស់សិប្បកម្ម( ការផ្ទេរ |

NASLA

| | |
|---|---|
| | សិទ្ធិ) ការប្តូរឈ្មោះសិប្បកម្ម និងការស្នើសុំលិខិតទុតិយតា)<br>២. សេវាកម្មបើកកន្លែងជួសជុលគ្រឿងអគ្គិសនីអេឡិចត្រូនិក លាងរថយន្ត និងលាងម៉ូតូ។ |
| **វិស័យរ៉ែ និងថាមពល** | |
| ១. ការងារធនធានរ៉ែ | ១. ការផ្តល់ និងការចុះបញ្ជីអាជ្ញាបណ្ណសិប្បកម្មធនធានរ៉ែសម្រាប់សេវាកម្មជីកអាចម៍ដី-រណ្តៅដីចល័តដែលមានក្រឡាផ្ទៃមិនលើសពី០,៥ហិកតា និងជម្រៅមិនលើសពី០៣ម៉ែត្រ ឬប្រតិបត្តិការបកយកអាចម៍ដីក្រឡាផ្ទៃមិនលើសពី០១ហិកតា និងជម្រៅមិនលើសពី០១ម៉្រែត<br>២. ការចុះបញ្ជីទីតាំងដេប៉ូពាណិជ្ជកម្មផលិតផលរ៉ែខ្សាច់ គ្រួស និងថ្មសំណង់។ |
| ២.ការងារថាមពល | ១. ការគ្រប់គ្រង និងការអនុញ្ញាតការតម្លើងម៉ាស៊ីនអគ្គិសនីសម្រាប់ធ្វើសេវាកម្មបញ្ចូលអាគុយដែលមានកម្លាំងមិនលើសពី២៥គីឡូវ៉ាត់។ |
| ៣.ការងារប្រេងកាត | ១. ការគ្រប់គ្រង និងអនុញ្ញាតអាជីកម្មលក់ឧស្ម័នឥន្ទនៈក្នុងកំប៉ុង ឬក្នុងធុងដែលមានចំណុះចាប់ពី៤៥ គីឡូក្រាមចុះក្រោម<br>២. ការគ្រប់គ្រង និងអនុញ្ញាតអាជីវកម្មលក់ និងប្តូរប្រេងម៉ាស៊ីន។ |
| **វិស័យទេសចរណ៍** | |
| ១. ការគ្រប់គ្រងតំបន់ទេសចរណ៍ធម្មជាតិ និងតំបន់រមនីយដ្ឋានទេសចរណ៍ | ១. ការគ្រប់គ្រង និងអភិវឌ្ឍតំបន់ទេសចរណ៍ធម្មជាតិ និងតំបន់រមណីយដ្ឋានទេសចរណ៍។ |
| ២. ការផ្តល់សេវារដ្ឋបាល | ១. ផ្ទះសំណាក់ចំណុះត្រឹម០៨បន្ទប់ចុះក្រោម<br>២. បន្ទប់ជួល<br>៣. ផ្ទះមានបន្ទប់ជួល<br>៤. អាហារដ្ឋាន និងភោជនីយដ្ឋានទេសចរណ៍ចាប់ពី៥០នាក់/កៅអី ចុះក្រោម (លើកលែងតែមានលក្ខណៈស្តង់ដា ឬគ្រប់គ្រងដោយជនបរទេស)<br>៥. អាហារដ្ឋាន និងភោជនីយដ្ឋានក្នុងស្រុកចាប់ពី៥០នាក់/កៅអី ចុះក្រោម |

NASLA

| | |
|---|---|
| | (រួមមានតូបលក់អាហារ ហាងលក់គុយទាវ កាហ្វេ និងហាងលក់សាច់អាំងជម្មតា)<br>៦. មធ្យោបាយដឹកជញ្ជូនទេសចរណ៍រួមមាន រថយន្តដឹកទេសចរណ៍ចាប់ពី ០៥កៅអីចុះក្រោម ម៉ូតូឌុបទេសចរណ៍ ម៉ូតូដួលទេសចរណ៍ ឬរ៉ឺម៉កម៉ូតូដឹកទេសចរណ៍<br>៧. ខារ៉ាអូខេចាប់ពី០៥បន្ទប់ចុះក្រោម<br>៨. ម៉ាស្សាសុខភាពចំណុះពី០៥គ្រែ ឬ០៥កៅអីចុះក្រោម<br>៩. ស្នូកឃ័រចាប់ពី០៥តុចុះក្រោម។ |
| **វិស័យអភិវឌ្ឍន៍ជនបទ** | |
| ១. ការអភិវឌ្ឍផ្លូវជនបទ | ១. ការសាងសង់ ការជួសជុល និងការថែទាំផ្លូវជនបទ ស្ពាន លូ។ |
| ២. ការគ្រប់គ្រង និងផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត | ១. ការសាងសង់ ការជួសជុល និងការថែទាំផ្លូវជនបទ ស្ពាន លូ។ |
| ៣. ការគ្រប់គ្រង និងការផ្តល់ សេវាអនាម័យជនបទ | ១. ការសាងសង់ ការជួសជុល និងការថែទាំបង្គន់អនាម័យសាធារណៈ<br>២. ការអប់រំ ផ្សព្វផ្សាយអំពីការលើកកម្ពស់អនាម័យជនបទ<br>៣. ការឧបត្ថម្ភធនលើការសាងសង់បង្គន់គ្រួសារក្រីក្រ។ |
| ៤. ការគ្រប់គ្រងផ្សារសហគមន៍ | ១. ការបង្កើត និងការគ្រប់គ្រងផ្សារសហគមន៍។ |
| **វិស័យពាណិជ្ជកម្ម** | |
| ១. ការងារអាជីវកម្ម សេវាកម្ម និង ពាណិជ្ជកម្ម | ១. ការចេញលិខិតអនុញ្ញាតធ្វើអាជីវកម្ម សេវាកម្ម ពាណិជ្ជកម្ម<br>២. ការចេញលិខិតអនុញ្ញាតប្រកបអាជីវកម្មលោហធាតុត្បូងថ្មមានតម្លៃជាគ្រឿងអលង្ការគ្រប់ប្រភេទ។ |
| ២. ការងារបិទស្លាកថ្លៃលើមុខទំនិញ | ១. ការត្រួតពិនិត្យលើការបិទស្លាកថ្លៃលើមុខទំនិញ និងសេវាគ្រប់ប្រភេទ និងការស្រង់សន្ទស្សន៍ថ្លៃទំនិញចាំបាច់ប្រចាំជីវភាពប្រចាំថ្ងៃ។ |

NASLA

| | |
|---|---|
| **៣ .ការងារទីផ្សារ** | ១. ការស្វែងរកទីផ្សារសម្រាប់ផលិតផលរបស់ប្រជាពលរដ្ឋ។ |
| **វិស័យប្រៃសណីយ៍ និងទូរគមនាគមន៍** | |
| ១. ការងារប្រៃណីយ៍ និងទូរគមនាគមន៍ | ១. ត្រួតពិនិត្យ និងរាយការណ៍អំពីបទល្មើសពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍ សម្ភារបរិក្ខារទូរគមនាគមន៍ និងការធ្វើអាជីវកម្មដោយខុសច្បាប់<br>២. តាមដានត្រួតពិនិត្យរាល់សកម្មភាពនៃការសាងសង់ហេដ្ឋារចនាសម្ព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ក្នុងភូមិសាស្ត្រស្រុកដោយមានការសហការជាមួយប្រតិបត្តិករទូរគមនាគមន៍<br>៣. រាយការណ៍អំពីកម្រិតគុណភាព និងតំបន់ពុំមានសេវាកម្មប្រៃសណីយ៍ និងទូរគមនាគមន៍<br>៤. ប្រមូលទិន្នន័យចំនួនបង្គោលអង់តែនទូរស័ព្ទចល័ត វិទ្យុម៉ាយក្រូវ៉េវ ទីតាំងជួសជុល លក់បរិក្ខារទូរគមនាគមន៍ និងសាលបម្រើអ៊ីនធើណែតកាហ្វេ<br>៥. ស្រង់ទិន្នន័យចំនួនប្រតិបត្តិករ ឬសាខាប្រៃសណីយ៍ និងប្រតិបត្តិករទូរគមនាគមន៍ និងក្រុមហ៊ុនផ្តល់សេវាអ៊ីនធើណេត<br>៦. ផ្សព្វផ្សាយ និងជំរុញការប្រើប្រាស់បច្ចេកវិទ្យាគមនាគមន៍ និងព័ត៌មានក្នុងអង្គភាពសាធារណៈ និងសហគមន៍។ |

NASLA

**ឧបសម្ព័ន្ធទី៦ ÷ មុខងារ និងមុខងាររងពាក់ព័ន្ធការិយាល័យសង្គមកិច្ច និងសុខុមាលភាពសង្គម**

| **មុខងារ** | **មុខងាររង ឬសកម្មភាព** |
|---|---|
| **វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** | |
| ១. ការងារកុមារកំព្រា និងកុមារងាយរងគ្រោះ | ១. ការគ្រប់គ្រងករណីកុមារកំព្រា និងងាយរងគ្រោះ<br>– គ្រប់គ្រង និងកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទលើកុមារ<br>– គ្រប់គ្រង ស្វែងរក និងប៉ាន់ប្រមាណគ្រួសារងាយរងគ្រោះ<br>– គ្រប់គ្រង តាមដាន និងបិទករណីកុមាររងគ្រោះដែលបានសមាហរណកម្មទៅសហគមន៍<br>– ផ្សព្វផ្សាយគោលនយោបាយ និងបទដ្ឋានអប្បបរមាស្តីពីកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើធ្វើអាជីវកម្មផ្លូវភេទ និងរំលោភបំពានផ្លូវភេទលើកុមារ។ |
| ២. ការងារជនរងគ្រោះ និងជនងាយរងគ្រោះ | ១. ការគ្រប់គ្រង និងការកំណត់អត្តសញ្ញាណជនរងគ្រោះ និងងាយរងគ្រោះ<br>– ប្រមូល និងគ្រប់គ្រងទិន្នន័យជនងាយរងគ្រោះដោយគ្រោះមហន្តរាយ ជនក្រីក្រ និងគ្រួសារនៅសហគមន៍<br>– ប្រមូល និងគ្រប់គ្រងទិន្នន័យជនអនាថា<br>– គ្រប់គ្រង កំណត់អត្តសញ្ញាណ និងតាមដានជនផ្ទុកមេរោគអេដស៍ ជំងឺអេដស៍<br>– គ្រប់គ្រង កំណត់អត្តសញ្ញាណ និងតាមដានស្ត្រីមានផ្ទៃពោះក្រីក្រ និងកុមារក្រោម២ឆ្នាំស្ថិតនៅគ្រួសារក្រីក្រ។ |
| ៣. ការងារជនពិការ | ១. ការគ្រប់គ្រងជនពិការ និងការផ្តល់ព័ត៌មានសេវាស្តារលទ្ធភាពពលកម្ម<br>– គ្រប់គ្រង និងចងក្រងទិន្នន័យជនពិការក្រីក្រ ជនពិការភាពទូទៅ ស្ត្រីពិការ កុមារពិការ និងកីឡាករជនពិការ<br>– គ្រប់គ្រង និងផ្តល់ព័ត៌មានអំពីសេវាកម្មសម្រាប់ជនមានពិការភាព<br>– គ្រប់គ្រង និងផ្តល់ព័ត៌មានការស្នើសុំផ្តល់សេវាស្តារលទ្ធភាពពលកម្មដល់ជនពិការ។ |
| ៤. ការងារបេឡាជាតិ អតីតយុទ្ធជន និង បេឡាជាតិសន្តិសុខសង្គម | ១. ការគ្រប់គ្រង និងកំណត់អត្តសញ្ញាណលើមុខសញ្ញាបេឡាជាតិអតីតយុទ្ធជន និងបេឡាជាតិសន្តិសុខសង្គមសម្រាប់ មន្ត្រីរាជការស៊ីវិល<br>– គ្រប់គ្រងទិន្នន័យនិវត្តជន (និវត្តជនចាស់ ថ្មី ផ្លាស់ប្តូរទីលំនៅ ទទួលមរណភាព ឬនិវត្តជនត្រូវបានលុបឈ្មោះ) |

NASLA

| | |
|---|---|
| | – គ្រប់គ្រងស្ថិតិ តាមដាន ត្រួតពិនិត្យស្ថានភាពអតីតយុទ្ធជនគ្រប់ប្រភេទ និងគ្រួសារ<br>– គ្រប់គ្រង និងស្នើសុំផ្ទេរលំនៅដ្ឋានរបស់អតីតយុទ្ធជន និងគ្រួសារ<br>– គ្រប់គ្រង និងស្នើសុំលុបឈ្មោះអតីតយុទ្ធជនដែលទទួលមរណភាព<br>– គ្រប់គ្រងទិន្នន័យជនបាត់បង់សម្បទាវិជ្ជាជីវៈ<br>– គ្រប់គ្រងអ្នកនៅក្នុងបន្ទុករបស់និវត្តជន និងជនបាត់បង់សម្បទាវិជ្ជាជីវៈ ឬអ្នកនៅក្នុងបន្ទុករបស់សពនិវត្តជន និងសពជនបាត់បង់សម្បទាវិជ្ជាជីវៈ មានប្រពន្ធ កូន<br>– គ្រប់គ្រង និងស្នើសុំលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារ ដែលផុតសុពលភាពទទួលរបបសន្តិសុខសង្គម<br>– គ្រប់គ្រង និងស្នើសុំលុបឈ្មោះអតីតយុទ្ធជន និងគ្រួសារ ដែលមិនបានបើកប្រាក់របបសន្តិសុខសង្គមរបស់ខ្លួនដោយគ្មានមូលហេតុ<br>– គ្រប់គ្រង និងស្នើសុំបញ្ចូល ឬលុបអ្នកក្នុងបន្ទុកអតីតយុទ្ធជន និងគ្រួសារ ដើម្បីបានទទួលរបបឧបត្ថម្ភប្រចាំខែ<br>– គ្រប់គ្រង និងទទួលសំណើអតីតយុទ្ធជន និងគ្រួសារ ដែលបានបោះបង់របបសន្តិសុខសង្គម<br>– សហការជាមួយសមាគមអតីតយុទ្ធជនកម្ពុជាក្នុងការបញ្ចូល ឬលុបអតីតយុទ្ធជនពីសមាជិកសមាគមអតីតយុទ្ធជនកម្ពុជា<br>– គ្រប់គ្រងព័ត៌មានអតីតយុទ្ធជនសម្រាប់ទទួលសេវាសុខភាព ឬសេវានានាពីរដ្ឋ<br>– សហការជាមួយធនាគារដៃគូក្នុងការគ្រប់គ្រង បើកផ្តល់របបសន្តិសុខសង្គម។ |
| ៥. ការងារអតីតយុទ្ធជន និងគ្រួសារ | ១. ការគ្រប់គ្រង និងកំណត់អត្តសញ្ញាណអតីតយុទ្ធជន និងគ្រួសារ<br>– ប្រមូលទិន្នន័យពីស្ថានភាពជីវភាព និងតម្រូវការរបស់អតីតយុទ្ធជន និងគ្រួសារជនពលីមរណៈ<br>– ផ្តល់សេវាឆ្លើយតបនឹងតម្រូវការជាក់ស្តែងរបស់អតីតយុទ្ធជន និងគ្រួសារជនពលីមរណៈ<br>– គ្រប់គ្រងទិន្នន័យអតីតយុទ្ធជន និងគ្រួសារដែលទទួលផ្ទះ។ |
| ៦. ការងារមណ្ឌលស្តារនីតិសម្បទា | ១. ការគ្រប់គ្រង និងសហការជាមួយមណ្ឌលស្តារនីតិសម្បទាខេត្ត<br>– គ្រប់គ្រងទិន្នន័យអនីតិជនទំនាស់នឹងច្បាប់<br>– គ្រប់គ្រង តាមដានអនីតិជនដែលបានស្តារនីតិសម្បទាដោយសារញៀនគ្រឿងញៀនក្រោយសមាហរណកម្មទៅ សហគមន៍។ |

NASLA

| | |
|---|---|
| ៧. ការងារសមាគមមនុស្សវ័យចាស់ | – ១. ការគ្រប់គ្រងទិន្នន័យមនុស្សវ័យចាស់ក្នុងសហគមន៍<br>– គ្រប់គ្រង និងស្រង់ទិន្នន័យ សមាជិក សមាជិកាសមាគមមនុស្សវ័យចាស់<br>– ផ្សព្វផ្សាយលក្ខន្តិកៈសមាគមមនុស្សវ័យចាស់<br>– តាមដានត្រួតពិនិត្យ និងវាយតម្លៃការប្រើប្រាស់ថវិកាវិភាគទានរបស់សមាគមមនុស្សវ័យចាស់។ |
| ៨. ការងារត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល | ១. ការត្រួតពិនិត្យមណ្ឌលថែទាំកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល។ |
| **វិស័យសុខាភិបាល** | |
| ១.ការផ្តល់សេវារដ្ឋបាល | ១.ផ្តល់លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ពិនិត្យស្ត្រីមានផ្ទៃពោះមុន និងក្រោយសម្រាល<br>២.ផ្តល់លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ព្យាបាលដោយចលនា<br>៣.ផ្តល់លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ថែទាំជំងឺ<br>៤. ផ្តល់លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរឈ្មោះឱសថការី ឬប្តូរម្ចាស់ទុននៃឱសថស្ថានរង "ក"<br>៥. ផ្តល់លិខិតអនុញ្ញាតបន្តសុពលភាពឱសថស្ថានរង "ខ"<br>៦. ផ្តល់លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ព្យាបាលជំងឺមាត់ធ្មេញ<br>៧. ផ្តល់លិខិតអនុញ្ញាតស្នើសុំបើកថ្មី បន្តសុពលភាព និងប្តូរទីតាំងបន្ទប់ព្យាបាលជំងឺទូទៅ<br>៨. ផ្តល់វិញ្ញាបនបត្របញ្ជាក់អនាម័យចំណីអាហារតាមភោជនីយដ្ឋាន និងអាហារដ្ឋានក្នុងស្រុក ឬអាហារដ្ឋានទេសចរណ៍ដែលមានចំណុះត្រឹម៥០នាក់។ |

| | |
|---|---|
| **វិស័យកិច្ចការនារី** | |
| ១.ការងារស្ត្រី និងកុមារ | ១.ការសម្របសម្រួល ទប់ស្កាត់ និងដោះស្រាយអំពើហិង្សាលើស្ត្រី និងកុមារ និងការជួញដូរស្ត្រី និងកុមារ<br>២.ការគ្រប់គ្រង និងប្រមូលទិន្នន័យស្ត្រី និងកុមារនៅតាមមូលដ្ឋាន<br>៣.ការអប់រំផ្សព្វផ្សាយអំពីសិទ្ធិស្ត្រី និងកុមារ ដើម្បីលើកកម្ពស់សីលធម៌សង្គម និងសមធម៌យេនឌ័រ។ |
| **វិស័យធម្មការ និងសាសនា** | |
| ១. ការងារធម្មការ និង សាសនា | ១. ការពិនិត្យ និងផ្តល់ទិដ្ឋាការសំណើសុំបួស<br>២. ការរៀបចំបង្កើតគណៈកម្មការអាចារ្យ និងគណៈកម្មការវត្ត<br>៣. ការសហការថេរសភាសង្ឃដោះស្រាយអធិករណ៍ផ្សេងៗតាមវត្ត<br>៤. ការលើកកម្ពស់ការងារពុទ្ធសាសនា និងសាសនាផ្សេងៗទៀត<br>៥. ការសម្របសម្រួលសកម្មភាព និងកម្មវិធីសាសនាផ្សេងៗ<br>៦. ការទប់ស្កាត់ការរំលោភអាណាធិបតេយ្យ។ |
| **វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ** | |
| ១. សេវាការងារ និងទីផ្សារការងារ | ១. ផ្សព្វផ្សាយសេវាការងារ និងព័ត៌មានទីផ្សារការងារ។ |
| ២. ការផ្តល់សេវារដ្ឋបាល | ១. ការចុះបញ្ជិកាសៀវភៅប្រចាំគ្រឹះស្ថាន(កម្មករនិយោជិតតិចជាង៨នាក់)<br>២. ការចុះបញ្ជិកាសៀវភៅបើកប្រាក់(កម្មករនិយោជិតតិចជាង៨នាក់)<br>៣. ការចុះបញ្ជិកាសៀវភៅចុះនាមក្មេងអាយុ ១២ឆ្នាំ ដល់ក្រោម ១៥ឆ្នាំ (កម្មករនិយោជិតតិចជាង៨នាក់)<br>៤. ការចុះបញ្ជិកាសៀវភៅចុះនាមក្មេងអាយុ ១៥ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ (កម្មករនិយោជិតតិចជាង៨នាក់)<br>៥. ការផ្តល់ទិដ្ឋាការជូនក្រុមហ៊ុនដែលស្នើសុំប្រើប្រាស់កម្មករនិយោជិតវ័យក្មេង (កម្មករនិយោជិតតិចជាង៨នាក់)។ |

| វិស័យវប្បធម៌ និងវិចិត្រសិល្បៈ | |
|---|---|
| ១. ការងារវប្បធម៌ និងវិចិត្រសិល្បៈ | ១. ការការពារ និងអភិរក្សទីទួលបុរាណដែលមានលក្ខណៈជាប្រវត្តិសាស្ត្រក្នុមូលដ្ឋាន<br>២. ការថែរក្សាការពារ និងលើកកម្ពស់សម្បត្តិវប្បធម៌ក្នុងមូលដ្ឋាន<br>៣. ការទប់ស្កាត់រាល់សកម្មភាពបំផ្លាញសម្បត្តិវប្បធម៌ សកម្មភាពផ្សព្វផ្សាយភាពយន្តវីដេអូដែលប៉ះពាល់ដល់ទំនៀមទម្លាប់ និងប្រពៃណីជាតិ<br>៤. ការបំផុសប្រជាជន មហាជនក្នុងមូលដ្ឋានចូលរួមក្នុងសកម្មភាពវប្បធម៌ និងការរៀបចំពិធីបុណ្យប្រពៃណីជាតិ<br>៥. ការទប់ស្កាត់ជាប្រចាំចំពោះការបំផ្លិចបំផ្លាញ ការលួច និងការធ្វើចរាចរណ៍ជួញដូរផលិតផលវប្បធម៌ខុសច្បាប់<br>៦. ការពង្រឹង និងពង្រីកវប្បធម៌នៅតាមវត្តអារាម។ |
| ២. ការផ្តល់សេវារដ្ឋបាល | ១. កម្មវិធីសម្តែងផ្សេងៗ (ក្រៅផ្លូវការ)<br>– ការប្រគំតន្ត្រីនៅទីសាធារណៈលក្ខណៈជាតិ<br>– ការសម្តែងទស្សនីយភាពល្ខោន លក់សំបុត្រ<br>– ការសម្តែងល្ខោនគ្រប់ទម្រង់<br>– អាជីវកម្មរាំកំសាន្ត លក់សំបុត្រ។<br>២. ការបញ្ចាំងភាពយន្ត វីដេអូ (ផ្សាយពាណិជ្ជកម្ម កំដរពិធីបុណ្យផ្សេងៗ និងកំដរភ្ញៀវ)<br>៣. អាជីវកម្មលក់ ជួលស្នាដៃភាពយន្ត វីដេអូ<br>– ហាងលក់ ជួលស៊ីឌី វីស៊ីឌី ឌីវីឌី<br>– អគារលក់ស៊ីឌី វីស៊ីឌី ឌីវីឌី។<br>៤. ស្លាកសញ្ញាអាជីវកម្ម<br>– ផ្ទាំងយីហោគ្រប់ប្រភេទ ទំហំចាប់ពី៤ម៉ែត្រការ៉េចុះក្រោម<br>– ប័ណ្ណប្រកាសផ្សាយពាណិជ្ជកម្ម(Poster)<br>– ផ្ទាំងរូបភាព និមិត្តសញ្ញាផ្សេងៗចាប់ពីទំហំ៤ម៉ែត្រការ៉េចុះក្រោម<br>– បដាផ្សាយពាណិជ្ជកម្ម។ |

NASLA

| | |
|---|---|
| | ៥. ការផ្តល់អាជ្ញាប័ណ្ណ (ផលិតស្លាកសញ្ញា ផ្ទាំងសញ្ញា ផ្ទាំងផ្សាយពាណិជ្ជកម្ម)<br>៦. អាជីវកម្មគ្រឿងបំពងសម្លេង (ជួលធុងបាស់ និងឧគ្ឃោសនសព្ទ)<br>៧. អាជីវកម្មលក់សៀវភៅ (បណ្ណាគារដែលមានផ្ទៃក្រឡាក្រោម៥០ម៉ែត្រការ៉េ)<br>៨. អាជីវកម្មសិល្បៈសូនរូប<br>– ទីតាំងផលិត និងលក់ចម្លាក់ ពុម្ពស៊ីម៉ងត៍<br>– ទីតាំងផលិត លក់ចម្លាក់ម្នាងសិលា<br>– ជាងគំនូរ។<br>៩. អាជីវកម្មថតរូប (ផ្ទះ ឬអគារផ្តិតរូប ថតរូប ថតវីដេអូ)<br>១០. អាជីវកម្មកាត់សក់ អ៊ុតសក់ លម្អក្រចក និងសម្អាងការ (ហាង)។ |

NASLA

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាល**

**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ០០០១ អ.ស.រ /ទរប

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតក្រុមការងាររៀបចំវគ្គបណ្ដុះបណ្ដាលតម្រង់ទិស សម្រាប់ក្រុមគោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ

## អគ្គនាយក នៃអគ្គនាយកដ្ឋានរដ្ឋបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១០៩ អនក្រ.បក ចុះថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ១៨២ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង
- បានឃើញអនុក្រឹត្យលេខ១៨៣ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលខណ្ឌនៃរាជធានីភ្នំពេញ
- បានឃើញអនុក្រឹត្យលេខ១៨៤ អនក្រ.បក ចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលស្រុក
- បានឃើញអនុក្រឹត្យលេខ១៩៣ អនក្រ.បក ចុះថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការប្រគល់មុខងារ និងផ្ដល់សេវាសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត
- យោងសេចក្ដីសម្រេចលេខ០៦៩ សសរ/គ.ជ.អ.ប ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៩ ស្ដីពីការដាក់ឱ្យអនុវត្តផែនការសកម្មភាព និងក្របខ័ណ្ឌពេលវេលាសម្រាប់អនុវត្តអនុក្រឹត្យស្ដីពីមុខងារ និងរចនាសម្ព័ន្ធរដ្ឋបាលក្រុង រដ្ឋបាលស្រុក រដ្ឋបាលខណ្ឌ និងអនុក្រឹត្យស្ដីពីការផ្ទេរមុខងារក្នុងវិស័យសុខាភិបាលទៅឱ្យរដ្ឋបាលរាជធានី ខេត្ត របស់គ.ជ.អ.ប។

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងាររៀបចំវគ្គបណ្ដុះបណ្ដាលតម្រង់ទិសសម្រាប់ក្រុមគោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌដែលមានសមាសភាពដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. លោក | **សូ មុនីរក្សា** | នាយកសាលាជាតិរដ្ឋបាលមូលដ្ឋាន និងជាប្រធាននាយកដ្ឋានបណ្ដុះបណ្ដាល | ប្រធាន |
| ២. លោក | **លី យ៉ាសាក់** | នាយករងសាលាជាតិរដ្ឋបាលមូលដ្ឋាន | សមាជិក |

៣.លោក **គង់ ប៊ុណ្ណា** អនុប្រធានអង្គភាពនៃលេខាធិការដ្ឋានគ.ជ.អ.ប សមាជិក

៤. លោក **អ៊ុំ ចំរើន** អនុប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

៥. លោក **ស៊ិត សុលីដា** អនុប្រធាននាយកដ្ឋានបុគ្គលិក សមាជិក

៦. លោក **ញ៉ាច តុង** អនុប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ សមាជិក

៧. កញ្ញា **ម៉ៅ ម៉ាលីស** អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល សមាជិក

៨. លោក **លឹម ពុទ្ធារី** អនុប្រធាននាយកដ្ឋានបណ្តុះបណ្តាល សមាជិក

៩. លោក **សួន សំរិទ្ធ** អនុប្រធាននាយកដ្ឋានមុខងារនិងធនធាន សមាជិក

១០. លោក **ម៉ែន វីរៈយុទ្ធ** ប្រធានការិយាល័យនៃលេខាធិការដ្ឋានគ.ជ.អ.ប សមាជិក

១១.លោក **លឹម កេតដារ៉ាត** ប្រធានការិយាល័យនៃ ន.កិច្ចការរដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ សមាជិក

១២.លោក **នួច និត** ប្រធានការិយាល័យនៃនាយកដ្ឋានមុខងារនិងធនធាន សមាជិក

១៣.លោក **សុខ សុផាន់ណា** ប្រធានការិយាល័យស្តីទីនៃនាយកដ្ឋានបណ្តុះបណ្តាល សមាជិក

១៤. លោកស្រី **នី រតនា** ប្រធានការិយាល័យស្តីទីនៃនាយកដ្ឋានបណ្តុះបណ្តាល សមាជិក

១៥. លោកស្រី **សក់ ស្រីលក្ខណ៍** អនុប្រធានការិយាល័យនាយកដ្ឋានបណ្តុះបណ្តាល សមាជិក

១៦. លោក **សុខ សួរ** មន្ត្រីនៃនាយកដ្ឋានបណ្តុះបណ្តាល សមាជិក

១៧. លោក **កោះ យូរ៉ា** មន្ត្រីនៃនាយកដ្ឋានបណ្តុះបណ្តាល សមាជិក

១៨. លោក **ណាំ ទីវីរ៉ូ** មន្ត្រីនៃនាយកដ្ឋានបណ្តុះបណ្តាល សមាជិក

**ប្រការ២.—**

ក្រុមការងារត្រូវសហការជាមួយ **ឯកឧត្តម លឹម ហាំងគ្រី** ទីប្រឹក្សាក្រសួងមហាផ្ទៃ និង**ឯកឧត្តម ឈួន ប៊ុណ្ណា** ទីប្រឹក្សាក្រសួងមហាផ្ទៃ នៅក្នុងការបំពេញតួនាទី ភារកិច្ចរបស់ខ្លួននិងត្រូវស្នើសុំយោបល់ពីថ្នាក់ដឹកនាំ នៃអគ្គនាយកដ្ឋានរដ្ឋបាល ក៏ដូចថ្នាក់ដឹកនាំក្រសួងមហាផ្ទៃ តាមការចាំបាច់។

**ប្រការ៣.—**

ក្រុមការងាររៀបចំវគ្គបណ្តុះបណ្តាលតម្រង់ទិសសម្រាប់ក្រុមគោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដូចមានចែងក្នុងប្រការ១ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- រៀបចំឯកសារបណ្តុះបណ្តាលសម្រាប់វគ្គតម្រង់ទិស សម្រាប់ក្រុមគោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ
- រៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល
- រៀបចំ និងចាត់ចែងវគ្គបណ្តុះបណ្តាលតម្រង់ទិសសម្រាប់ក្រុមគោលដៅនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌ នៅទូទាំងប្រទេស
- បំពេញការងារផ្សេងៗទៀតតាមការចាំបាច់។

**ប្រការ៤.–**

សាមីខ្លួនដែលមានឈ្មោះដូចក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ចន្ទ ៤រោច ខែ បុស្ស ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ មករា ឆ្នាំ២០២០

**អគ្គនាយក**

ឡាក់ សំរឿន

**កន្លែងទទួល:**

- លេខាធិការដ្ឋាន គ.ជ.អ.ប
- នាយកដ្ឋានចំណុះអគ្គនាយកដ្ឋានរដ្ឋបាល
  "ដើម្បីជ្រាបនិងសហការអនុវត្ត"
- ដូចប្រការ១ និងប្រការ២
  "ដើម្បីមុខការ"
- ឯកសារ-កាលប្បវត្តិ